# មជ្ឈមណ្ឌលឯកសារកម្ពុជា
## ករណី រស់ ស៊ុយ "សម្ភាសក្រៅប្រវត្តិរូប"
## សម្ភាសន៍ជាមួយ រស់ ស៊ុយ អាយុ ៤៩ ឆ្នាំ ត្រូវជាសាមីខ្លួន
## រស់នៅភូមិពាមប្រជុំ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល
## ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៣
## សម្ភាសដោយ ផាន់ សុជា និង ជួង សុភារិទ្ធ

សុជាៈ លោកពូខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជាលោកពូណា ។

ស៊ុយៈ បាទ ៗ ។

សុជាៈ ហើយសិក្សាពីរឿងរបបខ្មែរក្រហម មកចុះស្រាវជ្រាវក្នុងភូមិក្នុងឃុំនេះដើម្បីចង់ដឹងពីការពិតរបស់ប្រជាជនយើង ដែលធ្លាប់បានចូលធ្វើបដិវត្តតាំងពីមុនឆ្នាំ៧៥ ជាពិសេសតាមរយៈដូចជាខ្លួនគាត់ផ្ទាល់ បើសិនជាគាត់នៅរស់ រឺ ក៏តាមឪពុកម្តាយសាច់ញាតិរបស់គាត់ ។

ស៊ុយៈ បាទ ។

សុជាៈ បាទ ខ្ញុំមកនេះ ដោយសារមានករណីមួយដែរ ដែលត្រូវជាបងស្រីពូឈ្មោះ ព្រឹម ផ្លូន ។

ស៊ុយៈ បាទៗ ។

សុជាៈ ហើយក៏ខ្ញុំបានសួរនាំប្រធានភូមិទៅ គាត់ក៏បានស្ងាប់ ហើយនៅក្នុងប្រវត្តិរូបក៏បានគេដាក់ថា គាត់ត្រូវបានគេចាប់ខ្លួន ទាំងប្តីទាំងអីគាត់ហ្នឹងទៅទៀត អញ្ចឹងដោយសារតែខ្ញុំមកសម្ភាសពូនេះ គឺខ្ញុំចង់ដឹងពីរឿងរ៉ាវខ្លះ ហើយជាពិសេសពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពូតែម្តងដូចរឿងដែលពូបាននិយាយប្រាប់ខ្ញុំអំបាញ់មិញអ៊ា ពូឈ្មោះអីដែរពូ?

ស៊ុយៈ បាទ ខ្ញុំឈ្មោះ រស់ ស៊ុយ ។

សុជាៈ រស់ ស៊ុយ រាល់ថ្ងៃអាយុប៉ុន្មានដែរ?

ស៊ុយៈ អាយុ៤៩ឆ្នាំ ។

សុជាៈ គ្រួសារពូឈ្មោះអីដែរពូ?

ស៊ុយៈ ឈ្មោះសុខ វ៉េត ។

សុជាៈ សុខ រ៉េត ។

ស៊ុយៈ បាទ ។

សុជាៈ គាត់អាយុប៉ុន្មានដែរ?

ស៊ុយៈ អាយុ៤៦ឆ្នាំ ។

សុជាៈ នៅក្នុងភូមិនេះគេហៅភូមិអីគេដែរពូ?

ស៊ុយៈ ភូមិពាមប្រជុំ ។

សុជាៈ ចុះឃុំ?

ស៊ុយៈ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ។

សុជាៈ ពូមកនៅក្នុងភូមិនេះតាំងពីឆ្នាំណាដែរ?

ស៊ុយៈ ខ្ញុំ ស្រុកកំណើតខ្ញុំកើតនៅភូមិពាមប្រជុំ ឃុំព្រែកអំបិលនេះ តែក្រោយពីឆ្នាំ៧១ ខ្ញុំបានទៅធ្វើកងទ័ពជាមួយនឹងវៀតណាម ក្រោយពីវៀតណាមធ្វើបាបខ្លាំងពេក ខ្ញុំក៏រត់ចេញពីវៀតណាមទៅរកខាងទ័ពអង្គការខ្មែរយើង ដល់តែពេលទៅខាងកងទ័ពខ្មែរយើង ក៏ខ្ញុំបានទៅវាយក្នុងសមរភូមិជាមួយគេ ក្រោយមកទៀតក៏គេអោយខ្ញុំទទួលភារៈខាងសេដ្ឋកិច្ចសំរាប់ភូមិភាគ ។

សុជាៈ ភូមិភាគអីគេ?

ស៊ុយៈ ភូមិភាគពិសេស តែក្នុងនាមមិនមែនជាមេទេ គ្រាន់តែថាជាកូនទាហ៊ាន ។

សុជាៈ បាទ ហើយចុះហេតុអី បានជាពូទៅចូលរួមជាមួយកងទ័ពវៀតណាមពូ?

ស៊ុយៈ កាលហ្នឹងវាឃើញដោយសារសម្តេចលោកមានបន្ទូលថា កូនចៅត្រូវតែក្រោកឡើងដើម្បីតស៊ូរំដោះជាតិក្រោយពីរដ្ឋប្រហារលុន ណុល ។

សុជាៈ បាទ ។

ស៊ុយៈ ដូច្នេះមិនមែនថាតែខ្ញុំទេ ក្នុងនាមក្មេងជាយុវជនទាំងអស់ គឺត្រូវទៅស្ម័គ្រគ្រប់គ្នាតែម្តង ។

សុជាៈ ហើយចុះហេតុអីបានជាចូលទៅជាមួយនឹងកងទ័ពវៀតណាម?

ស៊ុយៈ ចុះគេថា គេថារួមគ្នាដើម្បីរំដោះពី ពួកលុន ណុលដែលធ្វើរដ្ឋប្រហារហ្នឹង ។

សុជាៈ ហើយចុះកាលហ្នឹងវៀតណាមខាងណាដែរ?

ស៊ុយៈ វៀតណាម គេហៅយៀតកុង១ហ្នឹង គេថា គេមកជួយរំដោះខ្មែរយើង ។

សុជាៈ ខ្មែរយើង បាទ ។

ស៊ុយៈ ដល់តែក្រោយមក ដល់តែឃើញការរំដោះហ្នឹងវាធ្វើបាបខ្មែរយើង កងទ័ពខ្មែរយើងខ្លាំង
ពេកទៅ ។

សុជាៈ ពួកយៀកកុងហ្នឹង?

ស៊ុយៈ បាទ ដល់អញ្ចឹងខបមាថាយើងវាយមួយក្រុម ខ្មែរមួយក្រុម យួនមួយក្រុមអញ្ចឹង ។

សុជាៈ បាទ ។

ស៊ុយៈ កាលណាមកដល់ត្រឹមវា វាដកចោលយើងបាត់ យើងនៅបាញ់តទឹងគេទៅ ដល់តែវា
វាដកថយបាត់ យើងអត់អ្នកណាជួយដល់តែអញ្ចឹង មើលតែលែងទុកចិត្តយួន ត្រូវតែ
ដកខ្លួនចេញ ។

សុជាៈ បាទ ហើយពូ ឪពុកពូឈ្មោះអីដែរ?

ស៊ុយៈ គាត់ឈ្មោះរស់ ព្រាម ។

សុជាៈ រស់ ព្រាម?

ស៊ុយៈ បាទ ។

សុជាៈ ហើយចុះម្ដាយ?

ស៊ុយៈ ហឹម ។

សុជាៈ ហឹម អីគេ?

ស៊ុយៈ ហឹម ផ្លុក ។

សុជាៈ ហឹម ផ្លុក?

ស៊ុយៈ បាទ ។

សុជាៈ គាត់ទាំងពីរនៅរស់ទេ?

ស៊ុយៈ នៅរស់ទាំងពីរ ។

សុជាៈ នៅក្នុងភូមិហ្នឹងរឺក៏?

ស៊ុយៈ បាទ នៅក្នុងភូមិហ្នឹង ។

សុជាៈ ហើយចុះពូមានស្រុកកំណើតកើតជានៅឯណា?

ស៊ុយៈ ខ្ញុំ ស្រុកកំណើតកើតជានៅភូមិពាមប្រជុំហ្នឹងតែម្ដង ។

សុជាៈ ឃុំ កាលហ្នឹងឃុំអី?

ស៊ុយៈ ឃុំព្រែកអំបិល ។

សុជាៈ អើ ខ្ញុំសួរ ពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ស៊ុយៈ ខ្ញុំបងប្អូនសព្វថ្ងៃនេះ គឺបាត់ខ្លួនពីរនាក់ ហ្នឹងគឺបងប្អូនបង្កើត ។

សុជាៈ បាទ ពីណាខ្លះទៅពូ?

ស៊ុយៈ ឈ្មោះ ព្រាម ពៅហ្នឹងមួយអើ ព្រាម នួន ហ្នឹងមួយ ហើយនិងព្រាម ពៅនោះមួយទៀត ហ្នឹងប្អូន ។

សុជាៈ អញ្ចឹងគិតទាំងអស់ ទាំងអស់គ្នាទាំងអស់អី ប៉ុន្មាន?

ស៊ុយៈ នៅរស់ ពីរនាក់ បួននាក់ ៦នាក់ សព្វថ្ងៃនៅរស់ ៦ នាក់ ។

សុជាៈ អញ្ចឹង ៨ នាក់ ទាំងស្លាប់ ទាំងបាត់ខ្លួន ៨នាក់?

ស៊ុយៈ បាទៗ ។

សុជាៈ ហើយគាត់ទាំងពីរនាក់បាត់ខ្លួនដោយសារអី ស្លាប់ដោយសារអី?

ស៊ុយៈ ទៅធ្វើកងទ័ពទាំងអស់គ្នា ។

សុជាៈ បាទ អើ ខ្ញុំសួរបន្តិច ពូកើតនៅឆ្នាំណាដែរពូ មានចាំទេ ហើយចុះឆ្នាំយើងខ្មែរ?

ស៊ុយៈ បាទ ។

សុជាៈ ឆ្នាំខ្មែរឆ្នាំអី?

ស៊ុយៈ ឆ្នាំខ្មែរ ឆ្នាំមមែ ។

សុជាៈ ឆ្នាំមមែ?

ស៊ុយៈ បាទ ។

សុជាៈ ហើយកាលពូចូលទៅក្នុងធ្វើបដិវត្តហ្នឹង ពូអាយុប៉ុន្មានដែរ?

ស៊ុយៈ អេ អត់ចាំទេ គ្រាន់តែដឹងថាឆ្នាំ៧១ ។

សុជាៈ ឆ្នាំ៧១?

ស៊ុយៈ បាទ ។

សុជាៈ កាលហ្នឹងពូជាយុវជន រឺ ក៏ជាកុមារ?

ស៊ុយៈ ជា ចង់ចូលវ័យយុវជនហើយ ។

សុជា៖ ៧១ ពូមានចាំថ្ងៃខែទេ?

ស៊ុយ៖ អត់បានចាំទេ មិនបានយកចិត្តទុកដាក់ ។

សុជា៖ បាទ កាលហ្នឹងមុននឹងពូទៅ ពូមានបានទៅរៀនទៅអីណាដែរ?

ស៊ុយ៖ អត់ អត់បានរៀន ។

សុជា៖ អត់បានរៀន?

ស៊ុយ៖ ចូលរណបគេ ទៅក្រាបខ្លួនជាមួយនឹងកងទ័ពគេ ។

សុជា៖ ហើយកាលហ្នឹងមូលហេតុសំខាន់ដែលនាំអោយពូចូលបដិវត្តិហ្នឹងដោយសារអីគេទៅ?

ស៊ុយ៖ ដោយសារមួយឃើញថា រដ្ឋប្រហារលន់ ណល់ អញ្ចឹងដល់សម្តេចប្រកាសអោយកូនចៅ ឡើងក្រោក ចូលព្រៃ មាគី មាគៀ ដើម្បីតស៊ូហ្នឹង យើងចូលទៅ ភ្ញាក់រលឹកទាំងអស់គ្នាទៅតែម្តង ។

សុជា៖ ហើយដល់ឪពុកម្តាយពូយ៉ាងម៉េចដែរ?

ស៊ុយ៖ ពេលហ្នឹង គាត់ហួសចិត្តគាត់ដែរ ដោយឃើញថា គេគ្រប់គ្នា ក៏ទៅ ដល់តែខ្ញុំសុំគាត់ទៅ គាត់អត់និយាយថាម៉េច បាទ ព្រោះយុវជនក្នុងភូមិហ្នឹង ប៉ុនតែខ្ញុំវានៅក្នុងចង្កោមយុវជនដែលត្រូវដើរទៅមុនគេ ។

សុជា៖ បាទ ។

ស៊ុយ៖ ដូចមានគេទៅម្នាក់ពីរនាក់មុនអញ្ចឹង បន្ទាប់មកខ្ញុំក៏ចេញដែរទៅ ដល់តែក្រោយពីខ្ញុំមកទៀតបានជាគេចេញ ច្រើនៗរហូត ទល់តែទៅទាំងអស់ពីទាំងភូមិបណ្តោយ ។

សុជា៖ កាលពីជំនាន់ពូទៅ ទៅគ្នាប៉ុន្មាននាក់ដែរមានចាំទេ?

ស៊ុយ៖ ខ្ញុំកាលពីខ្ញុំទៅនោះ កាលពីខ្ញុំចូលទៅវៀតណាម តែឯងទេ ដល់តែវៀតណាមធ្វើបាបខ្លាំងពេកក៏ខ្ញុំក៏បកមកផ្ទះវិញ ហើយបកមកផ្ទះវិញ គេទៅរកអង្គការខ្មែរ ខ្ញុំបានទៅ ប្រាំនាក់ ។

សុជា៖ ហើយឈ្មោះអីខ្លះដែរ ដែលទៅជាមួយពូហ្នឹង?

ស៊ុយ៖ ទៅ ជាមួយខ្ញុំហ្នឹង ឈ្មោះទិត្យ ដាតហ្នឹងមួយ ហើយនិង សូត្រ ង៉ែត ហ្នឹងមួយ ហើយនិង គុយ មានណោះមួយ ហើយនិង ឆែម សយ ហ្នឹង មួយ ហើយនិង ម៉ម សារួន ណោះមួយ ។

សុជាៈ ហើយពួកគាត់ចាស់ជាងពូរឺ ក៏អាយុដំណាលៗពូដែរ?

ស៊ុយៈ ស្រករៗគ្នា ។

សុជាៈ ហើយចុះបងរបស់ពូទៅមុនរឺក៏ទៅក្រោយ?

ស៊ុយៈ ទៅក្រោយ ។

សុជាៈ ទៅក្រោយ អើ ពូថានិយាយដំបូង ពូទៅចូលជាមួយនឹងកងទ័ពវៀតណាមមុន?

ស៊ុយៈ បាទ ។

សុជាៈ ហ្នឹងនៅកន្លែងណា កងទ័ពវៀតណាម?

ស៊ុយៈ កងទ័ពវៀតណាមកាលហ្នឹងវាចូលមកដល់ភូមិគ្រប់ គ្រប់ភូមិទាំងស្រុកអស់ហើយ ហើយកាលហ្នឹងអន្តកាខ្មែរ កងទ័ពខ្មែរ អត់ទាន់មកដល់ស្រុកភូមិនេះទេ ។

សុជាៈ បាទ ។

ស៊ុយៈ គេរៀបចំនៅខាងតំបន់ភ្នំខាងលិច លិចណោះណា ។

សុជាៈ បាទ ។

ស៊ុយៈ ក្រោយពីខ្ញុំទៅវាយជាមួយនឹងវៀតណាមនៅតាមដួរដងទន្លេបាសាក់នេះ ដល់តែគេធ្វើបាបខ្លាំងពេក ក៏ខ្ញុំសំរេចរត់ចោលវៀតណាមមក ហើយក៏កាប់ដើមចេកធ្វើជាក្បូនហែលឆ្លងមកដល់ស្រុកផ្សេងណោះ ហើយបានទំលាក់អាវុធ ទំលាក់អីចោលទៅ ហើយបានដឹងស៊ើបដំណឹងបានថា កងទ័ពខ្មែរគេមកកាលយើង ខាងខេត្តតាកែវ ខាងអីវិញ ។

សុជាៈ អើ អញ្ចឹងពូនិយាយអំបាញ់មិញបានន័យថា កងទ័ពវៀតណាមចូលមកក្នុងភូមិយើងនេះមុន មុនអើ កងទ័ពខាងខ្មែរយើងចូលមក?

ស៊ុយៈ បាទៗ ។

សុជាៈ កាលហ្នឹងវៀតណាមចូលមកក្នុងភូមិយើងនៅក្នុងឆ្នាំណាដែរ?

ស៊ុយៈ តាំងពី អីខ្ញុំមិនបានចាំច្បាស់ទេ ប៉ុន្តែគ្រាន់ដឹងថា ពីឆ្នាំ៧១ហ្នឹង គឺវៀតណាមវាមកដល់ហ្នឹងហើយ ។

សុជាៈ កាលហ្នឹងមូលហេតុអីបានជាវៀតណាមមកដល់ហ្នឹង?

ស៊ុយៈ ទេ ខ្ញុំអត់ដឹងទេ ខ្ញុំក្តាប់អត់បានទេ មិនដឹងម៉េចគេមក តែគេថាគេមកជួយរំដោះខ្មែរ ។

សុជាៈ អូ ហើយចុះមកដល់ហ្នឹង មកដល់ចូលដល់ក្នុងភូមិ ក្នុងឃុំហ្នឹង ហើយចុះ ប្រធានឃុំ

ប្រធានភូមិ ខ្មែរយើងធ្វើយ៉ាងម៉េចទៅ?

ស៊ុយៈ ប្រធានភូមិ ប្រធានឃុំខ្មែរយើងក៏គាត់អត់ដឹងដែរ ថាគេមកជួយរំដោះដែរ ហើយវាមានខ្មែរយើងចូលធ្វើទ័ពជាមួយវៀតណាម ទាំងគេទាំងខ្ញុំ ចេះតែចូលៗទៅណា ។

សុជាៈ ហើយចុះពួកាលហ្នឹងថាទៅវាយជាមួយនឹងកងទ័ពវៀតណាម វាយជាមួយនឹងកងទ័ពវៀតណាមទៅវាយនៅកន្លែងណា?

ស៊ុយៈ នៅអេខាងដងទន្លេបាសាក់ណោះ បានវៀតណាមឡើងមក ពួកអាហ្នឹងវៀតណាមវាមានពីរផ្នែក ។

សុជាៈ បាទ ។

ស៊ុយៈ អាមួយគេហៅអាហ្វូងភាគី ហើយអាមួយអាហ្វូងយៀតកុងដែលជួយរំដោះខ្មែរ ពួកអាភាគី វាពួកអាខ្មែរវយៈជាមួយហ្នឹងអាពួកលុន ណុល ។

សុជាៈ លុន ណុល ។

ស៊ុយៈ បាទ ហើយខ្ញុំចូលជាមួយអាយៀត កុងហ្នឹង វាយអាភាគីហ្នឹង ។

សុជាៈ វាយនៅម្តុំណា?

ស៊ុយៈ វាយនៅទល់ដែន ឡើងមកដល់វត្តសំប៉ាហ្នឹង វាឡើងត្រឹមមកដល់វត្តសំប៉ាហ្នឹង ពួកកងទ័ពហ្នឹងគេចេះតែបន្តគេហៅអីអញ្ចឹង ។

សុជាៈ បាទ ។

ស៊ុយៈ កាលណាកប៉ាល់វៀតណាមដូចថាអាភាគីឡើងមកអញ្ចឹង គេដកចោលខ្ញុំ ។

សុជាៈ អូ ។

ស៊ុយៈ ដកចោលមករៀបទ័ពឯណោះ ខ្ញុំអត់ដឹង ដល់តែដឹង ចេះតែវាយៗទៅ ដល់តែងាកមើលបាត់អស់រលីង ដល់បាត់អស់ ខ្ញុំដកខ្លួនថយ បោះកាំភ្លើងចោល រត់ កាត់ដើមចេកហែលឆ្លងបឹងមកបុស្សរីមក រត់មកផ្ទះមក ។

សុជាៈ កាលហ្នឹងទើបតែវាយបានមួយសមរភូមិហ្នឹងទេ?

ស៊ុយៈ អឺ វាយ វា វាយបានមួយសមរភូមិហ្នឹង ក៏ប៉ុនតែគ្រាន់ថាសមរភូមិតូចៗគ្រាន់តែយើងទៅឈ្លប ទៅវាយអីតូចតាចអីហ្នឹង ខ្ញុំអត់ទាន់ចូលទេ ព្រោះអាហ្នឹងបានធំ បានវាយម្តង ។

សុជាៈ ហើយវៀតណាម កាលហ្នឹងទ័ពវៀតណាមហ្នឹងកាន់កាំភ្លើងរហូត?

ស៊ុយៈ បាទ ។

សុជាៈ ហើយចុះខាងខ្មែរយើង ខាងពូវិញ ពីណាវិញដែលគ្រប់គ្រងប្រធានពូ?

ស៊ុយៈ គ្រប់គ្រង ដូចភ្លេចបាត់ហើយ ។

សុជាៈ ឈ្មោះអីអត់ចាំទេ?

ស៊ុយៈ ចាំខ្លះដែរ តែដូចស្លាប់នៅក្នុងសមរភូមិអស់ខ្លះហើយណា ។

សុជាៈ បាទ ។

ស៊ុយៈ ដូចឈ្មោះធីឈ្មោះហ្នឹង ស្លាប់អស់ហើយ ព្រោះខ្ញុំឃើញស្លាប់ផ្ទាល់ៗនៅសមរភូមិ ។

សុជាៈ ???

ស៊ុយៈ បាទ ។

សុជាៈ ហើយចុះពេលដែលពូចូល គាត់ចេញមកដល់អន្លង់សេក ពូនៅទៅចូល?

ស៊ុយៈ អត់ទេ អាហ្នឹងខ្ញុំបកមកផ្ទះ ។

សុជាៈ មកផ្ទះសិន?

ស៊ុយៈ បាទ ក្រោយៗពីវៀតណាមឡើងមកដល់អញ្ចឹងមក ប្រជាជននៅក្នុងភូមិហ្នឹង រត់អស់
រលីងទៅ រត់អស់ទៅនៅដល់រហូត ដល់ភូមិក្រាំងយ៉ូវ ទៅហួសរហូតទៅខាងស្រុកព្រែក
ស្តៅ ព្រែកអីឯណោះណា ។

សុជាៈ បាទ ។

ស៊ុយៈ ដល់តែក្រោយមកទៀតដល់តែពេលថា ចុះរួចអស់ទៅបានមកវិញ ដល់តែមកវិញ
ក្រោយមកទៀតខ្ញុំនៅ ខ្ញុំព្យាយាមតែងតែ ដល់តែឃើញវៀតណាមវាធ្វើបាបពួកខ្ញុំខ្លាំង
ពេក ហើយកាលហ្នឹងឪពុកខ្ញុំគាត់ធ្វើប្រធានភូមិផង ដល់តែអញ្ចឹងទៅខ្ញុំនាំគ្នាបង្កូចពួក
យុវជនហ្នឹង ដេញពួកវៀតណាម ។

សុជាៈ អូ ។

ស៊ុយៈ ដល់អញ្ចឹងទៅរករឿងធ្វើអីវាអត់កើត លួចកាំភ្លើងវៀតណាម យកទៅអោយ ពេលនោះ
កងទ័ពខាងខ្មែរ ។ អើរំដោះហ្នឹង គេមកដល់ហ្នឹងដែរហើយ ខ្ញុំលួចកាំភ្លើងខាងកងទ័ពវៀត
ណាម យកអោយកងទ័ពខ្មែរ ក្រោយពីគេចចារគ្នាត្រូវវិញទៅ អោយកាំភ្លើងហ្នឹងមក
វិញទៅ ក៏គេរករឿងពួកខ្ញុំ ខ្ញុំក៏រត់ទៅបណ្តោយ ។

សុជាៈ ចុះពូអើ ពេលដែលពួកវៀតណាមវាយជាមួយហ្នឹង នៅនេះហ្នឹង នៅឆ្នាំណាពូ មានចាំទេ?

ស៊ុយៈ ឆ្នាំ៧១ ។

សុជាៈ ៧១ហ្នឹងហ្មង ។

ស៊ុយៈ បាទ ។

សុជាៈ ហើយចុះដល់ពេលខ្មែររំដោះចូលមកនេះ ហើយពូលួចកាំភ្លើងលួចអីអោយគេហ្នឹង អាហ្នឹងនៅក្នុងឆ្នាំណាដែរ?

ស៊ុយៈ ឆ្នាំ៧២ ។

សុជាៈ ឆ្នាំ៧២ដែរ?

ស៊ុយៈ បាទ ។

សុជាៈ ហើយចាប់ពីពេលពូរត់ចូលទៅស្រុក ខ្មែរយើងហ្នឹងនៅណា ហើយនៅឆ្នាំណាដែរ?

ស៊ុយៈ នៅឆ្នាំ៧៣អាហ្នឹងដើមឆ្នាំ ។

សុជាៈ ឆ្នាំ៧៣ ហើយនៅភូមិណា?

ស៊ុយៈ អត់ អាហ្នឹងនៅភូមិអី ព្រោះខ្ញុំទាក់ទងគេមុនអោយហើយ ទាក់ទងគេអោយហើយ ដល់តែពេលនោះខ្ញុំទៅជាមួយគេបណ្តោយ ។

សុជាៈ តែអត់ដឹងពីចូលដំបូងនៅម្តុំណាអីកន្លែងណា?

ស៊ុយៈ អាហ្នឹងវាដំណើរគេមកនៅស្នាក់នៅភូមិហ្នឹង ។

សុជាៈ បាទ ភូមិពាមប្រជុំហ្នឹង?

ស៊ុយៈ បាទ ពាមប្រជុំ ។

សុជាៈ ហើយចុះដល់ពេលចេញពីភូមិហ្នឹងទៅ ពូទៅនៅឯណាទៀត?

ស៊ុយៈ អាហ្នឹងគេដើរផ្លាស់ គេតែងតែផ្លាស់ទីតាំងក្រោយពីគេផ្លាស់ទៅនៅឆ្នង ។ ក្រោយពីគេផ្លាស់ទៅនៅខាងខេត្តតាកែវអីអញ្ចឹងអាក្នុយ វាមិនទៀងទេ គេហៅកងទ័ព ។

សុជាៈ អាហ្នឹងនៅក្នុងអង្គភាពអីគេពូ?

ស៊ុយៈ នៅក្នុងអង្គភាពហ្នឹងកាលហ្នឹងវាគេអោយឈ្មោះថា គេអត់ទាន់រៀបជាកងពល៧០៣ រឺក៏៥០២អីទេ វានៅក្នុង គេហៅថា វរៈសេនាធំ វរៈ១១២អញ្ចឹងអាណា ។

សុជា៖ ១១២?

ស៊ុយ៖ បាទ ដល់តែក្រោយមកទៀត ដល់គេរៀបចំកំលាំងមួយផ្នែកអោយទៅជាខាងកំលាំង សេដ្ឋកិច្ច ។

សុជា៖ អាហ្នឹងនៅក្នុងឆ្នាំ៧៣?

ស៊ុយ៖ បាទ ។

សុជា៖ ហើយចុះពូនៅក្នុងកងវរៈ១២នេះ អ្នកណាគេប្រធានទៅ?

ស៊ុយ៖ ហ្នឹង តាណាត ។

សុជា៖ តាណាត?

ស៊ុយ៖ បាទ ។

សុជា៖ គ្នាប៉ុន្មាននាក់គេហៅ គិតមើលទៅ?

ស៊ុយ៖ អឺ ខ្ញុំទើបតែទៅដល់ភ្លាមអញ្ចឹង ខ្ញុំអត់ភ្ជាប់ពីណាគេបានទេ ។

សុជា៖ បាទ ។

ស៊ុយ៖ ប៉ុនតែគ្រាន់តែខ្ញុំដឹងថា ក្រោយពីខ្ញុំចេញពីវៀតណាមទៅ ខ្ញុំក៏ចូលទៅក្នុងអគ្គការខ្មែរយើង ហ្នឹង ក៏ គេរៀបចំខាងខ្ញុំហ្នឹងអោយមកទទួលខាងសេដ្ឋកិច្ច ផ្តល់ស្បៀងទៅសមរភូមិ ។

សុជា៖ ចុះក្រោយពីពូណាតកង១២ មានពីណាទៀតដែលជាថ្នាក់ដឹកនាំកង១២ហ្នឹង?

ស៊ុយ៖ វាមានថ្នាក់បន្តៗគ្នា មានតាំងពីថ្នាក់ភូមិភាគ មានតាំងពីថ្នាក់បន្តៗ មួយកងពលអីអញ្ចឹង មកណា ។

សុជា៖ ពូមានស្គាល់ឈ្មោះទេ?

ស៊ុយ៖ ស្គាល់ ខ្ញុំស្គាល់ ដូចពូឌាញហ្នឹង គាត់ជាជំនួញការភូមិយុទ្ធសាស្ត្រ មានតាវណ្ណរិទ្ធ សព្វថ្ងៃ គាត់នៅដែរ គាត់នៅអេខាងបូកឯណោះ ប៉ុនគ្រាន់តែថាកាលពីប្រវត្តិ ប្រវត្តិសាស្ត្រ ។

សុជា៖ បាទ ។

ស៊ុយ៖ ហើយដល់ពេលនោះគាត់វា ភូមិភាគពិសេសនោះគេចែកជាពីរ ម្ខាងនៅខាងជើង ម្ខាង នៅខាងត្បូង ព្រោះភូមិភាគពិសេសហ្នឹង គឺបានន័យថាសំរាប់ពួកភ្នំពេញហ្នឹងតែម្តង

សុជា៖ ចាំមើលពូខ្ញុំសុំសួរបន្តិច អើ អញ្ចឹងពេលហ្នឹងតាណាតហ្នឹងមិនមែននៅចំណុះភូមិភាគនិរតី

រឺ បូព៌អីទេ?

ស៊ុយៈ អត់ទេ នៅភូមិភាគពិសេស ។

សុជាៈ ពិសេសហ្នឹង បើនិយាយទៅ ទិសដៅវាយចូលទីក្រុងភ្នំពេញចូលតាមច្រកណាលោកពូ កងពលពិសេសហ្នឹង?

ស៊ុយៈ យើងចូលពីខាងហ្នឹងទៅ ស្អាង ខេត្តកណ្តាល ។

សុជាៈ ខាងពី?

ស៊ុយៈ មួយខាងពី ខាងពីផ្លូវជាតិលេខមួយមក ។

សុជាៈ បាទ ។

ស៊ុយៈ រួមសហការជាមួយនឹងកងទ័ព ។ ហើយនិងយើងចូលទៅខាងណោះ អមគេថា ដូចយើងនេះអញ្ចឹងភូមិភាគនិរតីហ្នឹង ដល់ពេលហើយចេះតែចូលណា ប៉ុនដោយឡែកគឺភូមិភាគពិសេសហ្នឹង គឺមុខសញ្ញាភ្នំពេញហ្នឹងតែម្តង ។

សុជាៈ អ៊ឺ កាលហ្នឹងកងពល១២ហ្នឹង ជាកងពលរឺក៏ជាថ្នាក់?

ស៊ុយៈ ក្រោយមកទៀតឡើងមកជាកងពល ។

សុជាៈ កងពល១២?

ស៊ុយៈ បាទ ឡើង កងពល១២ កងពល១២កាលនៅភូមិភាគខាងត្បូងនេះ គឺគេមានកងពល១២ ហើយនិងកងពល១១ ។

សុជាៈ ហ្នឹងគេហៅថា ភូមិភាគពិសេស?

ស៊ុយៈ បាទ ភូមិភាគពិសេស ។

សុជាៈ ហើយចុះដល់ពេលពូមកទទួលខាងសេដ្ឋកិច្ច សេដ្ឋអីហ្នឹង ពូមានដែលស្គាល់ឈ្មោះប្រាក់ឈ្មោះអីទេ?

ស៊ុយៈ អត់ អត់ដែល ។

សុជាៈ ហើយពេលហ្នឹងមូលដ្ឋានដែលពូនៅ?

ស៊ុយៈ នៅស្រុកព្រៃកប្បាស ។

សុជាៈ ស្រុកព្រៃកប្បាសដែរ?

ស៊ុយៈ បាទ នៅស្រុកព្រៃកប្បាសហ្នឹង យើងប្រាប់ ដើរដោះដូរជារបស់របរ ជាអំបោះ ជា

ក្រមា ជាក្រណាត់ ដើរដូរជាមួយប្រជាពលរដ្ឋដើម្បីយកស្បៀងចិញ្ចឹមកងទ័ព ។

សុជាៈ អូ ។

ស៊ុយៈ បាទ ក្រោយពីឆ្នាំ៧៥ទៅ រហូតដល់គេវាយឈ្នះទៅ អ្នកទាំងអស់គ្នាត្រូវចូលទៅភ្នំពេញ អ្នកដែលនៅក្នុងក្រសួងមន្ទីរហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ ក្រោយមកទៀតក៏ កាលពេលហ្នឹង កាំភ្លើងគឺមានគ្រប់ដៃ ក្រោយមកទៀតក៏គេបែកខាង ពួកខ្ញុំអោយទៅខាងរដ្ឋ ។

សុជាៈ បាទ ចុះពូអើ ចុះមុនពេលដែលវាយចូលនៅក្រុងភ្នំពេញ ពូអត់មានបានឡើងសមរភូមិអីទេ?

ស៊ុយៈ អត់ អត់បានចូលទេ ព្រោះគ្រាន់តែជាកំលាំងទាំងពីរ ។

សុជាៈ បាទ ។

ស៊ុយៈ ព្រោះដោះស្រាយអាសមរភូមិផង ។ ដោះស្រាយផង ។ ដូច្នេះវាអែបៗជាប់ អោយគេរំកិលបន្តិច ខ្ញុំក៏រំកិលទៅបន្តិច គេកិលបន្តិច ខ្ញុំក៏រំកិលទៅបន្តិច តគ្នាអញ្ចឹង ។

សុជាៈ បាទ ហើយចុះពូអាចនិយាយពីដំណើរដើមទង ពេលដែលពូចូលដល់ទីក្រុងភ្នំពេញមុន និងចូលដល់ទីក្រុងភ្នំពេញ ហើយពេលដែលចូលដលទីក្រុងភ្នំពេញដំបូង តើពូបានឃើញសភាពលក្ខណៈយ៉ាងម៉េចខ្លះ?

ស៊ុយៈ ពេលដែលក្រោយចូលដល់ភ្នំពេញដំបូងហ្នឹង គេអោយខាងខ្ញុំហ្នឹងធ្វើនៅមាត់ទន្លេ ។

សុជាៈ មាត់ទន្លេកន្លែងណា?

ស៊ុយៈ បាទ! មាត់ទន្លេគេហៅថាឃ្លាំងកំពុងទឹកកក ។

សុជាៈ នៅដែ?

ស៊ុយៈ នៅ អត់ទេ នៅជាប់នឹងខាងជើងវត្តខណាឡោម ។

សុជាៈ អូ ។

ស៊ុយៈ អាឃ្លាំងយើង ។

សុជាៈ ផ្សារចាស់?

ស៊ុយៈ អត់ទេ បើនិយាយអោយចំ ចន្លុលពីលិច ដល់ខាងកើតផ្សារថ្មីចំ បានន័យថាឃ្លាំងហ្នឹងវាមានចាប់ពីត្រឹមរបងវត្តខណាឡោមទៅដើង ។

សុជាៈ អូ ។

ស៊ុយៈ ទៅទល់គ្នានឹងផ្សារចាស់ ទៅទល់គ្នានឹងវត្តភ្នំឃ្លាំងទាំងអស់ហ្នឹងគឺគេប្រគល់មកអោយខាងខ្ញុំដូច្នេះ ពួកខ្ញុំនៅខាងមាត់ទន្លេហ្នឹងរហូត ដល់ក្រោយមកទៀតបានគេអោយឡើងដល់ផ្ទះថ្មហើយពេលដែលទៅហ្នឹងអត់មាន?

សុជាៈ ពេលដែលពូទៅដំបូងប្រជាជនចេញពីក្រុងភ្នំពេញអស់ហើយ?

ស៊ុយៈ ចេញអស់ហើយៗ ។

សុជាៈ ចុះនិយាយពីរឿងទ័ពតាណាគវិញ ទ័ពហ្នឹងនៅជាកងភូមិភាគពិសេសទៀត រឺក៏ដូរទៅភូមិភាគអីទៀត?

ស៊ុយៈ កាលពីនោះខ្ញុំគ្រាន់តែបានដឹងតែប៉ុណ្ណេះថា ក្រោយតែពីគេចែកថាពួកកំលាំងនៅសំរាប់ភូមិ បើគេនិយាយអោយខ្លីទៅវិញគេថា ឈ្មោះរបស់កន្លែងសេដ្ឋកិច្ចហ្នឹង ឈ្មោះគេហៅថាមន្ទីរ៣១១ ។

សុជាៈ នៅកងពលប៉ុន្មាន?

ស៊ុយៈ ចំណុះភូមិភាគពិសេស ។

សុជាៈ ពិសេស ។

ស៊ុយៈ មិនមានសំរាប់កងពលណាមួយទេ សំរាប់ភូមិភាគពិសេស ។

សុជាៈ បាទ ។

ស៊ុយៈ ឧបមាថាត្រូវកងពលណាគេមកត្រូវបើកអង្ករបើកអីហ្នឹង ។

សុជាៈ ហើយចុះភូមិភាគពិសេសហ្នឹងគ្រប់គ្រងប៉ុន្មានកងពលដែរមានដឹងទេ?

ស៊ុយៈ ខ្ញុំគ្រាន់តែដឹងថានៅខាងណោះ វាមានបីកងពល កងពល១១ ១២ ហើយនិង១៨ ។

សុជាៈ បាទ ។

ស៊ុយៈ បាទ ។

សុជាៈ ហើយចុះក្រោយមកកងពល១១ ១២ ហើយនិង១៨ហ្នឹង ក្លាយទៅជាកងពលអីវិញទៅ?

ស៊ុយៈ ខ្ញុំគ្រាន់តែដឹងថាកងពល១១ហ្នឹងវាក្លាយទៅជាកងពល៥ អើ ៥០២ ។

សុជាៈ ៥០២?

ស៊ុយៈ ហើយកងពល១២ វាទៅជាកងពល៧០៣ ហើយកងពល១៤ហ្នឹងគេបានអោយទៅនៅខាងរតនគិរី ។

សុជាៈ នៅហ្នឹងគេអត់ដាក់កងពលអីទេ?

ស៊ុយៈ បាទ អត់ហ្នឹងអត់ដាក់ទេ ។

សុជាៈ ហើយចុះអំបាញ់មិញ កងពល៥០២ហ្នឹង?

ស៊ុយៈ បាទ កងពល១១ហ្នឹងគេអោយទៅជាកងពល៥០២ ។

សុជាៈ ក្រោយមកទៅឈរជើងនៅឯណាដល់ពេលចូលដល់ទីក្រុងភ្នំពេញ?

ស៊ុយៈ ឈរជើងនៅភ្នំពេញដែរ ។

សុជាៈ នៅម្តុំណា?

ស៊ុយៈ ខ្ញុំក្តាប់អត់បានទេ ព្រោះដល់ពេលខ្ញុំបែកដាច់ដោយឡែកមកខាងឃ្លាំងមក គឺខ្ញុំដាច់ការទាក់ទងខាងហ្នឹងទាំងអស់ ។

សុជាៈ ពូមានចាំឈ្មោះប្រធានកងពល៥០២ហ្នឹង?

ស៊ុយៈ អត់ចាំទេ ដល់តែក្រោយមកទៀតគេផ្លាស់ប្តូរអាំ សមាសភាពគេត្រូវឡើងចុះអីអញ្ចឹង ។

សុជាៈ ហើយចុះមុនដំបូងកាលនៅកងពល១១ ដប់អីហ្នឹង?

ស៊ុយៈ កងពល១១នៅប្រធាន ។

សុជាៈ ប្រធានដែរ ប្រធានកងពល?

ស៊ុយៈ ប្រធាន បាទ ហើយតាណាតហ្នឹងគាត់ប្រធានកងពល១២ ។

សុជាៈ ១២?

ស៊ុយៈ បាទ ។

សុជាៈ ហើយពីណាគេប្រធានភូមិភាគពិសេស?

ស៊ុយៈ ប្រធានភូមិភាគពិសេស វន វ៉េត ។

សុជាៈ វន វ៉េតហ្នឹង?

ស៊ុយៈ បាទ ។

សុជាៈ  វន  វើតហ្នឹងស្រុកកំណើតគាត់នៅឯណាដែរ?

ស៊ុយៈ  ????

សុជាៈ  ហើយចុះពេលក្រោយមកពូបានផ្លាស់ទៅក្នុងកន្លែងកងគេក្នុងភូមិ?

ស៊ុយៈ  នៅត្រពាំងរង្គ ។

សុជាៈ  ត្រពាំងរង្គហ្នឹង?

ស៊ុយៈ  បាទ ។

សុជាៈ  ហ្នឹងនៅក្នុងឆ្នាំណាដែរ?

ស៊ុយៈ  នៅក្នុងឆ្នាំ៧៥ ហ្នឹងគឺគេអោយទៅខាងហ្នឹងតែម្តងក្រោយពីរំដោះហើយ ។

សុជាៈ  បាទ  អាហ្នឹងនៅម្តុំវត្តខណាឡោមហ្នឹង?

ស៊ុយៈ  បាទ  ឃ្លាំងរង្គវាមានបរិវេណដីហ្នឹងវា  គិតទៅឃ្លាំងនៅគីឡូលេខ៦  ក៏ក្នុងវង្វង់ឃ្លាំងរង្គ ឃ្លាំងនៅជ្រោយចង្វារក៏នៅក្នុងវង្វង់ឃ្លាំងរង្គ  ឃ្លាំងនៅមុខវត្តភ្នំក៏ឃ្លាំងរង្គ  ឃ្លាំងនៅកំពង់ទឹកកកជាប់វត្តខណាឡោមនេះ  ក៏ឃ្លាំងរង្គ  អាហ្នឹងគេថាក្នុងវង្វង់សំរាប់ឃ្លាំងរង្គគ្រប់គ្រង វាមានបរិវេណឃ្លាំង  អីនៅក្នុងហ្នឹង ។

សុជាៈ  បាទ  អញ្ចឹងពូមានឋានៈអីដែរកាលនៅហ្នឹង?

ស៊ុយៈ  ខ្ញុំពេលនោះ  ឋានៈជាកងហា  បានន័យថាកងហាណា ។

សុជាៈ  បាទ ។

ស៊ុយៈ  តែក្រោយមកទៀតគេប្រចាប់ប្រចូលគ្នាទាំងអស់អោយទៅកាន់ឃ្លាំង  គេដកសមាសភាព មួយនាក់ៗមួយកង  មួយនាក់ៗអញ្ចឹងទៅ  ទៅកាន់ខាងឃ្លាំងបានន័យថាខាងទទួលស្បៀង ។

សុជាៈ  បាទ  អាហ្នឹងនៅក្នុងឆ្នាំ៧៥ ហ្នឹងដែរ?

ស៊ុយៈ  បាទ ។

សុជាៈ  ឃ្លាំងដែលពូនិយាយរៀបរាប់អំបាញ់មិញវាមានច្រើនកន្លែងពូ  តើពូកាន់ជាប់លាប់ជាងគេនៅកន្លែងណា?

ស៊ុយៈ  ខ្ញុំកាលក្រោយពីគេហៅថា  ពេលនោះដែលគេចាប់ពួករំដោះ  បន្តដូចលោកនិយាយអំបាញ់មិញអញ្ចឹង  គេចាប់បានខ្មែរអញ្ចឹងអាំ  ក្រោយមកទៀតមកខ្ញុំ  ក្រោយពីនៅឃ្លាំងកំពុងទឹកកក  ក្រោយមកទៀតគេដកខ្ញុំទៅឃ្លាំងគីឡូលេខ៦  ទៅទទួលប្រធានរដ្ឋសភាផ្នែកស្បៀង

បញ្ជីមួយរយទាំងអស់នៅលើខ្ញុំអញ្ចឹងទៅណា នៅខាងគីឡូលេខ៦ ។

សុជាៈ ប្រធានខាងផ្នែកស្បៀងហ្នឹងដូចថាគ្រប់គ្រងនៅបញ្ជីឃ្លាំងទាំងអស់?

ស៊ុយៈ បាទ បញ្ជីឃ្លាំង ។

សុជាៈ ឃ្លាំងរដ្ឋទាំងអស់?

ស៊ុយៈ អត់ទេ ជាផ្នែក មិនមានឃ្លាំងទាំងអស់ទេ គ្រាន់តែមួយផ្នែកអ៊ា៎ ប៉ុនតែនៅក្នុងនេះគេមានប្រធានគេចាត់ការពីលើអញ្ចឹង ខ្ញុំគ្រាន់តែទទួលផ្នែកខបមាថាស្បៀន សំរាប់កត់ត្រាហើយនិងសំរាប់ធ្វើរបាយការណ៍គឺខ្ញុំទទួលភារៈបានទាំងអស់ ។

សុជាៈ អញ្ចឹងបញ្ជីដែលពូកត់ត្រាហ្នឹងវាមានស្អីខ្លះ?

ស៊ុយៈ វាមានទាំងពីអង្ករ ទាំងពីស្រូវ ទាំងពីពោតក្ដួរ ទាំងពីអំបិល ទាំងពីស៊ីម៉ងត៍ ។

សុជាៈ កាលហ្នឹងនៅក្នុងឆ្នាំណាពូ?

ស៊ុយៈ នៅឆ្នាំ៧៧ ។

សុជាៈ ៧៧អេ?

ស៊ុយៈ បាទ ខ្ញុំទទួលភារៈនៅគីឡូលេខ៩ ឆ្នាំ៧៧ ។

សុជាៈ ខែណាពូមានចាំទេ?

ស៊ុយៈ អត់ចាំខែទេ ។

សុជាៈ ចុះពេលហ្នឹង ពីណាគេអ្នកនៅលើពូទៀតពូ?

ស៊ុយៈ វាមានអាហ្នឹងចាំខ្ញុំរៀបរាប់ប្រាប់ថា បរិវេណឃ្លាំងរដ្ឋហ្នឹងវាមានតំណាងគេបីនាក់ ។

សុជាៈ បាទ ។

ស៊ុយៈ ឈ្មោះលោករឹទ្ធនោះមួយ ។

សុជាៈ រឹទ្ធអី?

ស៊ុយៈ អត់ចាំឈ្មោះ អេត្រកូលគាត់ទេ ខ្ញុំភ្លេចហើយណា ។

សុជាៈ តួនាទីគាត់ជាស្អីគេ?

ស៊ុយៈ អាហ្នឹងគាត់ប្រធានឃ្លាំងហ្នឹងហ្មងអ៊ា៎ ហើយនិងលោកប៉េងហ្នឹងទៀត ហ្នឹងអានុ តែខ្ញុំអត់ចាំត្រកូលគាត់ដែរ តែពីរនាក់ហ្នឹងស្លាប់អស់ហើយ ។

សុជាៈ ថីបានស្លាប់ពូ?

ស៊ុយៈ ស្លាប់នឹងជំងឺទាំងពីរនាក់ ប៉ុន្តែគាត់មិនមែនស្លាប់នៅភ្នំពេញទេ គាត់ទៅស្លាប់នៅឯភ្នំពេញអស់ ។

សុជាៈ ដល់៧៩អេ?

ស៊ុយៈ បាទ ។

សុជាៈ បីនាក់អេ?

ស៊ុយៈ បីនាក់នៅម្នាក់ទៀត ឈ្មោះជួន សព្វថ្ងៃនៅរស់ ។

សុជាៈ បាទ ។

ស៊ុយៈ ប៉ុន្តែគាត់នៅប៉ៃលិន នៅរស់នៅប៉ៃលិន ។

សុជាៈ នៅក្នុងឆ្នាំណាដែរពូ?

ស៊ុយៈ បាទ?

សុជាៈ ក្នុងឆ្នាំណា ៧០ប៉ុន្មាន?

ស៊ុយៈ ដែលគាត់ស្លាប់ហ្នឹង ។

សុជាៈ ដែលគាត់ធ្វើជាតួនាទីជាអី?

ស៊ុយៈ ហ្នឹង៧៥រហូតទល់ដល់ ៧៩ចេញ ។

សុជាៈ អូ ទាំងបីនាក់ហ្នឹងអេ?

ស៊ុយៈ បាទ ។

សុជាៈ ចុះអើអគ្គភាពហ្នឹងគេហៅអគ្គភាព ឃ្លាំងរដ្ឋ ឃ្លាំងអីអញ្ចឹង វានៅក្រោមចំណុះក្រសួងអីដែរអ៊ុំ?

ស៊ុយៈ វា មិនដឹងជានៅក្នុងចំណុះណាទេ ខ្ញុំតែងតែឃើញអ្នកធំៗចេញចូលវាមិនដឹងនៅក្រោមឱវាទខាងណាទេ?

ភារិទ្ធៈ ពីណាគេ?

ស៊ុយៈ ចេញចូលច្រើន ។

សុជាៈ បាទ ។

ស៊ុយៈ វាខាងខសន្សាហកម្មក៏ចូល ខាងពាណិជ្ជកម្មក៏ចូល ហើយលោកធំៗដូចខៀវ សំផនក៏ចូល នួន ជាក៏ចូល ហើយលោកសង្ឃខាងមន្ទីរប៉ុល ពតនោះក៏ចូល ដូច្នេះខ្ញុំវា ដល់តែអ្នកធំ

មកអញ្ចឹង ខ្ញុំមិនអាចដូចថាជ្រៀតជ្រៀកការងារគេ ខ្ញុំដឹងតែគេអោយធ្វើអី ដឹងតែធ្វើហ្នឹង ។

សុជាៈ បាទ ។

ភារិទ្ធៈ ចុះអៀង សារីអី ដែលចូលទេ?

ស៊ុយៈ អៀង សារីមិនសូវចូលទេ ក៏ប៉ុន្តែជួបតែគេ ដូចថាគេហៅទៅរៀន ទៅអីអញ្ចឹង អាហ្នឹងជួបហើយ ។

សុជាៈ បង្រៀនពីអីទៅ?

ស៊ុយៈ គេហៅបង្រៀនពី គេហៅថា មុនគេនិយាយថា មួយគេរៀនពីរផ្នែក មួយខាងប្រព័ន្ធទឹកកក មួយទៀតខាងមហាជនធម្មតា មួយទៀតខាងរដ្ឋបាលអីអញ្ចឹងណា ។

សុជាៈ ហើយចុះពូមានបានចូលសម្ព័ន្ធទឹកកកហ្នឹងទេ?

ស៊ុយៈ អត់ទេ ខ្ញុំអត់ចូលទេ ។

ភារិទ្ធៈ ហើយរៀនហ្នឹងញឹកញាប់ទេ?

ស៊ុយៈ រៀនខាងរដ្ឋបាលហ្នឹងគឺរៀនញឹក អត់ទេខែ ។

សុជាៈ ចុះពូនិយាយអំបាញ់មិញរៀបរាប់ដែលនៅលើពូដូចឈ្មោះរិទ្ធ ឈ្មោះតេង ឈ្មោះអាឈួនអីអញ្ចឹង?

ស៊ុយៈ បាទ ។

សុជាៈ ហើយចុះអ្នកដែលនៅក្រោមការគ្រប់គ្រងរបស់ពូវិញមានឈ្មោះអីដែរ ដូចថាកាលហ្នឹងពូមានឋានៈជាប្រធានស្មៀនឃ្លាំងអីដែរកាលហ្នឹង?

ស៊ុយៈ បាទៗ ។

សុជាៈ ចុះអ្នកដែលធ្វើការក្រោមៗពូមានចាំឈ្មោះទេ ពូមានចាំទេ?

ស៊ុយៈ ចាំ ខ្លះក៏ស្លាប់ បានចេញពីភ្នំពេញទៅខ្លះក៏ស្លាប់ហើយខ្លះក៏នៅអញ្ចឹងដែរណា ។

សុជាៈ ឈ្មោះអីខ្លះ?

ស៊ុយៈ ប៉ុន្តែវាមិននៅជុំគ្នា ។

សុជាៈ បាទ ។

ស៊ុយៈ មានឈ្មោះឈឿន ហ្នឹងនៅខាងកំពង់ធំ ។

សុជាៈ  គាត់មានឋានៈអីឈឿនហ្នឹង?

ស៊ុយៈ  ឈឿនជាអ្នកកត់ត្រា  អត់មានឋានៈអីទេ  គ្រាន់តែជាអ្នកកត់ត្រាណា ។

សុជាៈ  ក្នុងឆ្នាំ៧៧អេ?

ស៊ុយៈ  ៧៧  ចូលដល់៧៩ចេញពីភ្នំពេញមក ។

សុជាៈ  ហើយអ្នកណាម្នាក់ទៀត?

ស៊ុយៈ  ឈ្មោះយ៉ុម  ប៉ុនតែយ៉ុមហ្នឹងស្លាប់បាត់ហើយ  នៅពេលប្រជុំអីដែរ ។

សុជាៈ  អូ  តួនាទីគាត់ជាស្អីដែរយ៉ុមហ្នឹង?

ស៊ុយៈ  ជាស្មៀនជាអ្នកកត់ត្រាធម្មតាទាំងអស់នៅក្នុងហ្នឹង  គេរៀបចំតែប្រធាន  ដូចថាប្រធានមួយអញ្ចឹងទៅទទួលផ្នែកស្មៀនអញ្ចឹងទៅ  គាត់ជាប្រជាជនអញ្ចឹងទៅ ។

សុជាៈ  អើ  ពូមានឋានៈជាប្រធានស្មៀនដូចថាមើលការខុសត្រូវឃ្លាំងហ្នឹង  មានតែឋានៈត្រឹមហ្នឹងទេ  រឺក៏មានបានឡើងឋានៈអីទៀតទេ?

ស៊ុយៈ  អត់ៗ ។

សុជាៈ  ឡើងដល់ត្រឹមតែថ្នាក់ហ្នឹងទេ  រហូតដល់៧៩តែម្តង ។

ស៊ុយៈ  បាទ ។

សុជាៈ  អត់មានដូរទៅខេត្តណាខេត្តណីទៀតទេ?

ស៊ុយៈ  អត់ទេ  អត់មានដូរទេ ។

សុជាៈ  អើ  នេះយើងនិយាយអំពីរឿងការងារដែលទាក់ទងនឹងរឿងពូ?

ស៊ុយៈ  បាទៗ ។

សុជាៈ  ខ្ញុំចង់សួរពីរឿងទូទៅខ្លះទៀត  ដូចថាចូលមកដល់ទីក្រុងភ្នំពេញអញ្ចឹង  ឃ្លាំងដែលពូយាមហ្នឹង  វាច្រើនជាឃ្លាំងអីទៅ?

ស៊ុយៈ  ឃ្លាំងតាំងពីដើមឡើយខ្ញុំនៅខាងឃ្លាំងកំពង់ទឹកកកនេះ  ខ្ញុំក៏ជាប្រធានផ្នែកមួយដែរ  ក្រោយមកទៀតដល់តែពេលដឹកផាវ៉ាន់យកទៅដាក់ហ្នឹងវាមានគ្រប់មុខ  ទាំងពីដែកមកពីចិន  ដែកគ្រប់ប្រភេទ  អោយតែដែកគ្រឿងសំណង់មកពីបរទេសហ្នឹង ។

សុជាៈ  បាទ ។

ស៊ុយៈ  ក៏នៅបរិវេណហ្នឹងដែរ  ឃ្លាំងហ្នឹងដែរ  ហើយមួយផ្នែកទៀតផាវ៉ាន់ផលិតក្នុងរោងចក្រ  ក្នុង

ភ្នំពេញទាំងមូលហ្នឹងគឺគេដឹកបញ្ចូលទៅក្នុងឃ្លាំងដែរ តែគ្រាន់តែខ្ញុំដឹងថា ដឹកចូលដូចជាឧបមាថាមួយអាទិត្យដឹកម្តងៗ គ្រប់រោងចក្រ តែក៏បើកអោយគ្រប់ភូមិភាគ បានន័យថាគ្រប់តំបន់ក្នុងស្រុកខ្មែរយើងហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ ក៏បើករាល់អាទិត្យដែរ ដល់តែពេលដូចថាបើកខាងតំបន់២៥អញ្ចឹង គេមានអាក្រដាសគេប៉ុណ្ណេះមួយទៅមានបោះត្រាអីទៅ យកទៅហុចទៅ មានកំណត់នៅក្នុងហ្នឹងស្រាប់ ខ្ញុំក៏រាប់ប្រគល់អោយគេទៅ ហើយខាងនោះមកទៀត ខ្ញុំគ្រាន់តែរាប់ប្រគល់អោយគេទៅ ប៉ុនតែបើករាល់អាទិត្យ ។

សុជាៈ បាទ ។

ស៊ុយៈ គ្រប់ភូមិភាគ ពាយ័ព្យក្តី ខាងបូព៌ាក្តី ខាងបាត់ដំបង ខាងរីក៏បស្ចឹមនិរតី គឺទូទៅទាំងអស់ ។

សុជាៈ កាលហ្នឹង ចុះក្រៅពីដែកអីហ្នឹងមានឃ្លាំងអាវុធទេ?

ស៊ុយៈ អត់មាន អត់មានឃ្លាំងអាវុធ ។

សុជាៈ ហើយចុះខោអាវអី?

ស៊ុយៈ ខោអាវក៏អត់ដែរមានតែក្រណាត់ បាទ មានតែក្រណាត់ ។

សុជាៈ ខ្ញុំសុំសួរពូបន្តិច ពួកដែលភូមិភាគ រឺ ក៏តំបន់ឡើងមកយកហ្នឹង យករាល់អាទិត្យតែម្តង រឺ ក៏ខែ?

ស៊ុយៈ យករាល់អាទិត្យ ។

សុជាៈ អាទិត្យ?

ស៊ុយៈ បាទ ។

សុជាៈ ហើយដូចយើងឥលូវ ឧបមាថាបើកអញ្ចឹងយកទៅធ្វើអីៗគេមានដាក់នៅក្នុងហ្នឹងទេ?

ស៊ុយៈ អត់ដឹងទេ ខ្ញុំមិនអាចដឹងទេ គ្រាន់តែដឹងថាខ្ញុំបានមានភារកិច្ចមួយដូចថាខាងតំបន់ ២៥ មកយកអញ្ចឹង អត់មានស្តុកនៅក្នុងឃ្លាំង ខ្ញុំជូនគេទៅបើកផ្ទាល់ពីរោងចក្រតែម្តង ។

សុជាៈ អូ ។

ស៊ុយៈ ដូចជាត្រូវបើកស្បែកជើងអញ្ចឹង ត្រូវជាថ្នាំងដាំបាយ ត្រូវជាអំបោះដេរ រឺ ក៏ត្រូវជាស្បែមុងអីអញ្ចឹងទៅ អាហ្នឹង ទៅជូនផ្ទាល់ៗដល់រោងចក្រតែម្តងប្រគល់អោយគេតាម

ហ្នឹងទៅ ។

សុជាៈ ហើយចុះពួកដែលនៅក្រសួងមន្ទីរផ្សេងៗទៀតនៅក្នុងភ្នំពេញមានទៅបើកទេ?

ស៊ុយៈ បើកដែរ ។

សុជាៈ បើកដែរ?

ស៊ុយៈ បើក បើក ដូចគ្នាទាំងអស់ ។

សុជាៈ ហើយចុះឧបមាថាឋានៈពួកនៅតាមភូមិភាគ រឺក៏តំបន់មកបើកអាហ្នឹង គេមកបើកថ្នាក់តំបន់ដែររឺក៏?

ស៊ុយៈ គេមិនមែនមកបើកផ្ទាល់កន្លែងខ្ញុំទេ គេមកដល់សុំការសំរេចពីកន្លែងទីចាត់ការរបស់ខាងប៉ុល ពតអញ្ចឹងណា ដល់ហើយទៅគេចេញអាវ៉ាស៊ុយហ្នឹង អោយជាប្រកាន់ដៃហ្នឹង មកបើកពីកន្លែងខ្ញុំមក ។

សុជាៈ អញ្ចឹងអ្នកដែលចេញជាប្រកាន់ ជាប័ណ្ណ ជាវ៉ាស៊ុយអោយមកបើកហ្នឹង ពីណាគេអ្នក?

ស៊ុយៈ ពីកន្លែងទីចាត់ការរបស់ខាងប៉ុល ពតហ្នឹងតែមក ។

សុជាៈ ប៉ុល ពតហ្នឹង?

ស៊ុយៈ បាទ ។

សុជាៈ អញ្ចឹងរាល់ដែលពូបើកទំនិញអោយគេពូតែងតែឃើញសញ្ញារបស់ប៉ុល ពតហ្នឹង?

ស៊ុយៈ បាទ បើអត់មានក្រដាសហ្នឹងមកទេ គឺយើងមិនអាចបើកអោយគេបានទេ គេថាអោយប៉ុន្មានគឺមានបញ្ជីនៅក្នុងហ្នឹង យើងឧបមាថាថារបស់ដែលយើងបើកមកពីរោងចក្រយកមកតំកល់ឃ្លាំងអញ្ចឹង ។

សុជាៈ បាទ ។

ស៊ុយៈ កាលណាយើងបើកអោយគេច្រឡំហើយបើកខុះ គឺយើងទទួលខុសត្រូវ ។

សុជាៈ អើ ។

ស៊ុយៈ រឺក៏លើសគេសួរយើងបានពីណាមក ប្រឡំបានយកពីណាមក ដូច្នេះអ្វីដែលធ្វើហ្នឹងគឺអោយត្រង់ដូចទានអញ្ចឹង មិនហ៊ានអោយខុសព្រោះដឹងច្បាស់ថា អ្វីដែលខុសគេចាប់ផ្តើមដូច្នេះអ្វីក៏មិនហ៊ានអោយខុសដែរ សុខចិត្តអត់ងងុយស្កមខ្លួនយ៉ាងម៉េច មិនហ៊ានអោយខុសទេ ។

សុជាៈ ពូនិយាយអំបាញ់មិញថាការយកទំនិញចេញទាល់តែមានសញ្ញាប៉ុល ពតតែម្តង?

ស៊ុយៈ ត្រង់ ថាបើមិនមានប៉ុល ពតទេ គ្រាន់ថាមន្ទីររបស់ប៉ុល ពតហ្នឹង គេមានប្រធានគេ
អញ្ចឹងមក គេចារថាសំរាប់អោយទៅខាងណាប៉ុន្មានៗគឺគេធ្វើសំបុត្រអោយ ។

សុជាៈ ឈ្មោះអ្នកចារហ្នឹងពូមានស្គាល់ឈ្មោះទេ?

ស៊ុយៈ ខ្ញុំអត់ចាំទេ ប៉ុនគ្រាន់តែចេញពីក២៥អញ្ចឹងមក ។

សុជាៈ ក២៥ហ្នឹងជាស្អីគេទៅ?

ស៊ុយៈ ជាប្រធានមន្ទីរចាត់ការគេ ក២៥ ។

សុជាៈ មន្ទីរចាត់ការរបស់ពីណាគេ?

ស៊ុយៈ របស់ប៉ុល ពត ។

សុជាៈ ប៉ុល ពតហ្នឹងអេ?

ស៊ុយៈ បាទ ។

សុជាៈ ហើយមានដឹងពីណាប្រធានមន្ទីរទេ?

ស៊ុយៈ តែគ្រាន់តែដឹងថាកន្លែងហ្នឹងមានលោកសង្ស ។

សុជាៈ លោកសង្ស?

ស៊ុយៈ ធ្វើជាជំនាញការរបស់ប៉ុល ពត ។

សុជាៈ អូ ។

ស៊ុយៈ បាទ គ្រាន់តែដឹងតែប៉ុនណ្ណឹង ដល់តែស៊ីញ៉ៅខ្ញុំអត់សួរដល់តែវាយូរឆ្នាំពេកទៅវាភ្លេចទៅ ។

Side B:

សុជាៈ ពូដឹងថាគាត់ហ្នឹងជាជំនាញការប៉ុល ពតហ្នឹងនៅឆ្នាំណា?

ស៊ុយៈ គាត់ជាប្រធានមន្ទីរ ។

សុជាៈ ប្រធានមន្ទីរទេ?

ស៊ុយៈ បាទ ។

សុជាៈ ប្រធានមន្ទីរក ៥ហ្នឹង?

ស៊ុយៈ ប្រធានមន្ទីរ ក ២៥ ។

សុជា៖ អាហ្នឹងទីតាំងគេនៅកន្លែងណាពូ?

ស៊ុយ៖ អត់ អត់ស្គាល់ទេ គ្រាន់តែឃើញក្រដាសគេមក ឃើញតែក២៥ ក២៥ហ្នឹង ។

សុជា៖ ហើយដឹងអញ្ចឹងនៅក្នុងឆ្នាំណាពូមានដឹងទេ?

ស៊ុយ៖ បាទ ។

សុជា៖ មានចាំ មានដឹងទេ ថាកងហ្នឹងជាប្រធានមន្ទីរ ក២៥ហ្នឹងនៅក្នុងឆ្នាំណាពូមានដឹងទេ?

ស៊ុយ៖ អត់ ខ្ញុំមិនចាប់អារម្មណ៍ថានៅក្នុងឆ្នាំណាទេ ប៉ុនគ្រាន់តែដឹងថា ចាប់ពីត្រឹមខ្ញុំមកធ្វើការនៅកន្លែងទទួលប័ណ្ណរឺស៊ុយដែលគេធ្វើមកគឺតាំងពីឆ្នាំ៧៥មករហូត ។

សុជា៖ ៧៥?

ស៊ុយ៖ ប៉ុនតែគ្រាន់ថ្ងៃខ្ញុំមិនអាចដឹងទេ ថ្ងៃខែពេលវេលា ។

សុជា៖ បាទ ហើយចុះប៉ង់ហ្នឹងមានដែលទទួលបើកឥវ៉ាន់ហ្នឹង?

ស៊ុយ៖ អត់ទេ គេតែងតែមកពិនិត្យ ។

សុជា៖ ពិនិត្យស្អី?

ស៊ុយ៖ ពេលខ្លះគេមកពិនិត្យមើល បរិវេណឃ្លាំងអីយ៉ាងម៉េចអីយ៉ាងម៉េចអីហ្នឹង មកម្តងៗ ។

សុជា៖ ប៉ង់ហ្នឹងមានឈ្មោះអីផ្សេងទៀតក្រៅពីឈ្មោះប៉ង់ហ្នឹង?

ស៊ុយ៖ អត់ដឹងទេ គ្រាន់តែដឹងថាកង់ហ្នឹងគាត់ខ្វិចជើងម្ខាង ។

សុជា៖ ខ្វិចជើង?

ស៊ុយ៖ បាទ ។

សុជា៖ គាត់ខ្វិចជើងនៅពេលណាពូ?

ស៊ុយ៖ អត់ដឹងទេ ប៉ុនតែគ្រាន់តែឃើញគាត់ដើរពាំងពៀចៗអញ្ចឹងណា ។

សុជា៖ ខ្ពស់ រឺ ក៏?

ស៊ុយ៖ មិនខ្ពស់ទេ វាបាក់ដៃមួយខាង របួស ។

សុជា៖ ហើយស រឺ ខ្មៅ?

ស៊ុយ៖ ខ្មៅ អេ សំបុរសណ្តែកបាយ ។

សុជា៖ បាទ គាត់ជាអ្នកមកពីខាងណាដែរ? ស្រុកទេសគាត់ ?

ស៊ុយៈ អត់ស្គាល់ទេ អត់ស្គាល់ទេ ។

សុជាៈ ហើយចុះពូអំបាញ់មិញថាយកទំនិញចេញ ទាល់តែមានអ្នកណាពីមន្ទីរក២៥ហ្នឹងមក ។

ស៊ុយៈ បាទ ។

សុជាៈ ហើយចុះបើសិនជាយកទំនិញចូលវិញយើងត្រូវធ្វើរបាយការណ៍ឡើងទៅ ។

ស៊ុយៈ ធ្វើឡើង ។

សុជាៈ ធ្វើឡើងទៅណា?

ស៊ុយៈ ធ្វើ ខ្ញុំធ្វើឡើងវាមានថ្នាក់របស់ខ្ញុំ ខ្ញុំធ្វើឡើងទៅប្រធានទទួលឃ្លាំងរបស់ខ្ញុំ ដូចខ្ញុំថាលោករឹទ្ធ ហើយលោកហ៊ាញអញ្ចឹងអា៎ ធ្វើរបាយការណ៍ហ្នឹងបញ្ជូនទៅ គេធ្វើបន្តបានថ្នាក់ទៅទៀតទៅ ។

សុជាៈ អូ ។

ស៊ុយៈ ហើយពេលទុកឥវ៉ាន់ រឺក៏បើកឥវ៉ាន់ចេញ ក៏ ខ្ញុំត្រូវការមួយខែ ខ្ញុំធ្វើរបាយការណ៍ បញ្ជីមួយដងដែរ ។

សុជាៈ បាទ ។

ស៊ុយៈ បានន័យថាខ្ញុំនៅទទួលឥវ៉ាន់ក្នុងឃ្លាំងអញ្ចឹង កាលណាដាច់ខែខ្ញុំធ្វើរបាយការណ៍ជូនទៅរបស់នៅសល់ប៉ុនណា បើកអស់ប៉ុន្មានអីអញ្ចឹង និន្នាការ ការងារខ្ញុំគឺមានតែប៉ុណ្ណឹង ។

សុជាៈ បាទ អើខ្ញុំសុំសួរពូបន្តិចទៀត ចុះក្រៅពីប៉ង់ហ្នឹងប្រធាននៅតាមតំបន់ភូមិភាគអី ដូចថាប្រធានគណៈតំបន់ គណៈភូមិភាគដែលគេមកបើកផ្ទាល់ខ្លួន?

ស៊ុយៈ អត់ទេ គេមានខាងសេដ្ឋកិច្ចរបស់គេ ។

សុជាៈ របស់គេ?

ស៊ុយៈ បាទ សេដ្ឋកិច្ចរបស់គេ ឧបមាថាតំបន់ ២៥ មួយគេមានទីតាំងគេនៅភ្នំពេញឯណោះមួយទៅ មកខាងភូមិភាគបូព៌ាគេមានទីតាំងរបស់គេមួយទៅ ខាងភូមិភាគឥសាន ភូមិភាគផ្សេង បើនិយាយអោយចំទៅ គេមានភូមិភាគគេនៅជុំវិញភ្នំពេញហ្នឹងតែម្តង ដល់ពេលថា បើក ទីតាំងគេនៅជិតហ្នឹង គេ ។

សុជាៈ បើកប្រើប ។ ទៅ?

ស៊ុយៈ បាទ បើក គេត្រូវបើកអីគេទៅ ក ២៥ហ្នឹងហើយ គេយកតែក្រដាសហ្នឹងមកវិញ គេ

ប្រគល់អោយខាងសេដ្ឋកិច្ចគេមកបើកផ្ទាល់ៗតែម្តង។

សុជា: កាលហ្នឹងតាមពូដឹងមានប៉ុន្មានភូមិភាគដែរ ដែលធ្លាប់មកបើកកន្លែងពូហ្នឹង?

ស៊ុយ: ធ្លាប់មកបើកបូព៌ា ភូមិភាគបូព៌ា ភូមិភាគនិរតី ភូមិភាគបច្ចិម ភូមិភាគពាយ័ព្យ ភូមិភាគឧត្តរ ហើយនិងភូមិភាគឥសាន ហើយនៅក្នុងនោះដូចថាវាមានតំបន់ស្វ័យយ័ត ដូចថាព្រះវិហារ និង ឧត្តរមានជ័យអាហ្នឹង គេមកបើក?? ព្រះវិហារនិង ឧត្តរមានជ័យគេចាត់ទុកថាតំបន់ស្វ័យយ័ត្យ។

សុជា: ស្វ័យយ័ត្យហ្នឹង?

ស៊ុយ: បាទ វា ព្រោះអាហ្នឹងបើថាអោយឈ្មោះថាភូមិភាគវាតូចជាងគេ ដូច្នេះអោយទៅ ជាតំបន់ស្វ័យយ័ត្យ។

សុជា: ស្វ័យយ័ត្យហ្នឹងបើដូចយើងឥលូវ ដូចថាទីក្រុងភ្នំពេញ អេ ប៉ៃលិនហ្នឹង តំបន់ស្វ័យយ័ត្យមួយដែរ?

ស៊ុយ: បាទ។

សុជា: ហើយការគ្រប់គ្រងនៅតំបន់ស្វ័យយ័ត្យហ្នឹង ភាគច្រើនការសំរេចអីទៅលើ អ្នកតំបន់ហ្នឹងអ្នកនៅតំបន់ហ្នឹង?

ស៊ុយ: បាទ។

សុជា: អញ្ចឹងកាលហ្នឹងវាដូចគ្នាស្វ័យយ័ត្យយើងឥលូវ?

ស៊ុយ: អឺ អាការផេរធំៗខ្ញុំអត់ក្តាប់បានទេ ប៉ុនគ្រាន់តែខ្ញុំដឹងថាខាងណាមកបើក គ្រាន់តែខ្ញុំឃើញរឺស៊ុយគេមកហ្នឹង ខ្ញុំថាអ៎ខាងព្រះវិហារ តំបន់ស្វ័យយ័ត្យអញ្ចឹងទៅ ហើយខាងឧត្តរមានជ័យអញ្ចឹងទៅ តំបន់ស្វ័យយ័ត្យ ហើយក្រៅពីហ្នឹងខាងភូមិភាគ គេដាក់ភូមិភាគភូមិភាគអញ្ចឹងហ្នង។

សុជា: ចុះអើកាលណាមានសំណើរពីខាងភូមិភាគមក មិនមានថាសំណើរហ្នឹងត្រូវចេញពីគណៈភូមិភាគអីដែរអេ?

ស៊ុយ: បាទ គេចេញមកហ្នឹងហើយ ឧបមាការទាក់ទងគ្នាអីហ្នឹង គេត្រូវចែកចាយយ៉ាងម៉េចឧទាហរណ៍ អានេះការយល់របស់ខ្ញុំទេណា ឧបមាថា ហ៎ ត្រូវចែកទៅខាងណាប៉ុន្មាន ខាងណាប៉ុន្មានអាចប្រធានមន្ទីរគេហ្នឹង គេហៅគ្រប់ភូមិភាគមកចែកទៅ ខាងណេះទៅនេះ

ខាងណោះទៅនេះទៅ ហើយបានគេចេញអាវីស៊ុយហ្នឹង ចែកតាមកន្លែងមក ហើយបាន អ្នកបន្ទាប់ៗទៀតកាន់ក្រដាសហ្នឹង រឺស៊ុយហ្នឹង យកមកបើកក្នុងឃ្លាំងតែម្តង ។

សុជាៈ ចុះពូ ពូអាចស្គាល់គណៈភូមិភាគអីខ្លះទេពូ?

ស៊ុយៈ បាទ ។

សុជាៈ គណៈភូមិភាគ អើ និរតីកាលហ្នឹងឈ្មោះអីគេ?

ស៊ុយៈ តាម៉ុក ។

សុជាៈ តាម៉ុកណា?

ស៊ុយៈ បាទ តាម៉ុកដែលគេចាប់សព្វថ្ងៃហ្នឹង ។

សុជាៈ បាទ ចុះគណៈភូមិភាគបូព៌ា?

ស៊ុយៈ បូព៌ា អើ សោ ភឹម ។

សុជាៈ ចុះឧត្តរ?

ស៊ុយៈ ឧត្តរ ពៅ ឃួន ។

សុជាៈ ពៅ ឃួនអេ?

ស៊ុយៈ បាទ ។

សុជាៈ ហើយចុះភូមិភាគបស្ចឹម?

ស៊ុយៈ ភូមិភាគបច្ចិមអើ អត់ចាំអស់ទេ ហើយដឹងតែពាយ័ព្យអាហ្នឹងតាឈ្មោះញឹម ។

សុជាៈ ឈ្មោះញឹម ។

ស៊ុយៈ បាទ ។

សុជាៈ ពាយ័ព្យហ្នឹងខាងណាខ្លះ ខេត្តណាខ្លះដែលចូលជាភូមិភាគ?

ស៊ុយៈ ពាយ័ព្យមានតែពោធិ៍សាត់ បាត់ដំបង សៀមរាបហ្នឹង ។

សុជាៈ សៀមរាប?

ស៊ុយៈ បាទ អាហ្នឹងហើយខាងពាយ័ព្យ ។

សុជាៈ ហើយចុះបស្ចឹម?

ស៊ុយៈ បស្ចឹម អេ កំពង់ស្ពឺហ្នឹង ។

សុជាៈ កំពង់ស្ពឺ កំពង់?

ស៊ុយៈ កំពង់ស្ពឺ កំពង់សោមអាហ្នឹងដូចក្នុងបស្ចឹម ។

សុជាៈ បស្ចឹម មិនមែននិរតីទេ?

ស៊ុយៈ និរតីអត់ទ និរតីបែកខាងកំពត ខាងតាកែវ ។

សុជាៈ តាកែវ ខេត្តកណ្តាលយើងហ្នឹងដែរអេ?

ស៊ុយៈ ខេត្តកណ្តាលអត់ទេ ខេត្តកណ្តាលមួយចំហៀងតំបន់ ២៥ ហើយមួយចំហៀងគេហៅថាតំបន់ពិសេស ។

សុជាៈ ពិសេស?

ស៊ុយៈ ពិសេស តំបន់ពិសេសបាទ ។

ភារីទ្ធៈ ហើយចុះពូមានដឹងថាអ្នកដឹកនាំភូមិភាគបស្ចឹមអ្នកណា?

ស៊ុយៈ អត់ដឹង អត់ដឹងផង អត់ស្គាល់ផង ។

ភារីទ្ធៈ ហើយចុះភូមិភាគកណ្តាល?

សុជាៈ ភូមិភាគបស្ចឹម?

ស៊ុយៈ កណ្តាលភូមិភាគ អត់មាន គេហៅថា គេហៅថាអត់មានឈ្មោះភូមិភាគដែលកណ្តាលទេ មានឈ្មោះថាតែភូមិភាគពិសេសហ្នឹងតែម្តង ។

សុជាៈ អូ ពីណាគេអ្នកដឹកនាំ?

ស៊ុយៈ ភូមិភាគពិសេសហ្នឹង វ៉ន វ៉េតហ្នឹងតែម្តង ។

ភារីទ្ធៈ ហើយចុះបន្ទាប់ពីគេចាប់វ៉ន វ៉េតហ្នឹងពីណាគេទៅ?

ស៊ុយៈ អាហ្នឹងដល់តែពេលចូលភ្នំពេញហើយ អាហ្នឹងគេរៀបចំ វាលែងទៅជាភូមិភាគអស់ហើយ គេលែងរៀបចំទៅជាភូមិភាគអស់ហើយ ព្រោះអាហ្នឹងភូមិភាគ សំរាប់តែភូមិភាគពិសេសមួយទេ ក្រៅពីហ្នឹងគឺគេនៅ ភូមិភាគឧត្តរ ភូមិភាគពាយ័ព្យ ភូមិភាគអីគេនៅតែដដែលៗ តែភូមិភាគពិសេសគឺដូចជាគេមិនលឺនិយាយ ។

ភារីទ្ធៈ មានដែលស្គាល់ឈ្មោះកែ ពកទេ?

ស៊ុយៈ កែ ពកលឺ ហើយដឹងថាគាត់ហ្នឹងជាអនុប្រធានរបស់ កុយ ឃួន ។

សុជាៈ ហើយចុះពីមុនមក កុយ ឃួនហ្នឹងធ្វើនៅភូមិភាគឧត្តរ?

ស៊ុយៈ បាទ បាទ ហើយបន្ទាប់មកខ្ញុំស្គាល់គាត់រហូតតែនៅភ្នំទៀត រត់ទៅនៅភ្នំអាំ បានស្គាល់ ។

ឃើញតែមុខ ស្គាល់ច្បាស់ ។

សុជាៈ ពូស្គាល់តាម៉ុក ដែលជាប្រធានភូមិភាគនិរតីហ្នឹងនៅឆ្នាំណាដែរ?

ស៊ុយៈ អូ ស្គាល់ និយាយអោយចំទៅ តាំងពីអើយមកខ្ញុំស្គាល់រហូត ពីមុនឈ្មោះគាត់គេហៅថា តា ១៥ តា១៥ ។

សុជាៈ អឺ ។

ផេង្រៈ ចុះពីណាគេហៅ ឈិត ឈឿន?

ស៊ុយៈ ឈិត ឈឿនហៅ ម៉ុក ហ្នឹង ។

សុជាៈ អូ ។

ស៊ុយៈ ឈិត ឈឿនហ្នឹងហើយហៅតាម៉ុក ។

ផេង្រៈ បាទ ។

សុជាៈ ហើយហ្នឹងស្គាល់តាំងតែពីចូលបដិវត្តមក?

ស៊ុយៈ បាទ ។

ភារីទ្ធៈ ហើយចុះកែ ពក ពូស្គាល់តាំងពីពេលណាមកដែរ?

ស៊ុយៈ អត់ទេ ទើបតែស្គាល់អាពេលរត់ទៅនៅ អា ឧបមាថា ប្រជាជននៅហ្នឹងទៅ ហើយគាត់ក៏នៅជិតហ្នឹងហើយ ប្រជាជន ហើយបែកចេញចូលផ្ទាល់អញ្ចឹងទៅស្គាល់អញ្ចឹងណា ។

សុជាៈ ហើយពូថាស្គាល់តាម៉ុកដូចជាយ៉ាងម៉េចដែរ?

ស៊ុយៈ អេ តាម៉ុក អាហ្នឹងគ្រាន់តែអញ្ចេះ ស្គាល់តាម៉ុក មេដឹកនាំគ្រាន់តែ អាហ្នឹងគ្រាន់តែថាជាកសិករ បើត្រូវវាយៗតែម្តង ដូច អាណោះមួយអាណោះមួយគ្រាន់តែដឹងតែប៉ុណ្ណឹង ។

ភារីទ្ធៈ ដែលឃើញគេ គាត់វាយគេដែររឺក៏អត់?

ស៊ុយៈ ធ្លាប់តែឃើញអញ្ចេះ ឧបមាថាគាត់ហៅប្រពន្ធរៀនសូត្រអញ្ចឹងទៅ គាត់ដេរពាក់កណ្តាលរៀនអានយោបាយពាក់កណ្តាល ប៉ុនតែផុតពីហ្នឹង បើថានៅជិតដៃត្រូវវាយវាយអីហ្នឹង ។

សុជាៈ ធ្លាប់ឃើញដែរ?

ស៊ុយៈ បាទ ធ្លាប់ឃើញថាវាយៗដែរ ប៉ុនតែវាយហើយ អានថាវាយហើយអោយស៊ី ។

សុជាៈ បាទ ។

ស៊ុយៈ បើនិយាយអោយចំ ជាចរិកចូលចិត្ត ដល់ហើយ ខ្លាំងអាំ ដេញវាយគេអញ្ចឹង បើថាវាយ

បាន ក៏បាន បើថាវាយមិនបានហើយធម្មតាដដែល ។

សុជាៈ ហើយកាលហ្នឹងពូខស្សាហ៍ឃើញគាត់នៅម្តុំណា?

ស៊ុយៈ អាហ្នឹង ។

សុជាៈ អញ្ចឹងៗ ។

ស៊ុយៈ បើនិយាយអោយចំឃើញតែរហូត តាំងពីមុនបែកភ្នំពេញក៏ធ្លាប់ឃើញ ហើយអាដល់បែកភ្នំពេញហើយ ហើយដែល ពេលដែលបែក៧៩ហើយកាលនៅភ្នំហ្នឹង ក៏ធ្លាប់ឃើញចរិកគាត់អញ្ចឹង ។

សុជាៈ តើនៅក្នុងឆ្នាំ៧៥ ដល់ ៧៩ ដោយសារឃើញគាត់ធ្វើចរិកអញ្ចឹងៗ នៅក្នុង?

ស៊ុយៈ អត់ទេ អត់ដែលឃើញទេ ពេលចូលភ្នំពេញ អត់ដែលឃើញទេ ចរិកហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ តែមុនចូលភ្នំពេញ ហើយនិងអាក្រោយ ៧៩ទៅ ហ្នឹងឃើញចរិកគាត់ ។

សុជាៈ បាទ ។

ស៊ុយៈ គេហៅថាអាចរិកហ្នឹង វាថាខឹងដេញវាយអញ្ចឹង ហើយដល់ជួបមុខក្រោយអញ្ចឹងធម្មតាវិញ ។

សុជាៈ បាទ ។

ស៊ុយៈ មិនមែនថាខឹងហើយ ជួបមុខក្រោយវិញ បាញ់ចោលមិនមានទេ ។

សុជាៈ បាទ ។

ស៊ុយៈ គ្រាន់តែដេញវាយអញ្ចឹងទៅ បើរត់រួច រួចទៅ បើរត់មិនរួចត្រូវដំបងអញ្ចឹងទៅ ប៉ុន្តែថាបើស្អែកឡើងជួបមុខទៀតធម្មតាវិញ ។

សុជាៈ ហើយចុះពូខ្ញុំចង់សួរមួយទៀត អំបាញ់មិញខ្ញុំសួរដល់ថ្នាក់មេដឹកនាំថ្នាក់តាមភូមិភាគ?

ស៊ុយៈ បាទ ។

សុជាៈ ហើយឥលូវខ្ញុំសួរមេដឹកនាំដែលនៅតាមមន្ទីរក្រសួង នៅក្នុងទីក្រុងភ្នំពេញវិញ?

ស៊ុយៈ បាទ ។

សុជាៈ ពូមានស្គាល់ពីណាខ្លះទេ?

ស៊ុយៈ មន្ទីរក្រសួង ចង់សួរពីក្រសួងណា?

សុជាៈ បើថា ឥលូវដូចក្រសួងកសិកម្ម ពីណាគេប្រធាន រដ្ឋមន្ត្រី គេហៅថារដ្ឋមន្ត្រីហើយ ណោះកាលហ្នឹង?

ស៊ុយៈ រដ្ឋមន្ត្រីឈ្មោះចេង អន។

សុជាៈ ចេង អន?

ស៊ុយៈ បាទ។

សុជាៈ អាហ្នឹងក្រសួងកសិកម្ម?

ស៊ុយៈ ក្រសួងកសិកម្ម។

សុជាៈ ចេង អន កាលសម័យហ្នឹងពូស្គាល់តាមរយៈយ៉ាងម៉េច?

ស៊ុយៈ ខ្ញុំស្គាល់តាមរយៈអញ្ចេះ ព្រោះកាលពី ក្រោយពីខ្ញុំចេះតែសួរៗ តទៅ ខ្ញុំដឹងថាចេង អន ហ្នឹងគាត់នៅក្នុងគណៈកម្មាភូមិភាគពិសេស។

សុជាៈ អូ។

ស៊ុយៈ គាត់ទទួលខាងជើង ហើយវណ្ណរិទ្ធណោះ គាត់ទទួលខាងត្បូង។

សុជាៈ ឈ្មោះវណ្ណរិទ្ធ?

ស៊ុយៈ បាទ គាត់ដូនអី កែវ រិទ្ធ ដូនអីវណ្ណរិទ្ធ។

សុជាៈ ពូស្គាល់ចេង អននៅក្នុងឆ្នាំណា?

ស៊ុយៈ បាទ។

សុជាៈ ចេង អន។

ស៊ុយៈ បាទ ខ្ញុំស្គាល់ច្បាស់នៅក្នុងឆ្នាំ ៧៥ ។

សុជាៈ ៧៥ ខែក្រោយរំដោះអេ?

ស៊ុយៈ បាទ ក្រោយរំដោះហើយ។

សុជាៈ ហើយចុះក្រសួងផ្សេងទៀត ដូចក្រសួងពាណិជ្ជកម្មអី?

ស៊ុយៈ ក្រសួងពាណិជ្ជកម្ម ក្រោយមកទៀតតាដែលគាត់ទទួលភូមិភាគខាងត្បូង វណ្ណរិទ្ធហ្នឹង គាត់ទទួលខាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

សុជាៈ ហើយចុះវ៉ន វេតហ្នឹង?

ស៊ុយៈ វ៉ន វេត គាត់ខស្សាហ អត់ទេ បានន័យថាគាត់វ៉ាឡើងពីលើ វ៉ាទៅជា ឧបមាថាក្រោយ

ពីចាប់កុយ ឃួន មក គាត់ឡើងជំនួយ កុយ ឃួន ។

សុជា៖ បាទ ។

ស៊ុយ៖ ឡើងជាថ្នាក់កំពូលឯណោះវិញ ។

សុជា៖ កុយ ឃួនហ្នឹងឡើងជាស្អីគេវិញ?

ស៊ុយ៖ កាលពីមុន ខ្ញុំគ្រាន់តែដឹងលេខរៀង ប៉ុល ពត គាត់ទី១ អញ្ចឹងទៅ នួន ជាទីពីរអញ្ចឹង កុយ ឃួន ទីបីអញ្ចឹងទៅណា ។

សុជា៖ បាទ ។

ស៊ុយ៖ សារីបន្ត១ មក១ តាមថ្នាក់មកអញ្ចឹងមក ។

សុជា៖ បាទ ។

ស៊ុយ៖ ហើយក្រោយពីចាប់កុយ ឃួនទៅ ឃើញវ៉ន វ៉េតទៅអង្គុយកៅអីហ្នឹងអញ្ចេះ ខ្ញុំហើយនិងទាំងអស់គ្នាក៏សន្និដ្ឋានថាវ៉ន វ៉េតឡើងហ្នឹងតែម្តង ហើយក្រោយពីចាប់វ៉ន វ៉េតទៀតឃើញតាម៉ុក ឡើងជំនួសវ៉ន វ៉េតមួយទៀត ។

សុជា៖ អាហ្នឹងថ្នាក់អីគេ?

ស៊ុយ៖ អាហ្នឹងបើនិយាយទៅ គេរាប់ថ្នាក់ទី១ ទី២ ទី៣ អាហ្នឹង បើរាប់ថ្នាក់ ។

ភារិទ្ធ៖ អៀង សារី ទីប៉ុន្មាន?

ស៊ុយ៖ អៀង សារីបើនិយាយពីផ្ទៃក្នុងគាត់អាចលើ ក៏ប៉ុន្តែយើងនិយាយថា តាម៉ុកគាត់ទទួលទ័ពអញ្ចឹងណា អៀង សារី គាត់ទទួលការងារផ្សេងទៅ ប៉ុន្តែថាបើសិនជាសិទ្ធផ្ទៃក្នុងវិញ តាម៉ុក ក៏គាត់ក្រោមអៀង សារីដែរ ។ ប៉ុន្តែបើនិយាយសិទ្ធចំហ គឺតាម៉ុក គាត់ទទួលទ័ព អាហ្នឹងទៀតហើយ ។

សុជា៖ សិទ្ធចំហហ្នឹងវាយ៉ាងម៉េច?

ស៊ុយ៖ សិទ្ធចំហខ្ញុំចង់និយាយអញ្ចេះ ចង់និយាយថាក្រោយពីចាប់អ្នកដែលកាន់ទ័ពហ្នឹងទៅ ។

សុជា៖ បាទ ។

ស៊ុយ៖ តាម៉ុក គាត់ឡើងមកជំនួសអាហ្នឹង ។

សុជា៖ ហើយចុះសិទ្ធផ្ទៃក្នុង?

ស៊ុយ៖ សិទ្ធផ្ទៃក្នុង បើយើងនិយាយពី ខ្មែរក្រហមវិញ គឺគេថាសិទ្ធបក្ស ហើយនិងសិទ្ធរដ្ឋបាល ។

សុជាៈ បាទ ហើយអាហ្នឹង គាម៉ុក ហើយនិងអៀង សារីពីណាគេខ្ពស់ជាង?

ស៊ុយៈ បើយើងនិយាយពីសិទ្ធក្នុងជំនាន់ប៉ុល ពតវិញ អៀង សារី គេខ្ពស់ជាង ។

សុជាៈ ហើយចុះបើនិយាយពី កាលហ្នឹង អៀង សារី គាត់ជាស្អីដែរ?

ស៊ុយៈ កាលហ្នឹង គាត់ រដ្ឋមន្ត្រីក្រសួងការបរទេស ។

សុជាៈ ហើយចុះនៅក្នុងបក្សគាត់លេខរៀងទីប៉ុន្មានពូមានដឹងទេ?

ស៊ុយៈ អេ ក្នុងបក្សចាំអត់បានច្បាស់ទេ ។

ភារិទ្ធៈ ហើយចុះក្រៅពីការងារគាត់ គាត់មានចូលធ្វើការទទួលខុសត្រូវខាងអីខ្លះ?

ស៊ុយៈ ក្តាប់អត់បានទេ ។

សុជាៈ ចុះពូអើ ពូថាអំបាញ់មិញបន្ទាប់ពីប៉ុល ពតមក នួន ជា?

ស៊ុយៈ បាទ ។

សុជាៈ នួន ជាទីពីរអេ?

ស៊ុយៈ បាទ ទីពីរ ។

សុជាៈ ហើយគាត់មានកាន់ក្រសួងអីទេ នួន ជាហ្នឹង?

ស៊ុយៈ គាត់កាន់ខាងសភា ។

សុជាៈ អូ ប្រធានសភាអញ្ចឹង?

ស៊ុយៈ បាទ ។

សុជាៈ ក្នុងឆ្នាំណាដែរ?

ស៊ុយៈ តាំងពីចាប់ផ្តើមចូលភ្នំពេញនៅគាត់ ក្រោយពីប៉ុល ពត ប្រកាសខាងយូហ្គោស្លាវីគេថា
ថាប៉ុល ពតជាអ៊ីហ្នឹង ក្រោយពីគាត់ឆ្លើយថា គាត់ជារដ្ឋមន្ត្រីទី១អញ្ចឹងមក

សុជាៈ បាទ ។

ស៊ុយៈ ហើយមួយទៀត គាត់ជាសភាអញ្ចឹងទៅ ។

សុជាៈ ហើយចុះអើ?

ស៊ុយៈ ហើយអៀង សារី គាត់ រដ្ឋមន្ត្រីក្រសួងការបរទេសអញ្ចឹងទៅ ហើយលោកសុនសេនគាត់
ទទួលខាងទ័ពអញ្ចឹងទៅ ហើយលោកខៀវ សំផន គាត់ទទួលខាងប្រមុខរដ្ឋអញ្ចឹងទៅ
ប្រធានគេហៅប្រធាន គណៈ ប្រធានរដ្ឋហ្នឹង ។

ភារីទ្ធៈ ហើយចុះអេថាខាងយូហ្គោស្លាវីធ្វើនៅឯណា?

ស៊ុយៈ ធ្វើនៅភ្នំពេញ ។

សុជាៈ នៅភ្នំពេញហ្នឹង?

ស៊ុយៈ បាទ ។

សុជាៈ ហើយហេតុអីបានជាគេសួរ?

ស៊ុយៈ គេសួរក្រោយពីគេចង់ដឹងថា គេមិនដឹងថាពីណាគេប្រធានបក្សអា៎ ពីណាមេដឹកនាំធំជាង គេ ដល់អញ្ចឹងគេសម្ភាសគេសួរ ។

សុជាៈ យូហ្គោស្លាវីហ្នឹង ជាអ្នកការស្សែតរឺក៏ជាអ្នកដឹកនាំប្រទេសយូហ្គោស្លាវី?

ស៊ុយៈ ប្រទេសយូហ្គោស្លាវីតែម្តង ។

សុជាៈ ឈ្មោះអីគេពូចាំទេ?

ស៊ុយៈ អត់ចាំទេ ។

សុជាៈ គេមកហ្នឹងនៅក្នុងឆ្នាំណាដែរ?

ស៊ុយៈ ក្នុងឆ្នាំ៧៩ដែរ ប៉ុនគ្រាន់តែមិនចាំថ្ងៃ ។

សុជាៈ បាទ ។

ស៊ុយៈ ព្រោះកាលពីដំបូង ក្រោយពីគេបែកភ្នំពេញភ្លាមគេហៅទៅរៀន គេហៅទៅរៀន គេថា បើនិយាយអោយចំជាមួយប៉ុល ពត ។

សុជាៈ បាទ ។

ស៊ុយៈ ក្រោយពីបែកភ្នំពេញហើយ គេហៅទៅរៀនឆ្នាំលើកទី១ ដល់ទៅរៀន អ្នកទាំងអស់គ្នា អន្តុយឆ្លល់ថា មិនដឹងជាពីណាប្រធានបក្ស ។

សុជាៈ ទាំងយើង?

ស៊ុយៈ ទាំងយើងជាសាច់ទ័ពសាច់អីអត់ដឹងទាំងអស់ ។

សុជាៈ បាទ ។

ស៊ុយៈ យើងគ្រាន់តែដឹងថា តាសុន សេន គាត់ ជាអគ្គមេបញ្ជាការហើយ ។

សុជាៈ បាទ ។

ស៊ុយៈ តែខៀវ សំផន អី ១ទាំង ទាំង ហូ យុនអី យើងគ្រាន់តែដឹងថាជាអគ្គមេបញ្ជាការរួម

ទាំងអស់គ្នា ។ ក៏ប៉ុន្តែយើងនៅមិនទាន់ដឹងថាពីណាធំជាងគេ លេខាបក្សណោះ ដល់អញ្ចឹង ក្រោយមកទៀត បានលេចលឺថាខាងយូហ្គោស្លាវីគេសួរ ដល់គេសួរ ប៊ុនប៉ុល ពតគេចេញខ្លួនមក ប៊ុនតែគ្រាន់នៅក្នុងឯកសារសំងាត់របស់គេ ខ្ញុំគ្រាន់តែដឹងប៉ុល ពតហ្នឹងគាត់ឈ្មោះហៅថា សាឡុត ស ដល់ក្រោយពីយូហ្គោស្លាវីសួរហើយ គឺលេច ចេញដាក់ឈ្មោះប៉ុល ពតហ្នឹងហ្នង សាឡុត សហ្នឹងគឺទៅជាប៉ុល ពតតែម្តង ។

ភារិទ្ធៈ ពូដែលឃើញឯកសារសំងាត់ទេ?

ស៊ុយៈ ខ្ញុំធ្លាប់ឃើញដែរ ប៊ុនគ្រាន់តែថា អានេះគេនិយាយពីសមាសភាព ប៊ុនបើនិយាយពីថ្នាក់ អា៎ ម្នាក់នេះគេហៅថា អ្នកទី១ អ្នកទី២អញ្ចឹងទៅ រីក៏វីរជនទី១ រីក៏ទី២ ទី៣ ទី៤អញ្ចឹងទៅណា ។

សុជាៈ អាហ្នឹងជាសៀវភៅរឺក៏ជា?

ស៊ុយៈ ជាសៀវភៅ កូនសៀវភៅតូច ប្រហែល ប៊ុន ។

សុជាៈ ចំណាងជើងថាម៉េច?

ស៊ុយៈ អត់ចាំទេ អត់ចាំ គ្រាន់តែមើលតែសៀវភៅហ្នឹងមួយគ្រួសហើយ ហើយចុះបើខ្លាចគេអ្នកធំៗដែរនោះ ។

សុជាៈ បាទ ។

ស៊ុយៈ មើលសៀវភៅហើយ គ្រាន់តែគេឆែកឃើញអញ្ចឹងហើយគេយកទៅទៀតហើយ ។

ភារិទ្ធៈ ហើយចុះកាលហ្នឹងមានឃើញសៀវភៅជនបដិវត្តអីទេ?

ស៊ុយៈ ឃើញ ទាំងបដិវត្តហ្នឹងទៀត ។

ភារិទ្ធៈ ហើយចុះសៀវភៅហ្នឹង ខុសពី អា៎សៀវភៅសំងាត់?

ស៊ុយៈ អានេះខុសទេ ខុសពីសៀវភៅសំងាត់ អាហ្នឹងគេនិយាយពីវីរភាព និយាយវីរៈ អាយុបក្ស អាយុអីគេ គេក៏កើតហ្នឹង អាតូចៗ អាសៀវភៅតូចៗខ្ញុំនិយាយហ្នឹងណា អាណាទី១ អាណាទី២ អស់ពីណា នៅឯណាគ្រាន់តែដឹងអញ្ចឹង តែបើយើងនៅចុងបក្សអាហ្នឹង ។ គឺយើងនិយាយពីរឿងដែលគោលការណ៍ អាហ្នឹងបើយើងនិយាយផ្លូវ គឺយើងនិយាយពីគោលការណ៍យើងត្រូវធ្វើអីៗ ធ្វើអី អាហ្នឹងគ្រាន់តែធ្វើអញ្ចឹង ក៏ប៊ុនតែថាគ្រាន់តែថាសៀវភៅហ្នឹង អានេះខ្ញុំនិយាយយកតាមផ្លូវកណ្តាល ហើយមិនលំអៀងខាងណាទេ ព្រោះ

ថាកាលនោះបើនិយាយពីសៀវភៅអោយទៅសំលាប់ រឺ ក៏ធ្វើអ្វីមិនអោយមានការរីកចំរើនទេ ។

សុជាៈ បាទ ។

ស៊ុយៈ ប៉ុនតែគ្រាន់តែថារឿងខុសឆ្គងក្តី ហើយអារឿងក្រោយៗមកទៀតក្តីខ្ញុំអត់ក្តាប់បានទេ ប៉ុនតែគ្រាន់តែគោលការណ៍សៀវភៅគេមិនដែលដាក់អោយថាត្រូវតែសំលាប់ រឺក៏ត្រូវតែផ្តាច់ការមួយអញ្ចេះពីរអញ្ចុះពីរអីអត់ទេ អាហ្នឹងបើថានិយាយពីសៀវភៅហ្នឹងរៀបរាប់ហ្នឹង ។

សុជាៈ ទង់បដិវត្តន៍ហ្នឹង?

ស៊ុយៈ បាទ ទង់ហ្នឹង ។

សុជាៈ ហើយចុះអាសៀវភៅសំងាត់នោះ គេនិយាយតែវីរៈ វីរៈអីរបស់អ្នកដឹកនាំទេ?

ស៊ុយៈ បាទ ។

សុជាៈ កាលហ្នឹងថ្នាក់ត្រឹមណាដែលអាចមើលសៀវភៅហ្នឹងបានទង់បដិវត្តន៍អីហ្នឹង?

ស៊ុយៈ អាហ្នឹងបើនិយាយអោយចំ គេថាទោះបីយើងជា គេចាត់ទុកខ្ញុំថាជាជនចំរើនអីអញ្ចឹងទេ ។ ព្រោះខ្ញុំអត់បានចូលនិវត្តន៍ អត់បានចូលបក្សអីទេ ។

សុជាៈ បាទ ។

ស៊ុយៈ ពីព្រោះ ខ្ញុំធ្វើការកាលណាគេជិះជាន់ខ្លាំងខ្ញុំ តែឥតមាត់ ដល់តែអញ្ចឹងមនុស្សបែបហ្នឹងមិនងាយបានឡើងនឹងគេទេ ព្រោះតែតវ៉ាច្រើនគឺគេថាយើងមិនសូវល្អទេ ដូច្នេះគេមិនចាត់ទុកថាអោយចូលទៅអីណាទេ ។

សុជាៈ ដូចខ្ញុំធ្លាប់បានសួរគេពីមុនមកអ៊ាំ គេថាទង់បដិវត្តហ្នឹងមានប៉ុន្មានមានទី១ ទី២ ទី៣ ទី៤?

ស៊ុយៈ មានរហូតដល់ទង់៥ ។

សុជាៈ ទី៥អេ?

ស៊ុយៈ បាទ ។

សុជាៈ ហើយពូមើលដល់ទង់ទីប៉ុន្មាន?

ស៊ុយៈ ខ្ញុំមើលដល់ទង់៥អោះ ប៉ុនតែគ្រាន់ថាដូចថាសៀវភៅគេចែកអោយមើលអញ្ចឹង ឧបមាថា

ខ្ញុំនៅមន្ទីរអញ្ចឹងទៅ គេមិននៅចេះតែមើលទៅ ។

សុជាៈ ទង់៥ ម៉េចទៅ?

ស៊ុយៈ ទង់វាអានេះ គេដាក់ទង់វាមានអារូប ទង់៥អញ្ចឹងទៅណា ទង់ជ័យអា គេដាក់នៅអេក្រប សៀវភៅ ។

សុជាៈ ហើយចុះទង់ទី១ ដល់ទង់ទី៥ វាខុសគ្នាបន្តិចៗ ម៉េចទៅ?

ស៊ុយៈ វាមាន បើឧបមាថាទង់ទី១អញ្ចឹង វាសំរាប់ថ្នាក់មេក្រុមមើលអញ្ចឹងទៅណា ។

សុជាៈ បាទ ។

ស៊ុយៈ ទង់ទី២ ថ្នាក់កងហាអញ្ចឹងទៅ ទង់ទី៣ថ្នាក់កងរយ ទង់ទី៤ថ្នាក់កងវរៈ ទង់ទី៥ អើសំរាប់ អាមេធំៗអញ្ចឹងទៅ អាហ្នឹងការប្រៀបធៀប ខ្ញុំប្រៀបធៀប ។

សុជាៈ បាទ ។

ស៊ុយៈ វាមានថ្នាក់អញ្ចឹង ។

សុជាៈ ហើយគោលការណ៍ការនិយាយនៅក្នុងទង់ហ្នឹង ខ្លឹមសារសំខាន់ពូនិយាយអំបាញ់មិញថា ។ អត់មាននិយាយអំពីធ្វើការផ្តាច់ការ រឺក៏សំលាប់មនុស្សអត់មានទេ?

ស៊ុយៈ បាទ អត់មាននិយាយពីគោលការណ៍ផ្តាច់ការ អត់មាននិយាយពីការសំលាប់មនុស្ស ប៉ុន្តែ ពាក្យមួយគេនិយាយថា មហាលោតផ្លោះ មហាអស្ចារ្យហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ អាហ្នឹងគេគ្រាន់តែថាពង្រឹងហើយនិងបង្កើន ហើយបើថាអោយមានថាអ្នកណាធ្វើមិន ត្រូវ ត្រូវតែសំលាប់អី អត់មាននិយាយទេ ។

ភារ័ទ្ធៈ ចុះកាលហ្នឹង ពូមានដែល ការរស់នៅក្នុងរបបខ្មែរក្រហម មានដែលដឹងថាមានការសំលាប់ មនុស្សដែររឺអត់?

ស៊ុយៈ អត់ដឹងសុទ្ធ អ្នកនៅភ្នំពេញ អត់ដឹងរឿង អ្នកនៅភ្នំពេញអត់អោយចេញមកក្រៅ អ្នកនៅ ក្រៅអត់អោយចូលភ្នំពេញ ដូច្នេះសូម្បីតែឪពុកម្តាយខ្ញុំក៏ខ្ញុំអត់ដឹងថានៅរស់ដែរ ។

ភារ័ទ្ធៈ ចុះពូមានស្តាប់លឺ មានដឹងថាគេចាប់ខ្លួន យើងចេះតែខ្លាចគេអី?

ស៊ុយៈ ចាប់ឃើញគេចាប់មែន ព្រោះឧបមាថាអ្នកនេះក្បត់អញ្ចឹងទៅ គេក្រោយពីគេចាប់បាន អញ្ចឹងទៅ គេមិនមែនខ្លាចគេចាប់ឯងទេណា គេថាឥលូវហៅទៅរៀនសូត្រ ដល់តែហៅ

ទៅរៀនសូត្រ ឧបមាថា ដូចឧទាហរណ៍ថាអូនឯងនៅអញ្ចឹងអា៎ ធ្លាប់ជិតស្និទ្ធជាមួយអូនអីអញ្ចឹងអា៎ ដល់ពេលគេចាប់អូនណោះទៅណា ថ្ងៃក្រោយគេហៅអូនឯងទៅទៀត ដល់តែខ្ញុំនៅជិតហ្នឹងដែរ ខ្ញុំឃើញអញ្ចឹង ។

ភារ័ទ្ធៈ តាមពូ កាលគេចាប់ហ្នឹងពូយល់ថាយ៉ាងម៉េចដែរ?

ស៊ុយៈ អានេះវា ។

ភារ័ទ្ធៈ គេចាប់យកទៅណា?

ស៊ុយៈ គេចាប់ ចាប់ទៅបាត់ៗ ។

ភារ័ទ្ធៈ អត់ដែលឃើញគេមកវិញទេ?

ស៊ុយៈ អត់ដែលឃើញគេមកវិញ ហើយមិនអាចដឹងថាគេចាប់យកទៅណា ហើយបើសិនជាយើងហ៊ានតែសង្ស័យច្រើន គេសង្ស័យយើងទៀត ។

ភារ័ទ្ធៈ មានដែលមានអ្នកសួរដេញដាលទេ?

ស៊ុយៈ អត់មានអ្នកណាដែលហ៊ានសួរដេញដាលទេ ដឹងតែគេហៅទៅប្រជុំ គឺបាត់ខ្លួន ហៅប្រជុំគឺបាត់ខ្លួន ។

ភារ័ទ្ធៈ ហើយហេតុអីបានជាពូខ្លាច?

ស៊ុយៈ អា៎ បើមិនខ្លាចយ៉ាងម៉េច ព្រោះយើងម្នាក់ៗគឺខំតំរង់ខ្លួនដូចទានអញ្ចឹង ថាមៅ៉ងណាគឺមៅ៉ងហ្នឹងហើយ មិនដឹងថាថ្ងៃណាដល់វេណយើង នឹកព្រួយបារម្មណ៍គ្រប់គ្នាទាំងអស់ គឺទៅអញ្ចឹងតែម្តង មិនហ៊ានធ្វើអីអោយខុស ។

ភារ័ទ្ធៈ ហើយពេលចាប់ហ្នឹងនៅក្នុងចិត្តពូគឺដឹងថាចាប់យកទៅសំលាប់?

ស៊ុយៈ អត់ ។

ភារ័ទ្ធៈ ពូយល់ឃើញថាយ៉ាងម៉េច?

ស៊ុយៈ កាលនោះគ្រាន់តែដឹងថាប៉ុណ្ណេះ តែចាប់ទៅ គេគ្រាន់តែថា ចាប់ទៅគេយកទៅអោយធ្វើផ្លូវរទេះភ្លើង ធ្វើអី គ្រាន់តែដឹងតែប៉ុណ្ណឹង តែបើអ្នកណាវាជាចម្លើយគេបានច្រើន តែដឹងដែរ បើអ្នកណាចូលជាប់គេហៅថាខ្មែរបទអា៎ អាហ្នឹងអាចដឹងថាគេសម្លាប់តែម្តង តែបើឧបមាថាជាប់ត្រឹមគេឆ្លើយដាក់ម្នាក់ហើយ ពីរនាក់ ហើយអត់ទាន់ដល់បីនាក់ហ្នឹង អាហ្នឹងបានតែត្រឹមតែទៅធ្វើផ្លូវរទេះភ្លើង រឺ ក៏ជាប់ត្រឹមអ្នកគេសង្ស័យអា៎ គេហៅយកទៅអប់រំ

កសាង នៅកន្លែងកសាងអីអញ្ចឹងទៅណា ។

ភារីទ្ធៈ ពូថាគេចាប់តាមខ្សែ គេចាប់អើ?

ស៊ុយៈ ចេះតែភ័យ ឧបមាថា ខ្ញុំលើកឧទាហរណ៍មួយទៅខាងឃុំរដ្ឋដែរឈ្មោះវណ្ណ ឈ្មោះវណ្ណហ្នឹងកាលពីដើមគាត់ជាជំនួយការនៅឃុំហ្នឹងដែរអាំ ដល់តែគេចាប់ឈ្មោះវណ្ណហ្នឹងទៅអាំកូនចៅគាត់តៗមកគេចាប់ អោយតែថ្នាក់ត្រឹមបក្សជន គឺគេចាប់តាមខ្សែទាំងអស់អញ្ចឹងហ្នឹង ដូច្នេះដូចថាអ្នកនោះមួយហើយអត់មានសកម្មភាពអី ធ្វើអោយគេសង្ស័យក៏ដោយក៏ប៉ុន្តែអ្នកនោះគេចាត់ទុកថាខ្សែរបស់អ្នកនេះ ដូច្នេះបានគេចាប់ទៅ ។

ភារីទ្ធៈ ពូកាលហ្នឹងពូមានដែលនៅ តាមពូនិយាយពូដូចចាំឃុំហ្នឹងច្រើនកន្លែងណា?

ស៊ុយៈ បាទ ។

ភារីទ្ធៈ ហើយចុះពូមានដែលចាំឃុំស្រូវអង្ករអីទេ?

ស៊ុយៈ ហ្នឹងហើយ ក្រោយបំផុតខ្ញុំកាន់ខាងឃុំស្រូវអង្ករហ្នឹងហ្នង ។

ភារីទ្ធៈ ហើយចុះស្រូវអង្ករហ្នឹងមានដែលបញ្ជូនតាមភូមិភាគ តាមអង្គភាពអីទេ?

ស៊ុយៈ សំរាប់នៅភ្នំពេញ ក្រសួងមន្ទីរអី គឺទៅបើកអង្ករនៅកន្លែងហ្នឹងទាំងអស់ ។

ភារីទ្ធៈ ហើយអង្ករមានដែលនាំចេញទៅក្រៅអត់ទេ?

ស៊ុយៈ នាំ ។

ភារីទ្ធៈ នាំច្រើនទេ?

ស៊ុយៈ នាំម្តង ៦០តោន ១០០តោនដាង ទៅ ខ្ញុំតែងតែដឹងថា នាំទៅកាណាដា ទៅហុងកុងអីអញ្ចឹង អាហ្នឹងខ្ញុំធ្លាប់ដឹង ហើយពេលដែលចេញទៅ គ្រាន់តែខ្ញុំដឹងត្រង់ថា ហោះ ឥលូវគេយកក្រដាសប៉ុណ្ណឹងអញ្ចឹងមកអញ្ចឹងមក មានបោះត្រាមានអីអញ្ចឹង អោះអើត្រូវមានអង្ករចេញទៅកំពង់សោមទៅប៉ុណ្ណេះ តែគ្រាន់តែទៅណាអីណាខ្ញុំអត់ដឹងទេ គ្រាន់តែដឹងថាប៉ុណ្ណេះតោន ប៉ុណ្ណេះតោនគ្រាន់តែដឹងប៉ុណ្ណឹងទេ ។

ភារីទ្ធៈ ហើយចុះពូដឹងថាទៅហុងកុង ទៅកាណាដាអី?

ស៊ុយៈ អាហ្នឹងខ្ញុំលួចសួរតាមរយៈអ្នក ខាងរទេះភ្លើងអាំ គេថាអើ អង្ករទៅសារនេះអាចទៅខាងហុងកុង រឺក៏កាណាដាអីអញ្ចឹង យើងលួចសួរអញ្ចឹង ។

ភារីទ្ធៈ កាលហ្នឹងគេបញ្ជូនទៅធ្វើអី?

ស៊ុយៈ មិនដឹង កាលហ្នឹងយើងអត់មានសិទ្ធដេញដាលថ្នាក់លើគេអីបានទេ។

ភារិទ្ធៈ ពីណាគេអ្នកស៊ីញ៉ើអោយចេញទៅហុងកុង កាណាដាអី?

ស៊ុយៈ អេ អារឿងឧទាហរណ៍ថាខ្ញុំចង់និយាយលើកឧទាហរណ៍អំបាញ់មិញនេះ មិនមានដឹងថាមានគេដឹងថាទៅហុងកុង រឺក៏កាណាដាអីទេ គ្រាន់តែខ្ញុំលួចសួរខាងអេខស្សាហកម្ម អេខាងវទេះភ្លើងអញ្ចឹងណា គេថាអើសង្ស័យថាទៅកាណាដា រឺក៏ហុងកុងអីអញ្ចឹងទៅ គ្រាន់តែគេប្រាប់មកអញ្ចឹង គេគ្រាន់តែប្រាប់មក ហើយលាយលក្ខជាអក្សរមកថា អេមិត្តអារៀបចំបែងភាគអង្ករអោយទៅជាអង្ករ១៥ភាគរយប៉ុណ្ណេះតោន ៣៥ភាគរយប៉ុណ្ណេះតោន ហើយអា១៥ភាគរយខ្ញុំចង់បញ្ជាក់ថាក្នុងមួយរយគ្រាន់ហ្នឹងវាមានបាក់១៥គ្រាប់ បាទ គេបែងគុណភាពហ្នឹងអាំ ហើយអាំ ៣៥ភាគរយហ្នឹង ក្នុងមួយរយហ្នឹងវាបាក់៣៥គ្រាប់។

សុជាៈ រាប់អញ្ចឹង?

ស៊ុយៈ បាទ អាហ្នឹងគេបែងគុណភាព ព្រោះវាអាម៉ាស៊ីនគីឡូលេខ៦ហ្នឹងវាមានអូតូមេទិកវា កាលណាទរគេមកអញ្ចឹង វាចេញពីទរមួយទៅទរមួយ ចេញពីទរមួយចូលទរមួយ ស្រឡាញ់អង្ករប៉ុន្មានភាគរយគឺបានប៉ុន គឺបានប៉ុនណ្ណឹងហើយ គ្រាន់តែស៊ីវ៉េមានប្រដាប់ស៊ីវ៉េគេគឺអ្នកបច្ចេកទេសគេហ្នឹងអស់ទាស់ដែរ ស៊ីវ៉េអោយបានទៅជាអង្ករប៉ុន្មានភាគរយគឺបានប៉ុណ្ណឹងភាគរយ ។ ហើយអង្ករកាលណាចូលមកអញ្ចឹង គឺគេមួល ទ្រនិចវាទុកអោយហើយអញ្ចឹងក្នុងទរវាហ្នឹង កាលណាគ្រប់មួយរយគីឡូអញ្ចឹង ប៉ុនតែក្នុងនោះគេមួលដាក់ថា១០១គីឡូគិតទាំងទំងន់សំបកបាវផង កាលណាគ្រប់១០១គីឡូហ្នឹង គឺអូតូមេទិកវាទំលាក់មកគ្រឹបអញ្ចឹងមក យើងដោះអាក្រវ៉ាត់ហ្នឹងចេញ យកបាវស៊ឹកមកវិញ អូតូមេទិកវាទាញចេញទៅវិញទៀត ដល់តែកាលណាអង្ករវាចេះតែហូតធ្លាក់មកៗគ្រប់១០១គីឡូហ្នឹង អូតូមេទិកអញ្ចឹងមក អង្ករវាធ្លាក់ចូលបាវក្តុក ធ្លាក់ចុះមកក្រោមមក អានោះដោះក្រវ៉ាត់ហ្នឹងដាក់បាវថ្មី ហើយទាញឡើងទៅទៀត។ ក្នុងមួយថ្ងៃអាចកិនអង្ករ១៦០០បាវ ទៅ ១៧០០បាវ ហើយពេលនោះកំលាំងពលកម្មដែលធ្វើហ្នឹងអត់មានម៉ោងណាឈប់ទេ អស់ពីវេណមួយចូលវេណមួយ គេថាថ្ងៃណាក៏ថ្ងៃបុណ្យណា រាល់ថ្ងៃទាំងយប់ទាំងថ្ងៃអត់មានម៉ោងឈប់ ។

ភារិទ្ធៈ ហើយហូបចុកអីយ៉ាងម៉េចដែរ?

ស៊ុយៈ  កាលនោះ កាលនោះ គឺនៅខាងឃ្លាំងរដ្ឋហ្នឹង គឺអត់មានត្រូវការបានជួបបបរអីហ្នឹងគេទេ ខាងឃ្លាំងរដ្ឋគេតំកើងអា៎ គេអត់ តែគោលការណ៍គេអោយហូបបីពេលហ្នឹង គឺបីពេលមែន

ភារិទ្ធៈ  ចុះអ្នកនៅខាងកម្មករ?

ស៊ុយៈ  អ្នកនៅខាងកម្មករហ្នឹង គឺបាយបីពេលអត់ដែលស្គាល់ជាតិបបរទេ នៅខាងឃ្លាំងរដ្ឋហ្នឹង ខ្ញុំប្រាប់អញ្ចឹង

សុជាៈ  ហើយចុះពូនៅហ្នឹងពូកាន់ខាងឃ្លាំង អត់មានកាន់ខាងម៉ាស៊ីន អី?

ស៊ុយៈ  ខាងឃ្លាំងខាងម៉ាស៊ីនហ្នឹងគឺនៅលើខ្ញុំគ្រប់គ្រងដែរ ។

សុជាៈ  អូ ។

ស៊ុយៈ  ព្រោះឧបមាថាគេត្រូវការកិនអង្ករទៅខាងណាប៉ុន្មានហ្នឹង ខ្ញុំទៅបញ្ជារខាងម៉ាស៊ីនហ្នឹងអោយគេឆេះទៅជាអង្ករអញ្ចឹងទៅ ។

សុជាៈ  បាទ ។

ស៊ុយៈ  កិនអង្ករទៅ អ៎ រួចឃ្លាំងនេះ រួចអង្ករនេះត្រូវកិនប៉ុណ្ណេះតោនអា៎ រោងម៉ាស៊ីននេះត្រូវកិនប៉ុណ្ណេះតោន រោងម៉ាស៊ីននោះកិនប៉ុណ្ណេះតោនអញ្ចឹងមក បើយើងកិនសំរាប់តែម៉ាស៊ីនមួយយើងធ្វើអត់ទាន់ ។

សុជាៈ  បាទ ។

ស៊ុយៈ  រួចអញ្ចឹងហើយម៉ាស៊ីនបួន ប្រាំហ្នឹងគឺត្រូវកិនគ្រប់ម៉ាស៊ីនទាំងអស់ កំលាំងម៉ាស៊ីននេះកិនប៉ុណ្ណេះតោន ម៉ាស៊ីននោះកិនប៉ុណ្ណេះតោន យើងសរុប ដល់មោ៉ងវាថាគ្រប់ហើយ រទេះភ្លើងចូលហើយ យើងលើកដាក់លើកដាក់ ស៊ីញ៉េខ្ទាច់ ប្រគល់អោយគេទៅ ។

ភារិទ្ធៈ  ខ្ញុំចង់ដឹងថាអង្ករដែលគេនាំចេញទៅក្រៅអា៎ គេមានដែលនាំចូល ស្អីចូលមកវិញ?

ស៊ុយៈ  កាលពីខ្ញុំនៅឃ្លាំងភ្នំពេញ ខ្ញុំដឹង គ្រាន់ថា បើឃ្លាំងនៅគីឡូលេខ៦គេបញ្ជូនកៅស៊ូទៅស្រាប់តែឃើញគ្រឿងដែក គ្រឿងបន្លាស់ម៉ាស៊ីនអីមក ហើយពេលនោះខ្ញុំគ្រាន់តែឃើញមនុស្សកើត កាលខ្ញុំនៅទទួលភារៈមួយនៅខាងឃ្លាំង គេហៅឃ្លាំងកំពង់ទឹកកកហ្នឹង ម៉ាស៊ីនគ្រប់ធុនទាំងអស់ ផ្លូវខាងកើតផ្សារថ្មីអត់មានផ្លូវចេញទៅមាត់ទន្លេបានទេ ដាក់ម៉ាស៊ីនតំរៀបគ្នាពេញទាំងអស់ ។

សុជាៈ  ដាក់កណ្តាលថ្នល់?

ស៊ុយៈ ដាក់តាមៗថ្នល់ហ្នឹង ចាប់ពីផ្សារថ្មីមកកើតគឺគេទុកតែផ្លូវមួយ ផ្លូវពីរសំរាប់កម្មករបើកឡាន ធ្វើការទេ ក្រៅពីហ្នឹង សុទ្ធតែរៀបម៉ាស៊ីនពេញៗទាំងអស់ ។

សុជាៈ ម៉ាស៊ីនអីគេខ្លះ ម៉ាស៊ីនរោងចក្រ?

ស៊ុយៈ ម៉ាស៊ីនស្រាប់ស្រាំ ម៉ាស៊ីនស្រែ ម៉ាស៊ីនធំៗ ម៉ាស៊ីនកប៉ាល់ ម៉ាស៊ីនអី គឺខ្ញុំមិនអាចស្គាល់ឈ្មោះម៉ាស៊ីនអស់ទេ ប៉ុនគ្រាន់តែខ្ញុំដឹងថាម៉ាស៊ីនចង់ប៉ិនផ្ទះអស់ ក្នុងឡាំង ដាក់តំរៀបពេញទាំងអស់ ខ្ញុំដល់ពេលខ្ញុំមកដល់ស្រុកវិញ ខ្ញុំអគ្គុយឆ្ងល់ថា ម៉ាស៊ីនមិនដឹងជាគេយកទៅណាអស់ ដល់តែខ្ញុំស្រាវជ្រាវទៅ អូ គេថាយកដឹកទៅយួនអស់ ។

ភារិទ្ធៈ ហើយយកទៅយួនធ្វើអី?

សុជាៈ នៅពេលណា?

ស៊ុយៈ ពេលប៉ុល ពតចាញ់ហ្នឹង យួនចូលមកហ្នឹង យួនដឹក យកម៉ាស៊ីនហ្នឹងទៅទាំងអស់ ។

សុជាៈ ហើយចុះពួកកាលហ្នឹង ម៉ាស៊ីនហ្នឹងដឹកមកពីណាមកវិញ?

ស៊ុយៈ ដឹកគ្រប់ប្រទេស ប្រទេសណាដែល ឧបមាថា កូរ៉េ តាំងពីយូហ្គោស្លាវី ពិសេសចិនដឹកមកម៉ាស៊ីនច្រើនជាងគេ ដឹកមក យកមកចូល គ្រាន់តែខ្ញុំឃើញថាម៉ាស៊ីននៅខាងកើតផ្សារថ្មីហ្នឹង អូគ្រប់ផ្លូវទាំងអស់ ម៉ាស៊ីនណែន ។

សុជាៈ កាលហ្នឹងឆ្នាំណាដែរ?

ស៊ុយៈ ឆ្នាំ៧៦ ។

សុជាៈ ចុះក្រៅពីម៉ាស៊ីនមានដឹកអីផ្សេងយកមកទៀតទេ?

ស៊ុយៈ មានតែក្រណាត់ ។

សុជាៈ ក្រណាត់?

ស៊ុយៈ បាទ ក្រណាត់ ដែកហើយនិងគ្រឿងបន្លាស់អីផ្សេងៗអីហ្នឹង តាំងពីចប តាំងពីស្ទូហ្នឹង ។

សុជាៈ ហើយចុះកាំភ្លើង?

ស៊ុយៈ អូកាំភ្លើងអត់ដែលឃើញមានទេ ។

សុជាៈ អត់មានដែលចូលមកស្រុកខ្មែររឺក៏ពូមិនដែលឃើញ?

ស៊ុយៈ មិនដែលឃើញ ប៉ុនតែថា គេចូលឯណា អាហ្នឹងដូចថាវាខុសមុខសញ្ញាណា គេអាចអោយដឹងអាហ្នឹងក៏អាចថាបានដែរ ព្រោះគ្រាន់បើថា ដែក បើថាក្រណាត់ បើថាគ្រូវគ្រឿង

បន្ទាស់ខ្មៅខ្យងអី អាហ្នឹង បើត្រូវអាណាគេអោយចូលឃ្លាំង បានគេអោយដឹកតែម្តង ។

សុជាៈ ហើយទំនិញច្រើនតែយើងដឹកចេញអោយគេវិញច្រើនតែទំនិញអីគេ?

ស៊ុយៈ ច្រើនតែកៅស៊ូ ហើយនិង អង្ករ ។

សុជាៈ ស្រូវ អង្ករ ។

ស៊ុយៈ បើស្រូវអត់មានទេ ទៅជាអង្ករតែម្តង ព្រោះខ្ញុំនៅកាន់ខាងឃ្លាំងស្រូវហ្នឹង ឃើញអត់មានដែលចេញស្រូវទេ គឺចេញចេញជាអង្ករទៅតែម្តង ។

ភារិទ្ធៈ យកអាទៅក្រៅ ហើយបែងចែកនៅក្នុងស្រុកអីអញ្ចឹងអាណាច្រើនជាងតាមពូគ្គាប់មើល?

ស៊ុយៈ អត់ទេ ទៅក្រៅតិចជាង ។

ភារិទ្ធៈ តិចជាង?

ស៊ុយៈ ទៅក្រៅតិចជាង នៅក្នុងស្រុកគេ ព្រោះអាទៅក្រៅ ព្រោះគ្រាន់តែតាមអាមួយវា លាវដែលកប៉ាល់លិចទាំងអង្ករ?

សុជាៈ បាទ ។

ស៊ុយៈ ហើយពួកខ្ញុំទៅស្រង់អង្ករហ្នឹង ស្លាប់អស់មនុស្សម្នាក់ពីរ ។

សុជាៈ ទៅជួយលាវតែម្តង?

ស៊ុយៈ ទៅជួយលាវ កប៉ាល់មួយដឹកទៅជួយលាវ ដែលលិចនៅអាមេគង្គលើ ។

ភារិទ្ធៈ នៅកន្លែងណា?

ស៊ុយៈ អាំ ហួសពីបំបែក ហួសពីអាបំបែកហ្នឹងទៅ វាទៅជុងហ្នឹងអាដងកាល់កប៉ាល់ចាស់ ដែលវាលិចចាស់កាលពីឆ្នាំ៧៥ហ្នឹង ។

សុជាៈ អូ ។

ស៊ុយៈ ដល់ទៅជុងអាហ្នឹងទៅឆ្នុះបាតហ្នឹង លិចអាអង្ករហ្នឹង ។

សុជាៈ ទន្លេបួនមុខយើងហ្នឹង?

ស៊ុយៈ ខាងកើតអាបួនមុខអាទៅមេគង្គលើ ។

សុជាៈ អាទៅមេគង្គលើអញ្ចេះ?

ស៊ុយៈ បាទ ។

សុជាៈ អូ ។

ស៊ុយៈ វាទៅដុតលិចនៅហ្នឹង ហើយដល់ហើយប្រមូលកម្មករទាំងអស់ គ្រប់ក្រសួងមន្ទីរទៅជួយស្រង់អង្ករហ្នឹង ដល់តែទៅជួយស្រង់ ពួកខ្ញុំក៏ទៅជួយទេ ហើយកាលហ្នឹងខែកត្តិកផង ដល់តែទៅជួយទៅ ចុះក្នុងកប៉ាល់វាធំដូចក្រោមផ្ទះអញ្ចឹងអេ ។

សុជាៈ បាទ ។

ស៊ុយៈ ហើយច្រកចេញតែមួយអញ្ចឹង ដល់តែមុជទៅកាយយកអង្ករពីណោះ ដល់ពេលអស់ដង្ហើមមកវិញងើប ងើបវាខុសអាប្រឡោះហ្នឹង ទៅឃុំអាខ្លួនជាប់នៅហ្នឹងអានៅកប៉ាល់ហ្នឹងស្លាប់ ។

ភារីទ្ធៈ កាលហ្នឹងឆ្នាំណាដែរពូ?

ស៊ុយៈ ឆ្នាំ៧៧ ។

សុជាៈ ថីបានកប៉ាល់ហ្នឹងមកបាន?

ស៊ុយៈ បាទ ។

សុជាៈ ថីបានកប៉ាល់ហ្នឹងបានលិចហើយបាន បានមកដល់នេះ?

ស៊ុយៈ យើងដាក់អង្ករយកទៅជួយលាវ ។

សុជាៈ អូ ។

ស៊ុយៈ ដល់តែពេលចេញពីកន្លែងដាក់ហើយទៅហ្នឹង មិនបើកទៅជួយលាវ ដល់តែបើកទៅ វាអត់បានទៅដល់លាវឯណា វាទៅដុតនឹងអាដង់កាល់អាកប៉ាល់លិចចាស់ចាស់ហ្នឹង ឆ្ងាយទៅ ។

សុជាៈ អញ្ចឹងបានន័យថាកាលជំនាន់ហ្នឹងយើងយកអង្ករយកអីទៅលាវ ទៅវិញ?

ស៊ុយៈ បាទ ។

សុជាៈ ប៉ុនមិនមែនលាវមិនមែនចុះយកអង្ករខ្លួនឯងទេ?

ស៊ុយៈ មិនមែនទេ មិនមែនលាវដឹកទេ ។

ភារីទ្ធៈ ហេតុអីបានជាយើងជួយលាវ?

ស៊ុយៈ អត់ដឹង ខ្ញុំអត់ដឹង គ្រាន់តែដឹងថាអង្ករទៅលាវ គ្រាន់តែដឹងអញ្ចឹង ។

សុជាៈ តែកាលយើងដឹកអង្ករទៅលាវហ្នឹង យើងវាយជាមួយវៀតណាមឥលូវ ពូមានដឹងទេ?

ស៊ុយៈ នៅទេ ។

សុជាៈ នៅទេ?

ស៊ុយៈ បាទ ។

សុជាៈ ហើយពូ ពូនិយាយអំបាញ់មិញសុទ្ធតែរឿងនាំចេញនាំចូលអី?

ស៊ុយៈ បាទ ។

សុជាៈ ហើយខ្ញុំបកមកបន្តិចវិញ អើ ពូនិយាយពីតួនាទីរបស់តាម៉ុក អៀង សារី សុន សេន ប៉ុល ពតអីអញ្ចឹងអាំ ចុះពូ ខ្ញុំចង់សួរពីឈ្មោះផ្សេងទៀត ដូច អៀង ធារីទ្ធអី ពូមានដែលស្គាល់ទេ?

ស៊ុយៈ អៀង ធារីទ្ធហ្នឹង គ្រាន់តែដឹងថាគាត់នៅក្នុងជួរអ្នកធំដែរ ។

សុជាៈ បាទ ហើយគាត់មានឋានៈជាស្អីដែរ?

ស៊ុយៈ អី ឋានៈគាត់គ្រាន់តែខ្ញុំអត់ចាំ អីដូចខាងសិក្សាធិការ អញ្ចឹង អីមិនដឹងទេ ខាងអប់រំ ។

សុជាៈ ហើយចុះខាងសុខាភិបាលពីណាគេ?

ស៊ុយៈ ជួន ជឿន ។

សុជាៈ ជួន ជឿនហ្នឹង?

ស៊ុយៈ បាទ ។

សុជាៈ ហើយចុះពូមានដឹងថាអៀង ធារីទ្ធមានតួនាទីក្នុងបក្សស្អីគេដែរ?

ស៊ុយៈ បើនិយាយអោយចំទៅ សុទ្ធតែមានតួនាទីក្នុងបក្សធំៗទាំងអស់ ។

សុជាៈ អ្នកប៉ុន្មាននាក់ហ្នឹង?

ស៊ុយៈ បាទ ។

សុជាៈ ពូអាចរ៉ាយរ៉ាប់ខ្លះបានទេ ដូចថាអ្នកណាដែលមានតួនាទីសំខាន់ៗក្នុងបក្ស?

ស៊ុយៈ បើតាមខ្ញុំពិចារណាឃើញអ្នកដែលសំខាន់ជាងគេ បើនិយាយទៅ គេថាវាផ្នែកខុសៗគេ ផ្នែកខុសៗគ្នា ប៉ុនមិនដឹងថាពីណាខ្លាំងជាងពីណា ប៉ុនមិនអាចដឹង ។

សុជាៈ បាទៗ ។

ស៊ុយៈ ដូចថាលោកខៀវ សំផនអញ្ចឹងគាត់ ។

**កាសែ្សត ទី ២**

ស៊ុយៈ អាហ្នឹង មុខសញ្ញាគាត់ចេញទទួលទៅ ។

សុជាៈ បាទ ។

ស៊ុយៈ អត់មានអ្នកណាមកអញ្ជើញ គាត់បានតែដើរមើល ការងារតាមឃុំងជួយរៀបចំទុកដាក់អីអញ្ជើងទៅ ។

ភារីទ្ធៈ អញ្ជើងខៀវ សំផនអត់សួរមានតួនាទីទេ?

ស៊ុយៈ អត់សួរមានតួនាទីអីទេ បើតាមខ្ញុំដឹងកាលពី ខ្ញុំនៅភ្នំពេញ ក្រោយពីហ្នឹងគឺ ហាក់ដូចជាគេគេមាន សូម្បីតែឡានគេជិះហ្នឹងក៏ទំនើបៗហួសហេតុដែរ តែដោយឡែកខៀវ សំផនឡាំប្រឹតាកញ្ចាស់ ។

ភារីទ្ធៈ អៀង សារី តួនាទីគាត់ស្អីគេ?

ស៊ុយៈ អៀង សារី តួនាទីគាត់នៅក្រសួងការបរទេស ។

សុជាៈ នៅក្នុងបក្សអីគេ?

ស៊ុយៈ អាហ្នឹង អ្នកធំៗដល់ថ្នាក់ហ្នឹងហើយគេចែកការងារគ្នាហើយ ក្នុងបក្សជាមួយគ្នាហើយ ។

សុជាៈ បាទ ។

ស៊ុយៈ ព្រោះបើមិនអញ្ជើង កន្លែងសំខាន់ៗ ក្រសួងការបរទេសវាសំខាន់ដែរហើយ ដូច្នេះយកអ្នកដែលមិនសំខាន់ទៅដាក់យ៉ាងម៉េចកើត ។

សុជាៈ ហើយចុះអៀង ធារីទ្ធហ្នឹងក៏មានតួនាទីក្នុងបក្សហ្នឹងដែរ?

ស៊ុយៈ អាហ្នឹងដូច អៀង ធារីទ្ធ គាត់ដូចប្រពន្ធអៀង សារីហើយ រឿងអីគាត់ខាងក្រសួងមួយដែរ ។

ភារីទ្ធៈ ហើយចុះប្រពន្ធប៉ុល ពតវិញ?

ស៊ុយៈ ប្រពន្ធប៉ុល ពត គាត់ ខៀវ ប៉ុណ្ណារីហ្នឹង គាត់ប្រធាននារីកម្ពុជាទាំងមូល ។

ភារីទ្ធៈ ហើយចុះប្រពន្ធសុន សេន?

ស៊ុយៈ ប្រពន្ធសុន សេនគាត់ដូចខាងក្រសួងអីមួយមិនដឹង ខ្ញុំ ភ្លេចហើយ យុន យ៉ាត ហ្នឹង សុទ្ធតែគេថ្នាក់ៗលើហើយ ។

ភារីទ្ធៈ ហើយចុះពីណាគេនៅក្រសួងឃោសនាការ វប្បធម៌អី?

ស៊ុយៈ ហ៊ូ នឹម ហ៊ូ យន់ គ្រាន់តែបែកភ្នំពេញទៅ គេចាប់គាត់តែម្តង បាទ ។

សុជាៈ អើ ពូ នៅក្នុងជំនាន់ប៉ុល ពតពូមានដឹងថាមានការបះបោរប៉ុន្មានដងៗទេ?

ស៊ុយៈ អូ បើថាមានការបះបោរហ្នឹង គឺញឹកណាស់បើតាមខ្ញុំដឹងអញ្ជើងបានគេថា “កន្លែងណាមាន

ការកៀបសង្កត់ខ្លាំង កន្លែងហ្នឹងមានការរើកខ្លាំងដែរ» ។ បើនិយាយពីរដ្ឋប្រហារញឹកបំផុតគិតជាស់មួយអញ្ចឹងទៅ ចាប់ កាលជំនាន់ស្រី យ៉ា បះ អញ្ចឹងទៅ ចាប់មួយទៅ កុយ ធួន អញ្ចឹងទៅ ចាប់មួយទៅ ក្រោយមកទៀតពីណាគេបះទៅ ចាប់ទៅ ចាប់ៗញឹកមែនទែនណា ។

ភារិទ្ធៈ ស្រីយ៉ាហ្នឹងគាត់កាន់ខាងអីទៅ?

ស៊ុយៈ គាត់ខាងឥសាន ។

ភារិទ្ធៈ ខាងទិសឥសាន ហៅយ៉ាៗហ្នឹង?

ស៊ុយៈ ស្រីយ៉ាហ្នឹង ។

សុជាៈ ស្រី រឺ ប្រុស?

ស៊ុយៈ ប្រុស អា៎ ប៉ុនតែឈ្មោះស្រីយ៉ា ។

ភារិទ្ធៈ ឈ្មោះស្រីយ៉ា ហៅយ៉ា យ៉ា?

សុជាៈ បះយ៉ាងម៉េច ដូចគាត់រៀបចំ?

ស៊ុយៈ ខ្ញុំចង់និយាយអញ្ចេះ ស្តាប់កើត ឧបមាថាគេចង់បង្កើតបក្សមួយអញ្ចឹងទៅ ដើម្បីផ្តួលបក្សនេះចេញអញ្ចឹងទៅណា ។

សុជាៈ បាទ ។

ស៊ុយៈ ដូច្នេះគេកសាងកំលាំងគេគ្រប់កន្លែង គ្រប់កន្លែងអីអញ្ចឹងទៅហើយ មើលតែហើយគេផ្តួលទៅតែម្តង ដល់តែប៉ុល ពតដឹង ចាប់តាមខ្សែ ដែលខ្ញុំថាព្រួយបារម្ភមិនដឹងថាគេចាប់យកទៅណាអីមកណា អារឿងភ័យអាហ្នឹង ។

សុជាៈ អឺ ។

ស៊ុយៈ ឧបមាថាបើគេចាប់ខ្សែហ្នឹងបានអញ្ចឹងហើយអា៎ គេអត់ទុកអេ គេបញ្ជារអោយចាប់អស់រលីង ។

ភារិទ្ធៈ អាហ្នឹងប៉ុល ពតបញ្ជារអោយចាប់ផ្ទាល់រឺក៏?

ស៊ុយៈ ចាប់ បើមិនប៉ុល ពតបញ្ជារយ៉ាងម៉េចបើគេប្រុងធ្វើរដ្ឋប្រហារគាត់ហើយ មិនគាត់បញ្ជារអោយចាប់ ។

ភារិទ្ធៈ ហើយចុះក្រៅពីប៉ុល ពតមានពីណាបញ្ជារទៀតទេ?

ស៊ុយៈ អត់ភ្លាប់បានទេ ព្រោះថាអញ្ចេះ អោយតែឃើញឡានបិទឃ្លប់ជិតខាងសន្តិសុខមកហ្នឹង គឺដឹងថាមកកន្លែងហ្នឹង គឺមានចាប់ហើយកន្លែងហ្នឹង ។

សុជាៈ ឡានហ្នឹងដឹងថាអញ្ចឹងហ្ន?

ស៊ុយៈ ដឹងអញ្ចឹងហ្ន ។

ភារិទ្ធៈ ពេលចាប់ខ្លាំង ចាប់ក្នុងឆ្នាំណា?

ស៊ុយៈ ចាប់ពេញទាំងអស់ តាំងពីឆ្នាំ៧៧ ៧៨ នេះ គឺចាប់ខ្លាំងជាងគេ ។

ភារិទ្ធៈ អញ្ចឹងចាប់ផ្ដើមចាប់តាំងពីឆ្នាំ៧៧មក?

ស៊ុយៈ ចាប់ហូរហែរហូត ប៉ុនតែគ្រាន់ថា ៧៥ ៧៦ វាតិចអា៎ ចាប់ពី៧៧ ។

ភារិទ្ធៈ ចាប់គេធ្វើយ៉ាងម៉េច?

ស៊ុយៈ ចាប់បើតាមខ្ញុំភ្លាប់បាន គេហៅតាមរយៈ វាបណ្ដាយព្រាបអា៎ បើនិយាយអោយចំទៅគឺប៉ុល ពតបែកបាក់ផ្ទៃក្នុង ។ ។បែកបាក់ផ្ទៃក្នុង ដល់តែអញ្ចឹងទៅ មនុស្សយកកំលាំងមកមកគ្របកំលាំងអូនឯងអញ្ចឹងទៅ ធ្វើបាបវីក៏ចាប់អូនឯងអញ្ចឹងទៅ ដល់តែពេលអូនឯង ។ ឧបមាថាអូនឯងមិនមានខ្សែណោះមួយទៀត អូនឯងយកខ្សែទៅចាប់ពួកខ្ញុំអញ្ចឹងវិញទៅ ដូចថាចាប់ទៅ ចាប់មក ចាប់ទៅ ចាប់មក អត់ដឹងអ្នកណាល្អ អ្នកណាអាក្រក់បណ្ដោយពីចុងបញ្ចប់ អត់ដឹងពីណាល្អ ពីណាអាក្រក់បណ្ដោយ ។

ភារិទ្ធៈ ពេលគេចាប់ហ្នឹងមានគេចងអីទេ?

ស៊ុយៈ អា៎ សុទ្ធចងឥតចំណង ដែលខ្ញុំឃើញផ្ទាល់នឹងភ្នែកហ្នឹងបានខ្ញុំខ្លាចហ្នឹង គេចាប់ចងពើងទ្រូងមកក្រោយអញ្ចេះអត់មានចំណងទេ ចងអត់ចំណងអា៎ គេចុចទីណា ចុចអត់ចំណងអា៎ ពើងអញ្ចឹងហ្ន លើកចងអញ្ចឹង ។

សុជាៈ អូ អត់ខ្សែ?

ស៊ុយៈ អត់ខ្សែ មិនដឹងជាគេចុចត្រង់ណាទេ ។

សុជាៈ ហើយចុះអ្នកចាប់ហ្នឹងសុទ្ធតែកងពិសេសរបស់គេរឺក៏?

ស៊ុយៈ សុទ្ធតែកងពិសេសហើយដែលគេចេះក្បួនរបស់គេហើយបានជាគេចាប់ចងអត់ចំណងបាន ។

សុជាៈ ចុះពូខ្ញុំចង់សួរថាការបះបោរមុនដំបូង តាមពូដឹងខាងណាបះបោរមុនគេ?

ស៊ុយៈ តាមដឹង ខាងឧត្ដរ ខាងឥសាន ហើយ បន្ទាប់ពីឥសានមក ខាងឧត្ដរ ។

សុជាៈ ឥសានមាន?

ស៊ុយៈ ស្រីយ៉ា ។

សុជាៈ ស្រីយ៉ាហ្នឹង?

ស៊ុយៈ បាទ ។

សុជាៈ ហ្នឹងនៅក្នុងឆ្នាំណា ៧៦ រឺ ៧៧?

ស៊ុយៈ តាំង៧៦ មក ។

សុជាៈ ហើយចុះក្រោយមកខុត្តរអេ?

ស៊ុយៈ ក្រោយមកបន្តរហូត ។

សុជាៈ ចុះ ខុត្តរៗពីណាគេ?

ស៊ុយៈ ខុត្តរ កុយ ធួន ។

សុជាៈ កុយ ធួន?

ស៊ុយៈ បាទ ។

សុជាៈ ចុះពូមានដឹងថាក្រោយពីកុយ ធួន មកមានពីណាគេដែលគេចាប់ទេ?

ស៊ុយៈ វាអញ្ចេះ អានេះ គេចាប់តាមខ្សែ ។

សុជាៈ អូ ។

ស៊ុយៈ គេចាប់តាមខ្សែ ខ្ញុំមិនអាចរៀបរាប់អស់ទេ ព្រោះវាចាប់វាច្រើនពេក ចាប់ និយាយ អោយចំតាំងពីកងពលរហូតមកដល់ក្រុម ។

សុជាៈ កាលហ្នឹងកងពលខាងខុត្តរហ្នឹងកងពលលេខប៉ុន្មានពូមានដឹងទេ?

ស៊ុយៈ អត់ដឹង ។

សុជាៈ ហើយចុះពូមានដែលលឺកងពល ៣១០ទេ?

ស៊ុយៈ អត់ ដែលលឺដែរ តែមិនដឹងខាងណាអាំ ព្រោះ យើងវាមិនបានយកចិត្តទុកដាក់អី អញ្ចឹងដែរ ។

សុជាៈ ហើយពូមានដែលលឺឈ្មោះអឿនទេ?

ស៊ុយៈ អឿន ។

សុជាៈ បាទ ។

ស៊ុយៈ អត់ ។

សុជាៈ ព្រោះខ្ញុំធ្លាប់ទៅសម្ភាសគេនៅកំពង់ធំអា៎ ហើយគេថាឈ្មោះអឿនហ្នឹង គាត់ជាប្រធានកងពល៧១០ អេ ៣១០ អើមកពីភូមិភាគឧត្តរហ្នឹង ហើយគាត់ធ្លាប់បះបោររហូតដល់គេចាប់ខ្លួនហ្នឹង?

ស៊ុយៈ បាទ ។

សុជាៈ ហើយបើតាមពូនិយាយបានន័យភូមិភាគឧត្តរហ្នឹងបះបោរហ្នឹង?

ស៊ុយៈ បាទ ។

សុជាៈ មេធំលើអឿនហ្នឹង ជាកុយ ធួន?

ស៊ុយៈ អាហ្នឹង វាបើតាមខ្ញុំវិភាគហើយខ្ញុំយល់វិញថាអឿនហ្នឹង គាត់នៅក្រោយកុយ ធួនហ្នឹង ។

សុជាៈ កុយ ធួនហ្នឹង ។ ហើយកាលហ្នឹងគេចោទថាកុយ ធួនហ្នឹងគាត់ជាភ្នាក់ងារ ជាខ្សែអីនៅក្នុងហ្នឹងអញ្ចឹង ។

ស៊ុយៈ កុយ ធួនហ្នឹងគេមានឯកសារអីមកចាក់ថត ខ្សែចាក់ខ្សែអាត់ចម្លើយសារភាពពេលដែលលោកខៀវ សំផន ហៅពួក ខ្ញុំទៅរៀន ។

សុជាៈ ហើយគេចាក់អោយស្តាប់?

ស៊ុយៈ គេចាក់អោយស្តាប់ ចម្លើយសារភាព ។

សុជាៈ គេសួរ ឆ្លើយថាម៉េចទៅ?

ស៊ុយៈ ខ្ញុំមិនអាចចាំអត់ទេ ប៉ុនខ្ញុំដឹងត្រង់ថា គោល គោលការណ៍ប្រុងធ្វើរដ្ឋប្រហារប៉ុល ពតច្រើនលើកមកហើយ តែធ្វើមិនបានសំរេច ។

សុជាៈ បាទ ។

ស៊ុយៈ ដាក់តាមរយៈ ដាក់ថ្នាំបំពុល តាមបាយ ពេលប៉ុល ពតត្រូវហូបបាយ ប៉ុល ពតអត់ហូបទៅវិញ ហើយប្រុងសំលាប់ថាចេញមកច្រកហ្នឹងសំលាប់ ប៉ុល ពតមិនចេញច្រកហ្នឹង ។ ប៉ុល ពតចេញច្រកនោះ បាទ ហើយសូម្បីតែឆ្នាំ៧៥ ប្រុងធ្វើឃាតប៉ុល ពតឆ្នាំ៧៥ ណោះ ថាស្រាប់តែចូលទៅមនុស្សយាមរាប់ជាន់មិនឈ្នះ អត់ឃើញអ្នកលាក់ថ្វាស៊ិក ។ សំរាប់សំលាប់មនុស្ស ចូលរហូតដល់អា៎ ចុងក្រោយអាគេផុតសំរាប់ចូលហ្នឹង អន្ទុយកៅអីហ្នឹង អ្នកការពារនៅហ្នឹង ចាប់បានតែម្តង ។ យាមរាប់ជាន់ ផ្ទះ ទាបអីសព្វគ្រប់អស់

ហើយនៅតែរកមិនឃើញ នៅតែចុងក្រោយចាប់បាន ។

សុជាៈ កាលហ្នឹងនៅក្នុងពិធីអីគេបានគេ?

ស៊ុយៈ នៅក្នុងពិធីដូចថាខួបពីឆ្នាំ៧៥ ដូចថាគេអបអរនៅជ័យជំនះអើ ឆ្នាំ៧៥ហ្នឹង ។

សុជាៈ នៅណា នៅណា?

ស៊ុយៈ នៅស្តាតអូឡាំពិកហ្នឹង ។

ភារិទ្ធៈ ចុះខ្មែរខាងណាដែលចូល?

ស៊ុយៈ បាទ ។

សុជាៈ ខ្មែរខាងណាដែលចូលដំបូង?

ស៊ុយៈ ខ្មែរកុយ ឃួនហ្នឹង ។

សុជាៈ កុយ ធួនហ្នឹង?

ស៊ុយៈ បាទ ។

សុជាៈ អញ្ចឹងកុយ ឃួនហ្នឹងគាត់មានគំនិតតាំងពី៧៥មករហូត?

ស៊ុយៈ យូរហើយតាំងពីមុន៧៥ហ្នឹងទៀត ។

សុជាៈ ហើយចុះពូ ខ្ញុំមិនបានដឹងពីរឿងកុយ ឃួនហ្នឹងទេ តែខ្ញុំបានដឹងរឿងខ្លះកង តាមរយៈកង ពលគាត់ឈ្មោះអឿនណោះវិញ ។

ស៊ុយៈ បាទ ។

សុជាៈ បន្តហ្នឹង គេចោទថាអឿនហ្នឹងគឺជា សេ អ៊ី អា ហើយទទួលបានអើ ជំនួយអីពីខាង អាមេរិក អាអីអញ្ចឹងអាំ កាលពីជំនាន់ហ្នឹងពូមានលឺអញ្ចឹងទេ?

ស៊ុយៈ លឺដែរ ក៏ប៉ុន្តែថាអ្វីដែលខ្ញុំលឺមិនច្បាស់ ខ្ញុំមិនអាចរ៉ាយរ៉ាប់បានប៉ុន្តែគ្រាន់តែដឹងថា ពេល គេចាប់កុយ ធួន ហ្នឹងហើយ គេយកខ្មែរអាត់ហ្នឹងមកចាក់អោយស្តាប់ ចម្លើយសារភាព គាត់ធ្វើរដ្ឋប្រហារប៉ុន្មានលើកៗ ប៉ុន្មានលើក មិនបានសំរេច ។

ភារិទ្ធៈ គាត់និយាយអញ្ចឹង?

ស៊ុយៈ បាទ គាត់និយាយខ្លួនគាត់ចាក់ខ្សែអាត់ ។

ភារិទ្ធៈ ពូមានដឹងការស្លាប់របស់សោ ភឹមទេ?

ស៊ុយៈ សោ ភឹមគ្រាន់តែលឺសួរគេគ្នាថាគាត់រត់ទៅវៀតណាមហ្នឹង គេបាញ់ស្លាប់នៅឯព្រំដែន

ណោះ ។

ភារី៍ទ្ធៈ ចុះមានគេថាការស្លាប់របស់គាត់ហ្នឹងដោយសារការសម្លាប់ខ្លួន?

ស៊ុយៈ គាត់ស្លាប់ដោយការសម្លាប់ខ្លួនទេ ព្រោះកាលណាគេដេញទៅ គាត់មិនអោយគេសម្លាប់ គាត់សម្លាប់ខ្លួនគាត់ហើយបាញ់និរសារ ហើយនិងចោលខ្លួនឯងគ្រាន់តែដឹងតគ្នា ប៉ុន្តែ អោយឃើញជាក់ស្តែងអត់ដឹងទេ ។

ភារី៍ទ្ធៈ ពូដែលបានឃើញសាកសពគាត់ទេ?

ស៊ុយៈ អត់ទេ អត់ដែលឃើញទេ បាទ អត់ឃើញ ។

សុជាៈ ពូ អំបាញ់មិញនិយាយពីរឿងការបះបោររបស់កុយ ធួន ហើយចុះឥលូវខ្ញុំចង់សួររបស់ តាណាតវិញម្តង តាណាត។ នៅក្នុងកងពល៧០៣នេះ?

ស៊ុយៈ បាទ ។

សុជាៈ តើគាត់ តើ ចលនារបស់គាត់ហ្នឹងមុនកុយ ធួន រឺក៏ក្រោយ កុយ ធួន?

ស៊ុយៈ ក្រោយ។ ។

សុជាៈ ក្រោយកុយ ធួន។ ហើយចុះណាតហ្នឹងត្រូវបានគេចោទថាយ៉ាងម៉េចខ្លះទៅ?

ស៊ុយៈ ខ្ញុំអត់បានដឹងថាត្រូវគេចោទថាយ៉ាងម៉េចខ្លះទេ គ្រាន់តែខ្ញុំអាចបានដឹងថាវាជាខ្សែរបស់ វ៉ន វ៉េត ។

សុជាៈ វ៉ន វ៉េត?

ស៊ុយៈ បាទ ព្រោះតាណាតហ្នឹង វានៅក្រោមរបាត របស់វ៉ន វ៉េត ។

សុជាៈ បាទ ។

ស៊ុយៈ ក្រោយពីគេធម្មតា កាលហ្នឹងការផ្សារជំនាញ។ធំនៅភ្នំពេញហ្នឹង គឺវ៉ន វ៉េតហ្នឹងគឺគេជាអ្នក រៀបចំហើយ អ្នកណាទៅខាងអី។ អាណាល្អជាងអាណា អាណាយកទៅដាក់អាណាហ្នឹង គឺគេរៀបចំហើយ ដូច្នេះក្រោយមកគេយកអើ ឈ្មោះទាញដែលជាកងពលហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ ក៏ទៅទូត ហើយនិងតាណាតហ្នឹងក៏ទៅទូត ។

សុជាៈ ទៅទូតណាខ្លះទៅ ប្រទេសណាខ្លះទៅ?

ស៊ុយៈ ខ្ញុំភ្លេចហើយប្រទេសណា ប្រទេសពីរអោះ ទៅទូតហ្នឹង ប៉ុនគ្រាន់តែខ្ញុំអត់ចាំឈ្មោះ ។

សុជាៈ  បាទ នៅក្នុងឆ្នាំណាលោកពូ?

ស៊ុយៈ  ឆ្នាំ៧៧ ។

សុជាៈ  ៧៧ ហើយចុះមុន៧៧គាណាគធ្វើអីគេ ៧៧ មក ៧៥ អោះ?

ស៊ុយៈ  ៧៧ មុន គេថាមុនទៅទូតហ្នឹង គាត់សន្តិសុខជាតិ ហើយគាទាញណោះ គាត់អគ្គសេនាធិការ ។

សុជាៈ  ចុះដល់ពេលវ៉ែន វ៉ែតហ្នឹងអេពូនិយាយអំបាញ់មិញថាគាត់ជានេះទេ រដ្ឋមន្រ្តីខស្សរាហកម្មទេ?

ស៊ុយៈ  គាត់រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច ។

សុជាៈ  សេដ្ឋកិច្ច?

ស៊ុយៈ  បាទ ។

សុជាៈ  ក្រសួងសេដ្ឋកិច្ចហ្នឹងហើយម៉េច?

ស៊ុយៈ  ប៉ុន្តែក្រសួងសេដ្ឋកិច្ចដែលវាមាននៅពីក្រោមគាត់ហ្នឹង គឺចេងអនដែលគេទទួលខាងខស្សរាហកម្ម ។

សុជាៈ  បាទ ហើយបើតាមយើងឥលូវអ្នកដែលទៅធ្វើការនៅទូតនៅអី?

ស៊ុយៈ  បាទ ។

សុជាៈ  អោយតែមានការតែងតាំងពីរដ្ឋមន្រ្តីក្រសួងការបរទេស?

ស៊ុយៈ  បាទ ។

សុជាៈ  យើងអត់ជាប់ទាក់ទងជាមួយក្រសួងសេដ្ឋកិច្ចទេ ហើយហេតុអីបាននៅក្នុងតំបន់ហ្នឹងបាន ។ ក្រសួងសេដ្ឋកិច្ចតែងតាំង?

ស៊ុយៈ  អានេះប្រហែលជាគេអាមមានការទាក់ទងគ្នាហើយ ប៉ុនគ្រង់ខ្ញុំត្រឹមតែគ្រាន់តែដឹងថា គេអោយគាត់ធ្វើទៅខាងទូត ។

សុជាៈ  បាទ ។

ស៊ុយៈ  ប៉ុនតែមុននឹងគេទៅគឺគេអាចរៀបចំរចនាសម្ព័ន្ធហ្នឹង គឺតាមថ្នាក់របស់គេទៅហើយ ។

សុជាៈ  បាទ ។

ស៊ុយៈ  ប៉ុនតែគ្រាន់តែដឹងថាគាទាញ គាណាគហ្នឹងគឺគេអោយទៅខាងទូត ។

សុជាៈ បាទ ។

ស៊ុយៈ ក្រោយពីគេចាប់វ៉ន រ៉េតមកបានជាគេចាប់ទាំងតាទាញ ទាំងតាណោតហ្នឹងមកវិញ ។

សុជាៈ បាទ ។

ស៊ុយៈ គេមិនទៅចាប់នៅស្រុកគេណោះទេ គេរបៀបថាដូចថាហៅមកចាប់មកស្រុកវិញមកអញ្ចឹង ណា ។

សុជាៈ ចុះពូនិយាយអំបាញ់មិញ?

ស៊ុយៈ ក្រោយពីមកដល់ស្រុកវិញ គាត់ដើរលាគេលាឯង ឧបមាថាគាត់ធ្លាប់នៅជាមួយខ្ញុំអញ្ចឹង ទៅ គាត់ថាអើ ខំកសាងខ្លួន ប្រយ័ត្ន ប្រយ័ត្ន អ៊ីដែលគេអោយធ្វើអី គឺត្រូវតែធ្វើហ្នឹង ទៅ តែបងគេចាប់ហើយ តែគ្រាន់តែមិនដឹងថាថ្ងៃណាគេចាប់អោយ បងរត់ អត់រត់ទេ សុខចិត្តស្លាប់គេសំលាប់ ក៏សំរាប់ក៏សំលាប់ទៅចុះ អោយរត់អត់រត់ដាច់ខាត ។

សុជាៈ ហើយកាលហ្នឹងគាត់ដឹងខ្លួនគាត់អញ្ចឹង គេចោទតាគាត់ជាស្អីដែរ?

ស៊ុយៈ គាត់គ្រាន់តែគេហៅមកវិញ គឺគាត់ដឹងថាគេចាប់គាត់ហើយ ហើយ ។

សុជាៈ ចាប់តាមខ្សែរយៈ?

ស៊ុយៈ ចាប់តាមខ្សែតែម្តង ហើយអត់បាច់តវ៉ាអីបានទេ តែគេចាប់ហើយ គឺគេចាប់តាមខ្សែ តែម្តង គឺគេថា ដកស្មៅដកអោយអស់ទាំងឫស ។

សុជាៈ វ៉ន រ៉េតហ្នឹងចាប់ក្រោយកុយ ធួនទេអញ្ចឹង?

ស៊ុយៈ ចាប់ក្រោយ ។

សុជាៈ ហើយវ៉ន រ៉េតហ្នឹងត្រូវគេចោទថាយ៉ាងម៉េច គាត់រៀបចំរដ្ឋប្រហារក៏បះបោរអីដែរ?

ស៊ុយៈ អត់ អត់បានទេ ។

ភារិទ្ធៈ ហើយចុះគេចាប់តាណោតហ្នឹងនៅក្នុងឆ្នាំណា?

ស៊ុយៈ ចាប់ឆ្នាំ៧៨ វ៉ន រ៉េតក៏ចាប់ដើមឆ្នាំហ្នឹងដែរ ចាប់បន្តគ្នា ។

សុជាៈ ពូ មិនអាចដឹងគាត់ហ្នឹងជាប់ខ្សែតាំងពីជាមួយកុយ ធួនអីមកទេ?

ស៊ុយៈ អត់ ។

សុជាៈ តែកុយ ធួន ចាប់ឆ្នាំ?

ស៊ុយៈ អត់ទេ ផ្សេងៗគ្នា ។

សុជាៈ ផ្សេងៗគ្នា កុយ ឃួនចាប់ឆ្នាំណា?

ស៊ុយៈ តាំងពីឆ្នាំ៧៥ ។

សុជាៈ កុយ ឈួន ចាប់ឆ្នាំ៧៥?

ស៊ុយៈ បាទ បើតាមតែខ្ញុំដឹង គ្រាន់តែ៧៥ចាប់ពីរផ្នែកអោះ ៧៦ ក៏មានចាប់ ៧៧ក៏មានចាប់ ប៉ុនតែគ្រាន់តែខ្ញុំអត់ ដូចថាខ្ញុំមិនមានជំនាញខាងហ្នឹងអា៎ គ្រាន់តែដឹងថាចាប់អ្នកដែលចង់រដ្ឋប្រហារអីប៉ុនហ្នឹង ។

សុជាៈ កាលហ្នឹងពូដឹងអីតាមរយៈពីណាគេដឹងហ្នឹង?

ស៊ុយៈ អត់ទេវាដឹងតាមរយៈគេហៅ ឧបមាថាយើងទោះបីមិនចូលសម្ពន្ធគេក៏ដោយ ក៏ប៉ុន្តែយើងទទួលគេហៅថាស្តៀននៅហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ គេត្រូវតែហៅរៀនអី អេ គោលការណ៍ការងារដែលត្រូវធ្វើអីៗហ្នឹង គេហៅទៅបង្រៀនហើយ គេហៅថាផ្នែករដ្ឋបាល ។

សុជាៈ អឺ ។

ស៊ុយៈ ផ្នែករដ្ឋបាល លោកខៀវ សំផន គាត់តែងហៅទៅបង្រៀន ។

សុជាៈ ខៀវ សំផនតែមួយទេគាត់ហៅរៀន?

ស៊ុយៈ បាទ គាត់ហៅរៀនញឹកជាងគេ ផ្នែកការងាររដ្ឋបាល ព្រោះអានេះថាមិនមានខ្សែជាមួយគាត់ទេ ប៉ុនតែការងារគាត់គឺខាងរដ្ឋបាល គឺគាត់មាននាទីត្រូវហៅគេ ត្រូវរៀបចំជួរ ។ រដ្ឋបាលតែម្តង បើជួរផ្ទៃក្នុងអាហ្នឹង ប៉ុល ពតអី អាហ្នឹងគេហៅទៅរៀនផ្សេងទៅ ។

ភារីទ្ធៈ ធ្លាប់ទៅរៀនជាមួយនួនជាទេ?

ស៊ុយៈ ធ្លាប់ ធ្លាប់ទៅរៀនដែរ ។

សុជាៈ នួន ជាច្រើនតែរៀនពីខាងអីគេ?

ស៊ុយៈ បង្រៀនពីនយោបាយ នយោអី ។

សុជាៈ ហើយចុះរដ្ឋបាលហើយនយោបាយវាខុសគ្នាយ៉ាងម៉េចបង្រៀន?

ស៊ុយៈ រៀនពីនយោបាយដូចគ្នា ក៏ប៉ុន្តែគ្រាន់ថាមួយដូចគេថាត្រូវរៀបចំភូមិឃុំ រៀបសណ្តាប់ធ្នាប់ភូមិឃុំអញ្ចឹង ឧទាហរណ៍ណា ។

សុជាៈ បាទ ។

ស៊ុយៈ អាហ្នឹងខាងរដ្ឋបាលគេរៀបទៅ ហើយដល់ផ្នែកបក្សហ្នឹងគេរៀបចំថាឧបមាថាគោលការណ៍ត្រូវធ្វើអញ្ចេះ ធ្វើអោយបានអញ្ចេះ ធ្វើអោយបានអញ្ចោះ អាហ្នឹងគោលការណ៍របស់បក្សគេហើយណា ហើយបើគោលការណ៍របស់ខាងរដ្ឋបាល គេថាគោលការណ៍ត្រូវរៀបប្រព័ន្ធភូមិក្រុមត្រូវឃាមអញ្ចេះ ការពារអញ្ចេះ ការពារអីអញ្ចឹងណា បើការងាររបស់បក្សគេបើធ្វើមកគឺធ្វើអោយបានអញ្ចឹងហ្នង ។

សុជាៈ ហើយចុះពូក្រោយមកទៀតពូមានបានលឺពីរឿងចលនារបស់សោ ភឹម?

ស៊ុយៈ ចលនាហ្នឹងក៏ធ្លាប់លឺដែរ តែគ្រាន់តែដឹងថាបរាជ័យ គេចាប់បានខ្សែបានរហូត គ្រាន់តែដឹងថាចលនាមាន ។

សុជាៈ ហើយចុះមេដឹកនាំធំចលនា?

ស៊ុយៈ មេដឹកនាំធំ គឺសោ ភឹមហ្នឹងតែម្តង ។

សុជាៈ សោ ភឹមហ្នឹងហ្នង?

ស៊ុយៈ បាទ ។

សុជាៈ ដឹង១ ដឹង?

ស៊ុយៈ អត់ទេដឹង ពេលគេហៅទៅរៀន រៀន ពីនយោបាយ គេលើកនៃ អេគោលការណ៍អានេះក្បត់ អានេះអីអញ្ចឹង គេចាប់ខ្សែថ្នាក់អញ្ចេះ១ ដូច្នេះដើម្បីបង្ក្រាបបញ្ហាហ្នឹងគឺយើងកំលាំងទាំងអស់ត្រូវយល់ចិត្តទុកដាក់ថាកាលណាខ្សែនេះ វាបង្កប់ចូលអញ្ចេះចូលអញ្ចោះ អាហ្នឹងគេថា ។

សុជាៈ អូ ។

ស៊ុយៈ គេហៅទៅរៀនគឺដឹងតាមរយៈបង្រៀនហ្នឹងតែម្តង បាទ ហើយឧបមាថាចាប់ខ្សែហ្នឹងមួយអាំ ប្រកហ្នឹងត្រូវប្រុងប្រយ័ត្នអាំ ព្រោះវាមានបណ្តាញវានៅនេះ១១គេ ប្រាប់គោល១ទុកអញ្ចឹង ។ ដូច្នេះបើគេមានជំនាញខាងហ្នឹង គេតាមដានខាងហ្នឹងទៅ អញ្ចឹងបានថាគោលការណ៍ហ្នឹងគេចែកឯកសារដែលខ្ញុំចង់និយាយ ឯកសារទន់ប្រាំហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ វាមានតាំងពីគោលការណ៍សំរាប់ចាប់បច្ចេកទេស សំរាប់ចាប់មនុស្សកុំអោយខុស ចាប់

កុំអោយប្រឡូវអីអាហ្នឹង ។

សុជាៈ ពូចាំទេនិយាយពីស្អីខ្លះ?

ស៊ុយៈ បាទ គេនិយាយពី គេហៅថារៀន គេថារៀនគិតនិកខាងចាប់ ។

ភារីទ្ធៈ ពូមានបានរៀនគិតនិកទេ?

ស៊ុយៈ ទេ ខ្ញុំអត់បានរៀនទេ គ្រាន់តែថាសៀវភៅទុកនៅហ្នឹង ហើយមេទៅបាត់ហើយ មន្ទីរនៅហ្នឹងហើយយើងចេះតែលួចមើលទៅណា ។

ភារីទ្ធៈ លួចមើលទៅឃើញម៉េចខ្លះទៅ?

ស៊ុយៈ មើលគេ គេហៅថារៀន ពីគិតនិកមនុស្ស រៀនវិភាគពីទស្សនៈមនុស្ស មនុស្សនេះអោះ គេថាបើគ្រាន់តែឃើញមុខ ចាប់មិនអោយខុសអាំ អាំថារបៀបឃើញមុខ ។ ចាប់មិនអោយខុសវិភាគថាមនុស្សនេះចរិកអញ្ចេះៗ គេហៅថារៀន ទស្សនៈវិភាគឯកសារហ្នឹងគេថាទស្សនៈវិភាគ ។

សុជាៈ អូ សៀវភៅហ្នឹងយ៉ាងម៉េចដែរ ទ្រង់ទ្រាយសៀវភៅ?

ស៊ុយៈ ទ្រង់ទ្រាយសៀវភៅអាហ្នឹងវាថា គេថាឯកសារទង់ប្រាំរបស់គេហ្នឹង ។

សុជាៈ សៀវភៅពុម្ពអេ?

ស៊ុយៈ អាំសៀវភៅបោះដូចគណៈបក្សផ្សេងៗ ដែលគេគោលការណ៍ ថាគោលការគណៈបក្ស ។

សុជាៈ អូ ។

ស៊ុយៈ ដែលធ្លាប់ឃើញគោលការណ៍គណៈបក្សសមរង្សីទេ គេកិបជាសៀវភៅ ថាដូចសៀវភៅរៀនយើងអញ្ចឹង ។

សុជាៈ បាទ ។

ស៊ុយៈ ប៉ុនគ្រាន់តែគេដាក់ជារូបអញ្ចេះ ដូចថារូបទង់រូបអី គេមានរំលិចពណ៌តាមការនឹកឃើញរបស់គេ ។

សុជាៈ បាទ ។

ស៊ុយៈ ប៉ុនតែចូលទៅខាងក្នុងទៅ គ្រាន់តែជាអក្សរសរសេរដែរហ្នឹងអាំ ប៉ុនគ្រាន់តែសរសេរថាដាក់ជាឯកសារទង់ប្រាំអញ្ចឹងទៅ ។

ភារីទ្ធៈ បាទ ពូ ខ្ញុំចូរបកមកក្រោយបន្តិច ចង់សួរការងារដែលទាក់ទងពូនៅខាងឃ្នាំង?

ស៊ុយៈ បាទ បាទ ។

ភារិទ្ធៈ តើពូមានដឹងថាមានឃ្លាំងអាវុធ ខាងអី ហើយខាងណាជាអ្នកកាន់កាប់?

ស៊ុយៈ អត់ទេ ។

ភារិទ្ធៈ ព្រោះបើតាមបញ្ជីហើយតាមឯកសារ ខ្ញុំធ្លាប់ឃើញមានអើ ឯកសារនាំបញ្ចេញអាវុធទៅតាមអង្គភាព តាម?

ស៊ុយៈ បាទៗ ។

ភារិទ្ធៈ ខាងណាដែរ?

ស៊ុយៈ អាហ្នឹងបើតាមខ្ញុំដឹង ព្រោះផ្នែកខាងសឹក គេអត់ដែលអោយខាងឃ្លាំងនេះ ឃ្លាំងនេះគេចាត់ទុកថា ខាងរដ្ឋបាល ដូច្នេះខាងផ្នែកអាវុធ ផ្នែកអីគេអត់អោយចូលមកខាងឃ្លាំងនេះទេ ព្រោះអានេះវាចំហទាំងអស់ចេញចូល ដូច្នេះ គេនាំមក គឺគេចូលផ្ទាល់ៗជាមួយនឹងសេនាធិការហ្នឹងតែម្តង ។

ភារិទ្ធៈ ហើយពូមានដឹងថាអ្នកដែលគ្រប់គ្រងខាងសេនាធិការដែលមើលខុសត្រូវភូមិភាគខាងអាវុធខាងអីហ្នឹង ពីណាគេ?

ស៊ុយៈ អាហ្នឹងខាងអគ្គសេនាធិការ ឈ្មោះតាទាញហ្នឹង ។

ភារិទ្ធៈ តាទាញហ្នឹង?

ស៊ុយៈ បាទ ។

សុជាៈ ហើយចុះក្រោយមកតាទាញហ្នឹងគាត់ចេញទៅធ្វើទូតហ្នឹង?

ស៊ុយៈ ក្រោយមកទៀតអាហ្នឹង ខ្ញុំលែងយល់ហើយ ព្រោះបន្តិចឡើងបានមក៤ ៥ថ្ងៃហើយ អានោះមកចាប់ទៀត អានោះយកមកដាក់៤ ៥ថ្ងៃ អានោះមកចាប់ទៀត ដល់តែអញ្ចឹងវាច្របល់ គេថាវាបែកបាក់ផ្ទៃក្នុងអា៎ អានេះចាប់អានោះ អានោះចាប់អានេះ អានេះចាប់អានោះដល់អញ្ចឹងវា ។

សុជាៈ ចុះពូមានដឹងតួនាទីរបស់តាម៉ុក ជាអគ្គសេនាធិការទេ?

ស៊ុយៈ ក្រោយមកទៀត គ្រាន់តែដឹងថាតាម៉ុក ក្រោយពីចាប់វ៉ិត វ៉ិតហើយ ដំបូងចាប់កុយ ធួន ហើយចាប់វ៉ន វ៉ិតហើយ តាម៉ុក គាត់នៅទទួលបន្ទុក សឹងថាបញ្ជារទ័ពទាំងអស់នៅលើតាម៉ុក ។

ភារី៖  ហើយចុះពូយល់ឃើញយ៉ាងម៉េចដែរនៅកាលពីសម័យគេចាប់ សម័យអី?

ស៊ុយ៖  ខ្ញុំគ្រាន់តែយល់ឃើញអញ្ចេះ យល់ឃើញថាមិនដឹងជាគេចទៅណារួច ដូច្នេះមានតែស៊ូទ្រាំ ហើយតម្រង់ខ្លួនអោយដូចទៀនប៉ុណ្ណឹង មួយយប់មួយថ្ងៃ ខ្ញុំដេកបានតែមួយម៉ោងកន្លះទេ កំលាំង៤០០០នាក់ជាងគេដូរវេណធ្វើការរហូត ចំណែកខ្ញុំអាអត់ធ្មត់ដើម្បីរស់ មានមេធំមួយឈ្មោះ តាទាញ អេតាតេង១ហ្នឹង គាត់បន្តិចទៅទទួលភ្ញៀវនៅសៀមរាប អេនៅកំពង់សោម៦ណោះ ការងារនៅទាំងអស់នៅលើខ្ញុំ ។

ភារី៖  ឈ្មោះតេងហ្នឹង តេងហ្នឹង មិនមែនទាញទេ?

ស៊ុយ៖  តេងផ្សេង ទាញផ្សេង ដល់គេទៅធ្វើការបាត់ទៅ គេអោយខ្ញុំជំនួសហ្នឹង ចុះបើយើងនៅក្រោមគេ ស្រាច់តែគេអោយធ្វើអីត្រូវធ្វើហ្នឹង ដល់អញ្ចឹងកំលាំងគេ បួនម៉ោងគេដូរម្តង១ ដូចខ្ញុំអត់មានអីដូរហ្នឹងគេ ដល់ម៉ោង១១ ១២ យប់ដើរមើលកំលាំងគេធ្វើការ អង្គុយសរុបធ្វើរបាយការណ៍អោយគេទល់ម៉ោង២ គ្រាន់តែចប់ហើយគេឡើងអោយគេ រាយការណ៍អោយគេហើយ ចប់រឿងដើរមើលកំលាំងអោយគេហើយ ម៉ោង៩កន្លះ ដេកម៉ោង ៦ភ្ញាក់ ។

ភារី៖  ហើយចុះកាលសម័យហ្នឹង សម័យខ្មែរក្រហមហ្នឹង ពូមានដឹងថាមានការសំលាប់មនុស្សសំលាប់អីទេ?

ស៊ុយ៖  វា ខ្ញុំគ្រាន់តែដឹងថា អាតែចាប់ហ្នឹង គឺសំលាប់ហើយ ព្រោះអាណាទោសធ្ងន់គេសំលាប់អាណាទោសស្រាលគឺនៅ ប៉ុនគ្រាន់តែដឹងថាចាប់អារម្មណ៍ត្រង់ថា មូលហេតុសំខាន់ត្រង់ដែលគេមិនអោយមកលេងផ្ទះ គេមិនអោយអ្នកស្រុកទៅលេងកូនចៅ គ្រាន់តែដឹងថាអ្វូអានេះកាន់តឹងទៅៗហើយ ហើយគ្រាន់តែដឹងមួយទៀតថា ខ្ញុំចាប់អារម្មណ៍ហើយចាប់ផ្តើមភ័យខ្លួនត្រង់លឺលោករីទ្ធដែលខ្ញុំថា ប្រធានឃ្លាំងហ្នឹងអាត់ គាត់ថាសំរិតសំរាំងអោយតែល្អនៅតែម្នាក់ក៏យកដែរចាប់ផ្តើមភ័យពីត្រឹមហ្នឹងមករហូត ព្រោះការងារអ៊ីមិនហ៊ានអោយហួសពីកន្លះម៉ោងកន្លះនាទីអីទេ ព្រោះដឹងថាគេនិយាយថាអោយតែនៅម្នាក់ល្អក៏យើងនេះដែរ ។

សុជា៖  រីទ្ធហ្នឹងជាអ្នកនិយាយ?

ស៊ុយ៖  រីទ្ធហ្នឹងជាអ្នកនិយាយ ប៉ុនតែត្រង់តែស្តាប់គោលការណ៍ផ្ទៃក្នុងគេ មិនដឹងណែនាំអី

យ៉ាងម៉េច តែយើងនៅក្រោមៗធ្វើតាមតែគេ គេអោយធ្វើអីយើងធ្វើហ្នឹងមិនហ៊ាន
ប្រឆាំង ។

សុជាៈ ហើយចុះពូយល់ឃើញយ៉ាងម៉េចដែរនៅពេលដែលបានទទួលដំណឹងថាបង ?

ស៊ុយៈ បងខ្ញុំក្រោយពីដឹងដំណឹងដែរ ព្រោះខ្ញុំអាចចាប់អារម្មណ៍ដែរ ព្រោះខ្ញុំអាចចាប់អារម្មណ៍
ដែរ ។ ក្រោយពីខ្ញុំនៅភ្នំពេញដែរ កាលពីខ្ញុំនៅខាងទទួលប្រធានបញ្ជីមួយរយខាងឃ្លាំងនៅ
កំពង់ទឹកកកហ្នឹង ខ្ញុំដើរដឹកឥវ៉ាន់តាមរោងចក្រវាល់ថ្ងៃ ។

សុជាៈ ពូដែលជួបគាត់ទេ?

ស៊ុយៈ ជួប ដើរដឹកឥវ៉ាន់តាមរោងចក្រវាល់ថ្ងៃទាំងអស់ ហើយខ្ញុំវាតែងគេថាទោះបីយ៉ាងណា
ខ្ញុំតែងតែលាក់លាមពីនាយគេនាយឯងដើម្បីយកជាអង្ករក្រោម យកជាសាច់ជ្រូកកំប៉ុង
យកមកផ្ញើរក្មួយ ។

សុជាៈ ក្មួយទាំងពីរដែល?

ស៊ុយៈ ក្មួយទាំងពីរនាក់ដែលកូនហ្នឹង ។

សុជាៈ ហើយចុះកូនគាត់ហ្នឹងយ៉ាងម៉េចដែរ?

ស៊ុយៈ ក្រោយពីខ្ញុំមកដឹកឥវ៉ាន់តាមរោងចក្រកាលពីពេលនោះ គាត់នៅអេរោងចក្រឬស្សីកែវអេ
ដែងរោងចក្រចាក់អង្រែ ។ រោងចក្រចាក់អង្រែហ្នឹងគឺនៅរោងចក្រតម្បាញគេហៅថា
តម្បាញក៥ តម្បាញក៥ ដូច្នេះបានន័យថារោងចក្រហ្នឹងគេធ្វើក្រណាត់ដងធ្វើបាយ ។

សុជាៈ បាទ ។

ស៊ុយៈ ដល់តែថ្ងៃមួយខ្ញុំអត់ចាប់អារម្មណ៍ទេ ខ្ញុំដឹកឥវ៉ាន់ញឹកញាប់ទៅខ្ញុំមានពួកម៉ាកមួយគេប្រធាន
រោងចក្រហ្នឹង ដល់តែក្រោយខ្ញុំមកបើកឥវ៉ាន់ ឧបមាដូចខ្ញុំនិយាយខាងដើមអញ្ចឹងថា
ឧបមាថាក្រសួងនេះ រឺក៏ភូមិភាគនេះទៅបើកស្បៀងមុន រឺក៏គ្រឿងក្នុងឃ្លាំងអស់ខ្ញុំ ។
ជូនផ្ទាល់ៗទៅបើកនៅរោងចក្រអាញ្ចឹង ។ ដល់តែទៅបើកផ្ទាល់អញ្ចឹងដល់តែទៅវាក់អើ
ហ្នឹងបងចេញមកចេញមកធ្វើការ ដល់វាក់អើអញ្ចឹងដឹងថាបងនៅហ្នឹង ដល់ក្រោយដឹងថា
នៅហ្នឹង ខ្ញុំសួរថាកូនចៅនៅឯណាខ្លះ ថានៅឯមណ្ឌលកុមារ ដល់តែខ្ញុំទៅបើកក្រោយ ។
ទៀត ក៏ខ្ញុំហ៊ានលួចជាស្ករក្រោម ទឹកដោះគោអីយកមកផ្ញើរក្មួយដល់ពេលគេរៀបយកទៅ
ដាក់កន្លែងកុមារហ្នឹង ខ្ញុំក៏លួចមក ដល់តែលួចមកខ្ញុំថាមកសុំប្រធានរោងចក្រហ្នឹង ។

អោយសុំ សុំអនុញ្ញាតិគេ សុំជួបក្មួយអាំ ហើយគេថាអត់អីទេអាពួកម៉ាក ហើយបានគេយកក្មួយហ្នឹងយកមកអោយពូហើយចង់យកអីមកអោយក្មួយហូបបើគេយកមកអោយគ្នាណោះកុំអោយគេច្រណែន អោយយកហូបកន្លែងទីចាត់ការហ្នឹងគេហ្នឹងមក ។

សុជាៈ បាទ ។

ស៊ុយៈ ហើយខ្ញុំក៏យកអីអោយក្មួយអីហូបនៅទីចាត់ការហ្នឹង ហើយបានមកពីរខែក្រោយមកទៀតមកបានក្មួយមួយស្លាប់បាត់ ។

សុជាៈ ស្លាប់ដោយសារអី?

ស៊ុយៈ ដោយសារជំងឺ ។

សុជាៈ ជំងឺអី?

ស៊ុយៈ ឈឺអត់មានអ្នកណាយកចិត្តទុកដាក់មើល ម្តាយនៅធ្វើការនៅណោះហើយអាកូននៅផ្ញើរគេណោះ អាណាអន្តុយឈ្នះមើលកូនអោយ ។

សុជាៈ អឺ ។

ស៊ុយៈ ដល់អាហ្នឹងស្លាប់មួយអញ្ចឹង ដល់តែក្រោយមកទៀត ស្រាប់តែស្លាប់មួយទៀត ទៅម្តងបាត់មួយៗ ។

សុជាៈ ស្លាប់ដោយសារជំងឺទៀតអេកូនគាត់អេ?

ស៊ុយៈ បាទ ។

ភារិទ្ធៈ ហើយចុះពេលដែលពូទាក់ទងបងប្អូនគាត់មានគេដាក់?

ស៊ុយៈ ខ្ញុំលាក់ណាស់ នៃសូម្បីតែប្រពន្ធខ្ញុំអាំ មាខ្ញុំបង្កើតអា នៅជាមួយគ្នា ខ្ញុំលាក់អត់ស្គាល់ ។ មាខ្ញុំទេ ទាល់តែមកដល់ស្រុក យកគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ ៧៥ ៧៦ ៧៧ហ្នឹងមកហើយអត់ដឹងថាមាននៅជាមួយគ្នាទេ ខ្ញុំលាក់ បើមិនលាក់អញ្ចឹងគេចាប់មាទៅដល់ខ្ញុំ ចាប់ខ្ញុំទៅដល់មា តែប្រពន្ធក៏ហ៊ានប្រាប់ដែរ ។

សុជាៈ ហើយចុះមាហ្នឹងគាត់ស្លាប់ដែរអេ?

ស៊ុយៈ មានៅរស់ទល់សព្វថ្ងៃហ្នឹង ហើយនៅ ឧបមាថាថា នៅភូមិជាមួយគ្នាហ្នឹង បើនិយាយពីភូមិវិញ គេនិយាយពីអន្តភាពតែយើងនិយាយឧទាហរណ៍ថាដូចនៅភូមិជាមួយគ្នាអញ្ចឹង អត់ដឹងថាមា ហើយនិងក្មួយបង្កើតទេ ។លាក់ជាមួយប្រពន្ធទៀតប្រពន្ធខ្ញុំ

ខ្ញុំលោក់រហូតទល់ភ្នាមកស្រុកហ្នឹង បានប្រាប់ថានែមេ ។

សុជាៈ អញ្ចឹងកាលហ្នឹងពូមានកូនឥលូវ?

ស៊ុយៈ អត់ទាន់មានទេ ។

សុជាៈ ហើយ ។

ស៊ុយៈ ហើយបងដែលនៅរោងចក្រហ្នឹងក៏អញ្ចឹងដែរ មកប្រាប់អញ្ចឹង បងឯងលាក់ប្រវត្តិរូបកុំអោយដឹងខ្ញុំ ខ្ញុំលាក់ប្រវត្តិរូបកុំអោយដឹងបងឯង ។ សូម្បីតែមាបង្កើតក៏អញ្ចឹងដែរលាក់ទៅវិញទៅមកទាំងអស់ ដល់តែគេចាប់មួយនោះទៅបាត់ គឺនៅ ដល់តែគេចាប់នេះមួយបាត់ គឺនៅនេះ ។

សុជាៈ ពូ ចុះកាលជំនាន់ប៉ុល ពតហ្នឹងពូមានដឹងថា ដូចមានលឺបក្ស បក្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង?

ស៊ុយៈ មិនអាច ។

សុជាៈ ខាងណា?

ស៊ុយៈ មិនអាចអោយមាន គឺបក្សគេតែមួយហ្នឹងម្តង ។

សុជាៈ ខ្ញុំធ្លាប់លឺអ្នកដែលខ្ញុំធ្លាប់សម្ភាសខ្លះនោះនិយាយលេងបន្តិចមកថា គេថាកាលហ្នឹងមានបក្សកុម្មុយនិស្តមួយ មានប៉ុល ពត អៀង សារី មានតាម៉ុកអីអញ្ចឹង?

ស៊ុយៈ បាទ ។

សុជាៈ ហើយមានបក្សមួយទៀតគេហៅថាបក្សពលករ?

ស៊ុយៈ បក្សពលករ ។

សុជាៈ បាទ ដែលលឺទេ?

ស៊ុយៈ បក្សពលករហ្នឹងវាមានហើយ ប៉ុនតែគ្រាន់ខ្ញុំនិយាយថាបក្សវាមានច្រើនហើយ ក៏ប៉ុន្តែគេមិនអោយបក្សណាងើបរួចទេ គ្រាន់តែ អាណាងើបគេក្តិចៗ ប៉ុនតែគ្រាន់តែបក្សពលករ គឺបក្សពលករវៀតណាមហ្នឹងដែលគេចាប់ផ្តើមវាយផ្តួលប៉ុល ពតហ្នឹង គឺបក្សហ្នឹងហើយដែលផ្តួលបានវាយមុនគេ ។

សុជាៈ បាទ

ស៊ុយៈ តែគ្រាន់មកទៀតខ្ញុំសិក្សារៀនសូត្រទៅ គ្រាន់តែដឹងថា បើសិនជាបក្សពលករនេះមិនវាយ

បានមុនអាំ

សុជា៖ បាទ ។

ស៊ុយ៖ ក៏បក្សខាងលោកសឺន សានបានវាយមកមុនវិញដែរ ។

សុជា៖ កាលហ្នឹងមានបក្សលោកសឺន សានដែរ?

ស៊ុយ៖ បាទ លោកសឺន សានគាត់រៀបទ័ពគាត់នៅខាងស្រុកថៃអោះ ខ្ញុំពេលដែលចេញពីស្រុក ៧៩ទៅ ខ្ញុំទៅមើលទីតាំងគាត់ណោះដែរ ។

ភារិទ្ធ៖ ហើយចុះបក្សគាត់គេហៅបក្សអីដែរ?

ស៊ុយ៖ បក្សសេរីការ គាត់បង្កើតកងទ័ពសេរីការ ហើយរណៈសិរ្សរួបរួមជាតិរបស់លោក សឺន សានហ្នឹង ។

សុជា៖ បាទ អាហ្នឹងតាំងពីមុន៧៩ទៀត?

ស៊ុយ៖ បាទ តាំងពីមុន៧៩ គាត់បង្កើតហើយស្រេច ។

សុជា៖ ហើយចុះពូបក្សពលករវៀតណាមហ្នឹង ពូមានដឹងថាបក្សហ្នឹងដឹកនាំដោយពីណាគេទេ?

ស៊ុយ៖ មិនដឹង ។

ភារិទ្ធ៖ ហើយចុះខាងបក្សអ៊ិន តាំ?

ស៊ុយ៖ ខាងអ៊ិន តាំ ជាមួយខាងលោកតាសឺន សាន ។

សុជា៖ អូ ។

ស៊ុយ៖ បាទ ។

សុជា៖ អើ ពូអើ ពូមានដែលឃើញភ្ញៀវបរទេស បរអីមកលេងកន្លែងពូទេ?

ស៊ុយ៖ អូមកច្រើនអាំ ប៉ុន្តែមកច្រើន ច្រើនតែអញ្ចេះ ច្រើនតែចិន យូហ្គោស្លាវី កូរ៉េ ហើយនិង ។

សុជា៖ ហើយចុះរុស្ស៊ី?

ស៊ុយ៖ អត់ទេ ។

សុជា៖ វៀតណាម?

ស៊ុយ៖ វៀតណាមហ្នឹងហើយ ភូមា ។

សុជា៖ ពូមានចាំឈ្មោះគណៈប្រភូខ្លះទេ?

ស៊ុយៈ ចាំញ៉ែកដាំងគេតែលោកស្អី លោកអីខាងប្រទេសចិន ខាងសេដ្ឋកិច្ចអាំ អឺ ភ្លេចឈ្មោះ លោកហ្នឹង លោកហ្នឹងមកញ៉ែក ។

សុជាៈ ចុះពូអើ ពូបានធ្លាប់ឆ្លងកាត់របបខ្មែរក្រហមអីមក ពូមានដឹងថាមានការចាប់មនុស្ស ឃុំខ្លួនមនុស្ស តើកាលហ្នឹងពូមានដឹងថាការឃុំខ្លួនមនុស្សទាំងអស់ហ្នឹង ពូមានដឹងថាទៅឃុំនៅឯណា ពូមានដឹងទេ?

ស៊ុយៈ គ្រាន់តែដឹងថា អាណាដែលទោសស្រាលអញ្ចឹងគេយកទៅអោយធ្វើផ្លូវរទេះភ្លើងអញ្ចឹងណា អាណាដែលល្មមអញ្ចឹងអាំ ដូចថាចម្លើយមួយអញ្ចឹងអាំ គេអត់យកជាការទេ គេយកមក មកដាក់អាកន្លែងមួយ យកចិត្តទុកដាក់ មើលអាហ្នឹងសេរីទៀតរឺអត់ បើគេចោទថាសេរីបើយើងយកមកដាក់អាហ្នឹង ។ ឧបមាថាមកធ្វើស្រែ គិតតែធ្វើស្រែហ្នឹងទៅ អាហ្នឹងគេចាត់ទុកថាមនុស្សហ្នឹងល្អហើយ ។

សុជាៈ អឺ ។

ស៊ុយៈ គេចោទ រឺក៏ថាបន្ទុចអាណា តែបើយកមកហើយគេដាក់អោយមកធ្វើស្រែធ្វើអី មានបាយអីស៊ីសព្វគ្រប់មកដល់អានេះគិតតែពីដើរ ឧទាហរណ៍ដូចបងខ្ញុំអញ្ចឹង បងខ្ញុំដែលឈ្មោះសាយហ្នឹង អាហ្នឹងរឿងសុទ្ធតែ ។

សុជាៈ ពូដឹងថាគេចាប់ដែរ?

ស៊ុយៈ ដឹង ខ្ញុំថីមិនដឹង ខ្ញុំមានពួកម៉ាកមួយនៅកន្លែងសន្តិសុខហ្នឹង ។

សុជាៈ សន្តិសុខនៅឯណា?

ស៊ុយៈ សន្តិសុខជាតិហ្នឹង ។

សុជាៈ នៅកន្លែងណាពូ?

ស៊ុយៈ អាកន្លែងព្រៃស អាកន្លែងសន្តិសុខព្រៃសអើ កន្លែងខាងសន្តិសុខប្រចាំព្រៃស ។

ភារ័ទ្ធៈ អាហ្នឹងគេហៅអីដែរសន្តិសុខព្រៃស?

ស៊ុយៈ អើ ភ្លេចច្រើនខ្ញុំ ។

សុជាៈ ហើយឆ្នាំណាដែលគេចាប់បងពូឈ្មោះសាយហ្នឹង?

ស៊ុយៈ ចាប់ឈ្មោះសាយតាំងពីឆ្នាំ៧៧ ។

សុជាៈ អូ ។

ស៊ុយៈ គ្រាន់តែបាត់លែងជួបគ្នា ខ្ញុំដឹងថា ដើម្បីកុំអោយជាប់ខ្សែ ខ្ញុំលែងស្រាវជ្រាវសួរហើយ ។

សុជាៈ ហើយពូថាទៅផែកនៅមន្ទីរហ្នឹង ទៅផែកនៅឯណាឃើញ?

ស៊ុយៈ មន្ទីរអាកន្លែង ដែលថាអាឡានឃ្មុប ដែលខ្ញុំថាឡានខាងសន្តិសុខហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ ដល់តែថាស្គាល់ៗគ្នាអញ្ចឹង ស្គាល់ៗអញ្ចឹង ដល់ឧបមាថាខ្ញុំធ្លាប់នៅពីសង្គ្រាមនៅជាមួយគ្នាអញ្ចឹងណា ។

សុជាៈ បាទ ។

ស៊ុយៈ ដល់ពេលមួយគេនៅខាងសន្តិសុខ ហើយខ្ញុំនៅខាងណោះអញ្ចឹងទៅណា ដូច្នេះខ្ញុំចេះតែសួរធ្វើអារបៀបឆ្ងល់ថា គាត់គេមកអញ្ចឹង គេមានបញ្ជីថាត្រូវចាប់អាណាៗ គេមានបញ្ជីរគេមក ។

សុជាៈ អូ ។

ស៊ុយៈ គាមកដល់អញ្ចឹងគេបើងបញ្ជីរហ្នឹងមើល ឧបមាថាគេមកកន្លែងយើងអញ្ចឹង គេមកត្រង់ចាប់ឈ្មោះហ្នឹងអញ្ចឹង គេមកសួរយើង ដូច្នេះយើងប្រាប់ថាឈ្មោះនេះៗអញ្ចឹងទៅ

សុជាៈ អ្នកដែលពូសួរហ្នឹងឈ្មោះអី?

ស៊ុយៈ ឈ្មោះអើ ប៉ុននោះវាជាប្រធានក្រុមទេ មិនមែនអាប្រធានធំជាងគេណា ប៉ុនអានោះវាឈ្មោះអឿន ។

សុជាៈ បាទ ។

ស៊ុយៈ ប៉ុនតែឧបមាថាអោះ អោយក្រុមនេះមកចាប់ មកអញ្ចឹងទៅ រឺក៏អោយក្រុមនោះមកចាប់អាហ្នឹង វាជាក្រុមអ៎ា គ្រាន់តែគេប្រគល់ថាអោះក្រុមនេះទៅចាប់ ក្រសួងនេះអ៎ា ក្រុមនោះទៅចាប់ក្រសួងនោះអញ្ចឹង អាហ្នឹងវាអញ្ចឹង ។

ភារ័ទ្ធៈ បាទ ចុះពូថាប្រធានមន្ទីរសន្តិសុខ ហើយសន្តិសុខហ្នឹងគេនៅឯណា?

ស៊ុយៈ ប្រធានមន្ទីរសន្តិសុខហ្នឹងគេនៅភ្នំពេញហ្នឹងដែរ ។

សុជាៈ ឈ្មោះអីគេ?

ស៊ុយៈ កន្លែងមន្ទីរសន្តិសុខហ្នឹង គឺកន្លែងតាណាតហ្នឹងហ្នង ។

សុជាៈ អូ ។

ស៊ុយៈ ក្រៅពីអាហ្នឹង ដែលគាត់មិនទាន់ទៅខាងទូត ។

សុជាៈ បាទ ។

ស៊ុយៈ គឺគាត់ហ្នឹងប្រធានសន្តិសុខជាតិហ្នឹងម្តង ព្រោះខ្ញុំស្គាល់តាមរយៈមេហ្នឹង ព្រោះតាណាត ហ្នឹងពីដើមឡើយគាត់មេធំខ្ញុំដែរ ។

សុជាៈ ហើយចុះមានដែលលឺមន្ទីរសទេ?

ស៊ុយៈ អត់ដែលស្គាល់ទេ ប៉ុនលឺសួរតែឈ្មោះ ។

សុជាៈ ហើយមានដឹងពីណាគេប្រធានទេ?

ស៊ុយៈ អត់ អត់បានដឹងទេ ។

សុជាៈ ហើយចុះពូដែលលឺគុក ទួលស្លែងទេ?

ស៊ុយៈ លឺដែរ ទួលស្លែងក៏លឺដែរ ។

សុជាៈ ហើយចុះពូមានដឹងថា មន្ទីស ២១ ហើយនិងទួលស្លែងហ្នឹងជាកន្លែងតែមួយទេ?

ស៊ុយៈ អត់ ។

សុជាៈ អត់ទេអេ?

ស៊ុយៈ លឺតែឈ្មោះ អត់ដែលដឹង ។

សុជាៈ ហើយមានពីណា មានដឹងថាពីណាប្រធានហ្នឹងទេ?

ស៊ុយៈ ? ? ? ?

ស៊ុយៈ ហើយចុះពូ ពូខ្ញុំចង់សួរបន្តិចថាពូមានដែលលឺឈ្មោះឌុចទេ ។

សុជាៈ លឺ លឺនៅពេលណាដែរ?

ស៊ុយៈ លឺ លឺអាពេលនៅភ្នំពេញហ្នឹងដែរ ដែលគាត់ទទួលប្រធានគុក ក៏ប៉ុនមិនដឹងគុកទីណាលឺទៅ លឺតែថាប្រធានគុកហ្នឹង ប៉ុនតែមិនដឹងគុកនៅត្រង់ណា ។

សុជាៈ បាទ ។

ភារីទ្ធៈ អញ្ចឹងអាអ្នកសន្តិសុខដែលថាពូទៅសួរហ្នឹង គឺនៅក្រោមការគ្រប់គ្រងរបស់មន្ទីរនោះដែរ?

ស៊ុយៈ អត់ទេការងារគេណោះ សូម្បីតែអ្នកធ្វើការហ្នឹង ក៏អត់ហ៊ាននិយាយ អត់ហ៊ាននិយាយ គ្រាន់តែជួបមុខគ្នា ស្ងាត់អត់មាននិយាយអីទេ ។

សុជាៈ អញ្ចឹងពូ ឌុច ឈ្មោះឌុចហ្នឹងពូស្គាល់ឈ្មោះគាត់តាំងពីឆ្នាំណា?

ស៊ុយៈ បើស្គាល់ ស្គាល់ហ្នឹងតាំងពីមិនដែលស្គាល់មុខ ក៏ប៉ុនតែលឺឈ្មោះតាំងពីឆ្នាំ៧០ មុនបែក មុនភ្នំពេញមករហូត ។

សុជាៈ បាទ ។

ស៊ុយៈ គ្រាន់តែលឺអញ្ចឹង ។

ភារីទ្ធៈ មុនបែកណា?

ស៊ុយៈ យើងពីឆ្នាំ៧៣ ៧៤ទៅរហូត គឺលឺឈ្មោះហ្នឹង លឺរហូតហើយ ។

សុជាៈ គាត់មានឈ្មោះអីផ្សេងទៀតទេ?

ស៊ុយៈ អត់មានឈ្មោះអីទេ ប៉ុនតែគ្រាន់តែដឹងថាបែកភ្នំពេញហើយគឺគ្រាន់តែដឹងថាគាត់ទទួលខាង ប្រធានគុក ប៉ុនមិនដឹងគុកណា ។

សុជាៈ ពូដូចថាអ៊ីៗដែលពូបានរ៉ាយរ៉ាប់ប្រាប់ខ្ញុំពីរឿងរ៉ាវរបបខ្មែរក្រហម ។

**Side B**

ស៊ុយៈ ផ្តាច់ការអ៊ីៗដែលធ្វើគឺនៅលើបក្ស ។

សុជាៈ អឺ ។

ស៊ុយៈ ផលប្រយោជន៍គឺបាននៅលើបក្ស បើប្រជាជនខំ សូម្បីតែដឹកក្រណាត់ លីសែង បាន មួយត្រឹម មាំ ខោអាវ ស្បៀកពាក់តែប៉ុណ្ណឹង អាផលប្រយោជន៍ធំៗបាននៅលើបក្ស ទាំងអស់ ។

ភារីទ្ធៈ ហើយចុះកាលសម័យហ្នឹងពូមានសំគាល់ឃើញថារបបហ្នឹងមានចំណុចណាល្អទេ?

ស៊ុយៈ ចំណុចល្អត្រង់ថាគឺ គ្មានចោរ ខ្ញុំគ្រាន់តែសរសើរថាគ្មានចោរ ហើយចំណុចនេះគឺថា របប នេះខ្ញុំស្អប់ណាស់ ក៏ប៉ុន្តែក៏ខ្ញុំមានចំណុចសរសើរគេថា គេយកចិត្តទុកដាក់ការពារទឹកដី ។ ព្រំដែនគឺ បើចូលទៅវាយថៃ បើឯងមិននៅ មិននៅទៀត វាយដុតចោលៗអត់អោយ នៅ ។

សុជាៈ កាលជំនាន់ខ្មែរក្រហមដែលវាយថៃដែរ?

ស៊ុយៈ ខ្ញុំអត់ដែលវាយទេ ប៉ុនគ្រាន់តែឃើញ ។

សុជាៈ បាទ ។

ស៊ុយៈ ក្រោយមកទៀតដល់អាពេលបែក៧៩ខ្ញុំទៅឃើញហើយ គឺអោយតែបង្គោលឡាក់នៅ

ដផែ្នកអញ្ជឹង គឺត្រង់ហ្នឹងភូមិថៃ វាយហើយដុតចោលឃើញតែសរសរនៅណោះ ។

សុជាៈ កាលហ្នឹងក្រោយ៧៩?

ស៊ុយៈ បាទ ក្រោយ៧៩ហើយកាលជំនាន់ខ្មែរក្រហមគេនៅកាន់កាប់ហ្នឹងអា៎ គឺខ្ញុំឃើញព្រំដែនអត់មានថៃណាចូលវាបានទេ ។

សុជាៈ ហើយចុះរឿងរ៉ាវដែលពូនិយាយប្រាប់ខ្ញុំអំបាញ់មិញហ្នឹងពូមានដែលនិយាយប្រាប់ក្មេងៗរឺ ក៏អ្នកផ្សេងៗទៀតអោយបានដឹងទេ?

ស៊ុយៈ ខ្ញុំតែងតែនិយាយប្រាប់ សូម្បីកូនចៅតែពីបញ្ហារស់នៅក្តី ពីបញ្ហាដំណាក់កាលសង្គមយើងពីជំនាន់នោះ មកជំនាន់នេះក្តី ខ្ញុំតែងតែបរិយាយនិងប្រាប់កូនចៅថា ធ្វើយ៉ាងម៉េចគឺយើងស្វែងយល់ពីដំណាក់កាលមួយទៅដំណាក់កាលមួយ សង្គមនេះវាប្រែប្រួលអញ្ចេះ ពីជំនាន់នោះវាមានដំណាក់កាលសង្គម គឺគេធ្វើអោយមនុស្សយ៉ាងណា ដំណាក់កាលមួយទៀតគេធ្វើអោយមនុស្សយ៉ាងណា ។ ហើយដំណាក់កាលមួយទៀតគេធ្វើអោយមនុស្សយ៉ាងណា ហើយមកដល់ដំណាក់កាលនេះគឺគេត្រូវតែរៀបចំសង្គមអោយមនុស្សវាមនុស្សវាស្គាល់ពីលទ្ធិប្រជាធិបតេយ្យយ៉ាងណាៗ គឺខ្ញុំតែងតែពន្យល់ក្មេងដើម្បីអោយវាយល់ហើយបើកាលណាប្រវត្តិខ្លះដែលយើងដឹងហើយ ចេះហើយ យើងមិនបានផ្សព្វផ្សាយទេក្មេងវាមិនបានយល់ថាជំនាន់នេះអញ្ចេះ ជំនាន់នោះអញ្ចុះ ។

សុជាៈ ហើយចុះពូគិតថារឿងរ៉ាវនេះ គួរតែបំភ្លេចចោល រឺក៏បន្តប្រាប់ក្មេងៗបន្តទៀតដែរ?

ស៊ុយៈ ដើម្បីស្គាល់ហើយដើម្បីហ្នឹងអានេះវាដូចជាប្រវត្តិសាស្រ្តមួយដែរ ។

សុជាៈ អឺ ។

ស៊ុយៈ ដើម្បីជាគំរូមួយដែរ បើកាលណាយើងបំបាត់ចោលអា៎ ក្មេងវាអត់អាចដឹងបានទេ អារបបនេះធ្វើទៅអញ្ចេះហើយ គឺវាជួយស្រឡះពីលទ្ធិប្រជាធិបតេយ្យ ។ ហើយអារបបនេះអេ វាផ្តាច់ការ ។បើយើងមិនលើកយកមកប្រៀបធៀប របបមួយៗ យកមកប្រៀបធៀបទេ ក្មេងអត់យល់ ដូច្នេះដល់តែយើងលើកយកមកប្រៀបធៀបថា របបលទ្ធិប្រជាធិបតេយ្យគេត្រូវទៅធ្វើដូចអញ្ចេះ ហោះលទ្ធិផ្តាច់ការ ។ ។គឺអ៊ីៗវាបានទៅលើអ្នកភូមិអ្នកមានអំណាចទេ ដូច្នេះយើងត្រូវពន្យល់ហេតុផលដើម្បីអោយក្មេងជំនាន់ក្រោយដែលមិនទាន់ស្គាល់ពីលទ្ធិប្រជាធិបតេយ្យហ្នឹង ស្គាល់ពីសិទ្ធមនុស្សអោយវាយល់ ។

សុជាៈ ហើយចុះកាលជំនាន់ខ្មែរក្រហម ៧៥ ដល់ ៧៩ហ្នឹង ពូមានបងប្អូនស្លាប់ប៉ុន្មាន?

ស៊ុយៈ ខ្ញុំបើគិតទៅ មាខ្ញុំក៏ស្លាប់ បងខ្ញុំក៏ស្លាប់ ប្អូនខ្ញុំក៏ស្លាប់ សាច់ជីដូនមួយខ្ញុំក៏ស្លាប់អស់ច្រើនណាស់ សូម្បីតែផ្ទះសំបែងក៏គេរើខ្ទេចខ្ទីដែរ ។

សុជាៈ ចុះពូអើ រឿងរ៉ាវដែលស្លាប់ដែលអីហ្នឹង ហើយបើសិនជាមកដល់រាល់ថ្ងៃពូដឹងថាអ្នកដែលសម្លាប់បងប្អូន ឪពុកម្តាយរឺក៏ ពូមីងពូ ហើយគេរស់នៅជិតខាងពូតើពូមានគំនិតចង់សងសឹកគេទេ?

ស៊ុយៈ ពីដើមឡើយខ្ញុំមានអារម្មណ៍ហ្នឹងមួយដែរ កាលពីមុនដែលខ្ញុំ ដែលធ្វើទាហ៊ានហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ ខ្ញុំទៅធ្វើទាហ៊ានបាត់គេចោទថាខ្ញុំធ្វើមេបាតុកម្ម ហើយខ្ញុំអត់ដឹងសុទ្ធ ទៅធ្វើទ័ពទៅវ៉ាយលុន ណុល អេជិតភ្នំពេញណោះ គេថាខ្ញុំមកធ្វើបាតុកម្មមួយជំនាន់បាតុកម្ម គេរាយការណ៍ទៅរហូតថា ខ្ញុំមេបាតុកម្ម ចិត្តខ្ញុំខឹងហើយកាលហ្នឹង ខ្ញុំធ្វើមេកងហាហើយ កាន់ទ័ពហើយណា ពេលដែលចប់សមរភូមិ គេមករករឿងហើយ ប៉ុន្តែដល់មកទៀតគេដឹងផែនការខ្ញុំគេចេះតែទុក កើត លិច កើត លិច ខ្ញុំផុតអស់ទៅ ។

សុជាៈ បាតុកម្មអីគេពូ?

ស៊ុយៈ នែ សួរអូនខាងណោះដឹងហើយ បាតុកម្មវ៉ាទៅតាមទារសេរីភាពអីគេ មួយជំនាន់យើងពីឆ្នាំ ៧៣ ៧២អេ មុនជំនាន់ខ្មែរក្រហមហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ ហើយអាខ្ញុំអត់ដឹងអីផង ដល់តែគេចោទអញ្ចឹងវ៉ាខឹង ។

សុជាៈ តែបើដឹងអ្នកសំលាប់បងពូ បងអី?

ស៊ុយៈ អូ អត់ទេអានោះ អត់អាចទេ សងសឹក អានេះវ៉ាគ្រាន់តែជាគំនិត ជាទស្សនៈមួយថាគ្រាន់ថាចង់មានគំនិតថាចង់សងសឹកថា មិនអោយមានរបបហ្នឹងកើតមានទៀតតែម្តង បើមានគំនិតសងសឹកហ្នឹងគឺចង់សងសឹកអញ្ចឹងតែម្តង មិនអោយរបបហ្នឹងកើតមានតទៅទៀត

សុជាៈ តាមវិធីណាដើម្បីកុំអោយរបបហ្នឹងកើតមានតទៅទៀត?

ស៊ុយៈ តាមវិធី ខ្ញុំចង់និយាយថាក្រោយពីខ្ញុំឆ្លងកាត់ គ្រាន់តែខ្ញុំអត់ដំបូល ជ្រកម្លប់ ។

សុជាៈ បាទ ។

ស៊ុយៈ ចង់១០ឆ្នាំអាំ ដូច្នេះធ្វើអីក៏មិនបាន ថាអីក៏បាន គឺយើងគ្មានសិទ្ធ ប្រជាជនគ្មានសិទ្ធ ក្រោមរបប ក្រោមអំណាចរបស់គេ អ៊ីដែលធ្វើបានមកគឺគេជាអ្នកចាត់ចែងទាំងអស់ ។ ហើយយើងជាអ្នកតូចតាច យ៉ាងច្រើនបានម្ហូបឆ្ងាញ់ ហើយពេលខ្វះបបររាវទៀតយើងមិនត្រឹមថាឆ្ងាញ់ទេ ឆ្ងាញ់មួយវែកទៅហើយ អាហ្នឹងឆ្ងាញ់ហើយ គេជប់លៀងហើយ អាហ្នឹងបបរមួយវែកទៅហើយ អាហ្នឹងឆ្ងាញ់ហើយ ដូច្នេះទស្សនៈដែលខ្ញុំចង់សងសឹកមិនមែនថាអត់ទេ មាន គឺរូបភាពដែលខ្ញុំចង់សងសឹកហ្នឹង គឺខ្ញុំខំប្រយល់បងប្អូន កូនចៅក្នុងភូមិ ក្នុងឃុំទាំងមូល ។

សុជាៈ បាទ ។

ស៊ុយៈ ថាធ្វើយ៉ាងណា ហើយខ្ញុំតែយកការប្រៀបធៀបកាលជំនាន់នោះមកជំនាន់ដំណាក់កាលមួយៗ ដើម្បីពន្យល់អោយគាត់យល់ថា ដំណាក់កាលនេះយើងនាំគ្នាត្រូវតែបំបាត់អំពើពុករលួយ របបផ្តាច់ការ ។ របបកុម្មុយនិស្តហ្នឹងអោយដាច់ ហេតុអីនេះហើយវាជារូបមន្តដែល ជាទស្សនៈដែលខ្ញុំចង់សងសឹក គឺខ្ញុំចង់បំបាត់របបហ្នឹងអោយដាច់តែម្តង ។

សុជាៈ ហើយរឿងរ៉ាវរបបខ្មែរក្រហមមកដល់រាល់ថ្ងៃនេះ ពូមានដែលលឺពីរឿងរ៉ាវគេបង្កើតតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ស៊ុយៈ ខ្ញុំតែងលឺដែរ ហើយក៏ខ្ញុំពេញចិត្តណាស់ ខ្ញុំពេញចិត្តណាស់ ហើយក៏ខ្ញុំមានអារម្មណ៍នឹក ។ ឃើញស្តាយក្រោយកាលពេលនោះខ្ញុំភ្ញាក់រលឹកដោយចាញ់នយោបាយរបស់គេ គឺត្រូវធ្វើទាហ៊ានមិនខ្លាចស្លាប់ណា មិនត្រូវតែប៉ុនណ្ណឹងអាំ បកមកវិញធ្វើបាបឪពុកម្តាយខ្ញុំ ។ ខ្ញុំចាប់ពន្ធធានាគារអឺហួរហែរអាំ ដូច្នេះមកដល់ពេលនេះក្រោយពីពិចារណាទៅ គឺថាខ្ញុំឈប់ចាញ់បោកអ្នកណាទៀតហើយ ។

សុជាៈ ហើយពូការកាត់ទោសមេដឹកនាំខ្មែរក្រហមហ្នឹងលោកពូចង់អោយមានការកាត់ទោសមេដឹកនាំនៅតាមមូលដ្ឋានដែរ រឺក៏កាត់តែមេដឹកនាំធំនៅថ្នាក់លើទេ?

ស៊ុយៈ អានេះបើនិយាយអោយចំទៅខ្ញុំ ជាទស្សនៈខ្ញុំបើនិយាយថាអ្នកណាក៏ដោយអោយតែជាប់ក្នុងគេហៅថា អាប្រល័យពូជសាសន៍ហ្នឹងគឺខ្ញុំចង់តែកាត់ទាំងអស់ មិនថាតែជំនាន់មុន រឺក៏ជំនាន់នេះផង អ្នកណាក៏ដោយអោយតែមានឈ្មោះថាអ្នកសំលាប់មនុស្សហ្នឹងគឺចង់កាត់ទោសទាំងអស់ ។

សុជាៈ ព្រោះការកាត់ទោសនៅក្នុងច្បាប់តុលាការហ្នឹង គឺគេយកអ្នកដែលពាក់ព័ន្ធពីឆ្នាំ៧៥ដល់៧៩ ទេ?

ស៊ុយៈ បាទៗ

សុជាៈ ហើយពូយល់ថាយ៉ាងម៉េចចំពោះពាក្យយុត្តិធម៌ពូ?

ស៊ុយៈ បាទ ។

សុជាៈ ពូយល់ថាយ៉ាងម៉េចដែរចំពោះពាក្យថាយុត្តិធម៌?

ស៊ុយៈ យុត្តិធម៌គឺអោយសិទ្ធមកដល់ប្រជាពលរដ្ឋ អ្វីដែលប្រជាជនធ្វើទៅហើយអ៊ា អ្វីដែលគេ ហៅថាគ្មានច្បាប់ចែងអ៊ា ប្រជាជនធ្វើអ៊ា អាហ្នឹងគឺអត់អោយតំលៃថាគាត់ខុសទេ ព្រោះ អត់ច្បាប់ បើច្បាប់ចែងហើយតែគាត់អត់ធ្វើអ៊ា អាហ្នឹងបានន័យថាខុស តែអ្វីដែលគ្មាន ច្បាប់ចែងគាត់ធ្វើ ហើយអោយគាត់ខុសអ៊ា អាហ្នឹងគឺគ្មានយុត្តិធម៌ហើយ ។

សុជាៈ ហើយចុះពូពីក្រោយ៧៥ ហើយមក ៧៩ហ្នឹង ពូទៅនៅឯណា?

ស៊ុយៈ ខ្ញុំគ្រាន់ តែខ្ញុំ ស្វែងរកបងប្អូនខ្ញុំដែលស្លាប់ហ្នឹង រហូតហើយពីរនាក់ប្រពន្ធ ដើររកបងប្អូន រហូត តាមរកហ្នឹង គឺតាមរយៈកងទ័ព ចេញពីនៅកន្លែងនេះទៅនៅកន្លែងនោះទៅ សុំគេទៅ ជាមួយទៅ ក្រែងលរកបងប្អូនអញ្ចឹងទៅ នៅមួយខែពីរខែរកមិនឃើញ ចេញពីកន្លែងនេះ ទៅនៅកន្លែងនោះអញ្ចឹងទៅ ។

សុជាៈ ហ្នឹងទៅនៅខាងកន្លែងណា?

ស៊ុយៈ នៅក្នុងទ័ព បើនិយាយអោយចំទៅ ខ្ញុំមួយជុំអ៊ា តាំងពីប៉ៃលិនរហូតទៅដល់ចុងស្រួច ឥសាន ។

សុជាៈ អូ ។

ស៊ុយៈ ប្រទេស ស្វែងរកបងប្អូន ខ្ញុំនៅគិតតែតាំងពីឆ្នាំ៧៩ទៅ ។

សុជាៈ បាទ ។

ស៊ុយៈ ចេញបែកភ្នំពេញ ប៉ុល ពតចាញ់អញ្ចឹងទៅ ទៅ ធ្លាក់ទៅរហូតប៉ៃលិន រហូតអី អើភ្នំ កាង៉ក់ ភ្នំអី ។

សុជាៈ បាទ ។

ស៊ុយៈ ហើយបកមកវិញបានមកនៅចំការដូង ភ្នំម៉ាឡៃ ធ្លាក់អញ្ចឹងមករហូតមកដល់ឧត្តរមានជ័យ

រហូតព្រះវិហារ រហូតដែលគេថាអេទន្ទេអំពៅ ។

សុជាៈ ???

ស៊ុយៈ បាទ ។

សុជាៈ ហើយក្រោយមកចូលមកនៅហ្នឹងភូមិក្នុងឆ្នាំណាដែរ?

ស៊ុយៈ ក្រោយពីហ្នឹងមកវិញ បកមក បានមកនៅគេថាតំបន់មួយឧត្ដរមានជ័យនេះវិញ ក្រោយមកទៀតខាងកក្កបាទក្រហមអន្ដរជាតិគេពង្រើក ដូចថាទទួលជនភាសខ្លួន ។

សុជាៈ អឺ ។

ស៊ុយៈ ពេលនោះខ្ញុំមកធ្វើ គេអោយខ្ញុំធ្វើមេភូមិនៅកន្លែងខ្មែរក្រហមជាមួយតាម៉ុកជាមួយហ្នឹង ។

សុជាៈ បាទ ។

ស៊ុយៈ ខ្ញុំលួចទៅដោះប្រជាជនអោយចេញ ទៅនៅជាមួយអង្គការកាកបាទក្រហមអន្ដរជាតិហ្នឹង ដល់តែចេញទៅអស់ទៅ តាម៉ុករករឿងខ្ញុំ ទីងខ្ញុំក៏អោយខ្ញុំទៅតាមរកកំលាំងហ្នឹងវិញ ។ ល្បិចខ្ញុំ ខ្ញុំថាឥលូវបើអោយខ្ញុំដើរ ខ្ញុំអត់ទៅទេ អោយឡានជូនមក ហើយគេព្រមជូនឡានមក មកដល់អាកន្លែងជនភាសខ្លួនស្រួលហើយ ខ្ញុំមកធ្វើអីវិញ ខ្ញុំលែងមក ។

សុជាៈ អាហ្នឹងនៅក្នុងឆ្នាំណា?

ស៊ុយៈ អាហ្នឹងឆ្នាំ៨៦ ៨៧ហ្នឹង ។

សុជាៈ ហើយពូចូលមកក្នុងភូមិនេះវិញនៅក្នុងឆ្នាំណាដែរ?

ស៊ុយៈ មកដល់ ៩០ ជាង ។

សុជាៈ មកតាមរយៈជនភាសខ្លួនហ្នឹងអេ?

ស៊ុយៈ តាមរយៈជនភាសខ្លួន ។

សុជាៈ ហើយពូមានអ៊ីចង់បន្ថែមទៀតទេ ពេលដែលខ្ញុំ នូវអ៊ីដែលខ្ញុំមិនទាន់បានសួរនាំពូអាំ?

ស៊ុយៈ បាទ ឥលូវខ្ញុំមានតែសំណូមពរអញ្ចេះទេ ។ សូមអោយអង្គការ គ្រប់អង្គការគាត់ជួយធ្វើយ៉ាងណាអោយលទ្ធិប្រជាធិបតេយ្យកើតមាន ដើម្បីរាស្ត្រខ្មែរបានសុខប៉ុណ្ណឹង ដើម្បីកុំអោយមានសង្គ្រាមហើយ កុំអោយរាស្ត្រខ្មែរគាត់វេទនាតទៅទៀត ព្រោះប៉ុន្មានជំនាន់ប្រទេសខ្មែរយើងឃើញតែសង្គ្រាម ។

សុជាៈ អឺ ។

ស៊ុយៈ ប្រជាជនខ្មែររងទុក្ខវេទនាណាស់ រក?

សុជាៈ ចុះពូខ្ញុំសុំសួរបន្តិច បើកាលនៅជំនាន់នៅក្នុងក្រុងភ្នំពេញ ពូមានដែលឃើញវិហារសាសនាកាតូលិកមួយនៅខាងលិចវត្តភ្នំទេ ជាប់សាលាក្រុងរាល់ថ្ងៃ?

ស៊ុយៈ ជាប់សាលាក្រុង ។

សុជាៈ បាទ ។

ស៊ុយៈ ចង់និយាយថាគេបង្កើត រឺក៏គេ ។

សុជាៈ កាលពីរំដោះ ៧៩មក តាមរយៈខ្ញុំសួរគេទៅ គេថាមានវិហារសាសនាកាតូលិកមួយ ។

ស៊ុយៈ បាទ ។

សុជាៈ នៅខាងកើតចំសួនក្មេងវត្តភ្នំហ្នឹង មកលិច មកខាងលិចមក?

ស៊ុយៈ បាទ ។

សុជាៈ តើពូមានឃើញអាហ្នឹងទេកាលហ្នឹង?

ស៊ុយៈ អត់បានឃើញយកចិត្តទុកដាក់ផង អត់ចាប់អារម្មណ៍ ។

សុជាៈ ចុះពូថាអើគេចាប់ឪពុកម្តាយដាក់គុកហ្នឹងនៅឆ្នាំណា?

ស៊ុយៈ ដឹង មិនដឹងឆ្នាំប៉ុន្មានទេ កាលគេយកប៉ាខ្ញុំដាក់ចំណាងហ្នឹង អាហ្នឹងគ្រាន់តែខ្ញុំអត់នៅទេ តែខ្ញុំនៅណោះ ប៉ុនតែលឺគេប្រាប់ខ្ញុំ ។

សុជាៈ បាទ ។

ស៊ុយៈ គេចាប់យកទៅអោយធ្វើលបធ្វើអី គេថាគាត់ហ្នឹងកូនធ្វើមេបាគុកម្មជាប់សមាសភាពអីអញ្ចឹងណា ។

ភារីទ្ធៈ អូតាំងពីមុនសម័យខ្មែរក្រហម?

ស៊ុយៈ បាទ ។

ភារីទ្ធៈ អញ្ចេះខ្ញុំគ្រាន់តែចង់បញ្ជាក់ត្រង់ថា ពូអត់ពេញចិត្តរបបខ្មែរក្រហម?

ស៊ុយៈ បាទ ។

ភារីទ្ធៈ ហើយចុះក្រោយពេលដែលបែក៧៩ ពេលវៀតណាមវាយចូលអាំ ហើយពូរត់ទៅតាមខ្មែរក្រហមអញ្ចឹង ពូមានដែលគិតថាធ្លាប់ គេចខ្លួនចេញអីទេ?

ស៊ុយៈ គេច រកផ្លូវគេច តែដល់តែឆ្ងាយហួសហេតុពេក ហើយណាមួយយើងវាគ្មានមធ្យោបាយ

វាផ្លូវដើង បើកាលណាយើងរត់មិនរួចគេតាមទាន់ យើងត្រូវតែស្លាប់ ម៉្លោះហើយ ។ ដល់តែរកល្បិច ចេះតែរកៗគេតាមដំណើរអញ្ចឹងទៅ គ្រាន់តែដឹងថា អង្គការសិទ្ធមនុស្ស គេបង្កើតភា្ជម ខ្ញុំរកមធ្យោបាយទៅចូលអាហ្នឹង ។

ភារិទ្ធៈ អញ្ចឹងនៅខាងខ្មែរក្រហមហ្នឹងពេលដែល ពេលដែលចេះតែរត់អញ្ចឹង តើគេឃោសនា យើងយ៉ាងម៉េចដែរ បានមានអ្នកខ្លះ កាលទៅធ្វើខ្មែរក្រហមមានលទ្ធភាពរត់មកស្រុក វិញ?

ស៊ុយៈ គេ នយោបាយគេ គេថាយួនអាក អ្នកធ្លាប់ធ្វើការងារនៅពីដើមប៉ុន្មាន ហើយទៅក្រុង ។ ប៉ុន្មានហ្នឹងគេអាក ដល់តែហើយ ដល់តែម្យ៉ាងទៀតដល់តែវា គេហៅថារបបសេដ្ឋកិច្ច ដង្ហើមរស់នៅជាមួយគេអា៎ បើយើងទាល់តែតាមគេ ។

ភារិទ្ធៈ ហើយអំបាញ់មិញ ខ្ញុំចង់សួរអញ្ចេះ ពូថាចង់អោយតុលាការខ្មែរក្រហមដែលនឹងកើតមាន នៅពេលខាងមុខនេះ?

ស៊ុយៈ បាទ ។

សុជាៈ អោយកាត់ទោសអ្នកណាក៏ដោយអោយតែពាក់ព័ន្ធទៅនឹងការប្រល័យពូជសាសន៍?

ស៊ុយៈ បាទៗ ៗ ។

សុជាៈ ហើយចុះខ្ញុំ ហើយពូដែលមានគិតថាមានបញ្ហាអីកើតមានទៀតទេ?

ស៊ុយៈ ជាទស្សនៈខ្ញុំទោះបីកើតក៏ខ្ញុំ ព្រោះធ្លាប់ឆ្លងកាត់ហើយ ខ្ញុំអត់ខ្លាចទេ អោយតែអង្គការហ្នឹង កាត់ទោសខ្មែរក្រហម ទោះបីកើតសង្គ្រាមក៏ខ្ញុំសុខចិត្តគាំទ្រលំបាកយ៉ាងណាក៏ខ្ញុំតស៊ូដែរ ។

ភារិទ្ធៈ អញ្ចឹងទោះបីយ៉ាងណាក៏ដោយពូចង់អោយថាអោយតែអ្នកណាខុសយកមកកាត់ទោស?

ស៊ុយៈ បាទ ខុសយកមកកាត់អាហ្នឹងវាថាត្រឹមត្រូវ ព្រោះដោយសារតែអ្នកទាំងអស់ហ្នឹងហើយ បានជាបងប្អូនខ្ញុំស្លាប់ ។

ភារិទ្ធៈ អញ្ចឹងអំបាញ់មិញពូស្គាល់តាមអ្វីដែលពូរៀបរាប់ប្រាប់ខ្ញុំពូហ្នឹង ពូស្គាល់មេដឹកនាំខ្មែរ ក្រហម សឹងតែទាំងអស់?

ស៊ុយៈ បាទ ។

សុជាៈ ហើយបើដូចជា ច្បាប់គេដឹកនាំតែមេដឹកនាំធំៗអញ្ចឹង?

ស៊ុយៈ បាទ ។

ភារីទ្ធៈ តើមេដឹកនាំណាខ្លះដែលពូយល់ថាគួរតែយកមកកាត់ទោស?

ស៊ុយៈ អានេះបើវាជាទស្សនៈខ្ញុំវិញ ព្រោះថាអ្នកទាំងអស់គ្នាហ្នឹងក៏គេហៅថា បើជាទស្សនៈខ្ញុំយល់ទៅវិញគឺថា មិនមានគ្នាក្បត់ទាំងអស់ទេ ក៏ប៉ុន្តែមួយនៅក្រោមឱវាទរបស់គេ ហើយមួយទៀតបញ្ជារគេផ្ទាល់ បាទ អាហ្នឹងគួរយកកាត់ទោសដែរ តែបើដូចខ្លះនៅក្រោមឱវាទរបស់គេ គ្នាត្រូវតែធ្វើតាមគេហើយ ដើម្បីរស់ ។

ភារីទ្ធៈ អញ្ចឹង ខ្ញុំចង់គ្រាន់តែថា ចង់សួរបញ្ជាក់ពូអើ ពូស្គាល់ឈ្មោះសឹងតែទាំងអស់មេដឹកនាំធំៗអាំ ប៉ុន្តែតាមអើច្បាប់គេកំណត់អោយកាត់ទោសតែមេដឹកនាំធំៗ?

ស៊ុយៈ បាទ ។

ភារីទ្ធៈ តាមគំនិតពូផ្ទាល់ដែលធ្លាប់ឆ្លងកាត់ហើយរស់នៅមុន ហើយក្នុងរបប ជំនាន់ខ្មែរក្រហមហើយក្រោយមកទៀតដែលចេះតែរត់តាមរស់នៅជាមួយខ្មែរក្រហមទៀត តើក្នុងគំនិតពូផ្ទាល់តើពូចង់អោយកាត់ទោសមេដឹកនាំឈ្មោះអីខ្លះ ហើយថ្នាក់ណា ថ្នាក់ណាអី?

ស៊ុយៈ ខ្ញុំជាទស្សនៈខ្ញុំ ខ្ញុំចង់បានអញ្ចេះ ព្រោះខ្ញុំគេហៅថា មិនអាចដឹងការងាររអ្នកភូមិទាំងអស់ ។ អ្នកណាធ្វើអី អ្នកណាធ្វើអីទេ ជាទស្សនៈខ្ញុំគ្រាន់តែចង់ពឹងផ្អែកទៅលើអង្គការដែលស្រាវជ្រាវដឹងថាអ្នកនោះជាអ្នកប្រល័យពូជសាសន៍ ។ឧបមាដែលតាដូច តាយាមគុកអំបាញ់មិញ វាគួរដែរ ពីព្រោះថាហ្នឹងហើយជាអ្នកផាយសំលាប់មនុស្សផាយបំផុតហើយហ្នឹង ។ តែបើក្រៅៗពីហ្នឹងទៀត ឧបមាថាដូចជាលោកនេះ លោកនោះ លោកណាៗដែលថាមិនទាក់ទងដល់ការ កាប់សំលាប់មនុស្សហ្នឹង ។ ក៏គួរអនុគ្រោះដែរ ព្រោះថាសាច់គ្នាមិនបានស៊ីហើយអោយគ្នាយកឆ្អឹងញូរក អាហ្នឹងក៏អត់ល្អដែរ ព្រោះថាគ្នាអត់បានមកធ្វើអាហ្នឹងផងមានតែឈ្មោះមេដែរ ប៉ុន្តែយើង ។

ភារីទ្ធៈ ហើយចុះដូចតាម៉ុកដែលពូធ្លាប់នៅជាមួយផ្ទាល់?

ស៊ុយៈ បាទ ។

ភារីទ្ធៈ ហើយចុះពូយល់ថាយ៉ានម៉េច គួរតែកាត់ទោសរឺអត់?

ស៊ុយៈ អានេះវា ខ្ញុំមិនហ៊ានសន្និដ្ឋានទេ ព្រោះអញ្ចេះ ព្រោះថារបបមួយៗ គឺបើខ្ញុំនិយាយវិញសំខាន់លើគេគឺប៉ុល ពតហ្នឹងតែម្តង ព្រោះគ្មានបញ្ជារពីប៉ុល ពតគឺ ។

ភារីទ្ធៈ ហើយចុះឥលូវពូដឹងថាប៉ុល ពតស្លាប់ហើយ?

ស៊ុយៈ បាទ ។

ភារិទ្ធៈ ឆ្នាំ៩៨ អើអញ្ចឹងក្រោយពីប៉ុល ពតស្លាប់ហើយ យើងគួរកាត់ទោសពីណាទៀត ក្រៅពីប៉ុល ពត?

ស៊ុយៈ អានេះវាដូចខ្ញុំបញ្ជាក់ហើយអញ្ចឹងថា អ្នកណាដែលគេហៅថាចូលក្នុងលក្ខណៈមួយថាដៃដល់អាំ ខ្ញុំចង់អោយកាត់ទោសអ្នកនោះ ហើយខ្ញុំក៏មិនអាចហ៊ាននិយាយថាឈ្មោះអ្នកនេះ អ្នកនោះដែរ ពីព្រោះថាខ្ញុំជាអ្នកតូចអ្នកតាចមិនដឹងសកម្មភាពអ្នកណាមួយគេធ្វើយ៉ាំងម៉េច អ្នកណាមួយគេធ្វើយ៉ាំងម៉េចណា ។

ភារិទ្ធៈ បាទ ហើយចុះបញ្ហាខ្ញុំចង់សួរបញ្ជាក់ចុងក្រោយ តើបញ្ហាផ្សះផ្សារជាតិអាំ ដែលខ្មែរក្រហមចំណាំតែនិយាយដែរ?

ស៊ុយៈ បាទ ។

ភារិទ្ធៈ តើពូយល់ថាយ៉ាំងម៉េចខ្លះ?

ស៊ុយៈ ចង់និយាយពីជំនាន់ឥលូវៗ ។

ភារិទ្ធៈ ឥលូវហ្នឹង?

សុជាៈ ចង់និយាយថាអញ្ចេះ ចង់និយាយថាអើការកាត់ទោសមេដឹកនាំខ្មែរក្រហមហ្នឹងវាអាចប៉ះពាល់ទោសដល់ការផ្សះផ្សារជាតិដែរ?

ភារិទ្ធៈ ផ្សះផ្សារជាតិ ដូចជាការលើកលែងទោសដល់អៀង សារីអីអញ្ចឹងអាំ ហើយចំពោះពូផ្ទាល់ពូយល់ឃើញយ៉ាំងម៉េចដែរ?

ស៊ុយៈ អេ ចំពោះបញ្ហានេះ វាគ្រាន់តែវាជាទស្សនៈខ្ញុំ បើគ្រាន់តែថាបើនៅតែពន្យារពេលខ្លាំងពេក ប្រជាជនម្នាក់ៗវារងទុក្ខតែរាស្ត្រទាំងអស់ ព្រោះថាប្រជាជនដែលគាត់ខំបោះឆ្នោតអោយហើយអាំ អ្នកឧទាហរណ៍ថាអ្នកកាន់គណៈបក្សនេះ គ្នារងារ ។

សុជាៈ បាទ ។

ស៊ុយៈ ខ្លះអត់ហ៊ានដេកផ្ទះ ដូច្នេះអាំអ្នកគណៈបក្សដែលមានអំណាច ចេះតែមកគំរាមគ្នាអញ្ចឹងទៅដូច្នេះអាំ ខ្លះមករកគំរាមថាឯង ថាដឹងថាអានេះឈ្មោះអានោះឈ្មោះឯង មក ។

ភារិទ្ធៈ អត់ទេ ខ្ញុំចង់និយាយអញ្ចេះ ត្រង់ថាអញ្ចេះបញ្ហាតុលាការខ្មែរក្រហមហ្នឹងវាមានការប៉ះពាល់ដល់ការផ្សះផ្សារជាតិជាមួយរដ្ឋាភិបាល យើងសព្វថ្ងៃជាមួយខាងភាគីខ្មែរក្រហមដែរ

រឺអត់?

ស៊ុយៈ អារឿងប៉ះពាល់អាំ អាហ្នឹងបើនិយាយ ខ្ញុំវាគ្មានរឿងអីត្រូវប៉ះពាល់ទេ បានជាខ្ញុំយល់ថាវាគ្មានរឿងអីត្រូវប៉ះពាល់ ព្រោះតុលាការកាត់ទោសវាជារឿងតុលាការផ្សេង ហើយអានេះវាជារឿងផ្សះផ្សារជាតិវាជារឿងផ្សេងដាច់ស្រឡះពីគ្នា ។

ភារីទ្ធៈ អញ្ចឹងខ្ញុំដូចជាអស់ហើយ ប៉ុន្តែពូមានសំណួមពររឺក៏មានជាស្នឹចង់បញ្ជាក់ថែមទេ?

ស៊ុយៈ ខ្ញុំជាទស្សនៈខ្ញុំគ្រាន់តែថាអញ្ជេះ សុំអោយអង្គការគ្រប់អង្គការទាំងអស់ មេត្តាជួយគេថាដល់អ្នកក្រីក្រផង ព្រោះកំពុងស្រែកឃ្លានលទ្ធិប្រជាធិបតេយ្យព្រោះប្រជាជនមិនចង់ថាបានអារបបដាច់ការហ្នឹងទេ ។ បាទដូច្នេះសំណួមពរខ្ញុំអត់មានអីច្រើនទេ គ្រាន់តែចង់អោយអង្គការជួយធ្វើម៉េចអោយស្រុកខ្មែរយើងវាឆាប់ស្រុសស្រួលត្រូវគ្នាទៅ អ្នកណាធ្វើអីក៏ធ្វើទៅ អាហ្នឹងអោយថាវាស្រុសស្រួលគ្នាមក ។

ភារីទ្ធៈ ហើយចុះដល់ពេលបង្កើតមានតុលាការហើយពូធ្លាប់ដឹងរឿងរ៉ាវអីច្រើនអញ្ចឹង?

ស៊ុយៈ បាទ ។

ភារីទ្ធៈ បើខាងតុលាការគេហៅពូទៅបំភ្លឺ រឺក៏ទៅ?

សុជាៈ ជាសាក្សី ។

ភារីទ្ធៈ និយាយពីអ្វីដែលពូធ្លាប់ដឹងលឺអីអញ្ចឹងអាំ ពូហ៊ានទៅទេ?

ស៊ុយៈ ខ្ញុំអត់ញញើត ហើអត់ខ្លាច ត្រង់អ្វីដែលខ្ញុំធ្លាប់ឃើញ អ្វីដែលខ្ញុំធ្លាប់ដឹងគឺខ្ញុំអាចហ៊ានហើយមានដីហគឺមិនរុញរាដាច់ខាត តែខ្ញុំចង់បញ្ជាក់ថាអ្វីដែលខ្ញុំធ្លាប់ឃើញហើយនិយាយទាំងប៉ុន្មាននេះគឺខ្ញុំហ៊ានទទួលខុសត្រូវ ។

សុជាៈ អញ្ចឹងខ្ញុំអរគុណពូច្រើន?

ភារីទ្ធៈ អរគុណច្រើន ។

ស៊ុយៈ បាទៗ ។

## ចប់

សុជាៈ បទសម្ភាសន៍នេះធ្វើឡើងដោយខ្ញុំឈ្មោះសុជា និងសុភារីទ្ធ ជាមួយនឹងឈ្មោះរស់ ស៊ុយជាប្អូនរបស់ វាន នួន ដែល ពីរឿងរបស់ការស្រាវជ្រាវផ្ទាល់ ហើយគាត់ជាអ្នកដែលគ្មានប្រវត្តិរូបដែលតាមរក នៅភូមិពាមប្រជុំ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល

សម្ភាសន៍ចប់នៅម៉ោង ១ និង ១៥នាទី នៅថ្ងៃទី ១៩ ឆ្នាំ ២០០៣ ។